ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី “ឌុច”
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៩**

**សវនាការលើកទី៤៧**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវ៉ែន

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាតាចា វីស៊ែល រីសឺ

*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក សេង ប៊ុនឃាង

លោក វិលៀម ស្មីត *(Mr. William SMITH)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំពែល *(Mr.Zachery LAMPEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រ៉ូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គឹម ម៉េងឃី

លោក គង់ ពិសី

លោកស្រី ស៊ីលឃី ស្ទួតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកឃ្វីន (ហ្សាកកាំង)

*(Mrs. Martine Jacquin)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

**មេធាវីជំនួយការរបស់សាក្សី ហ៊ីម ហ៊ុយ៖**

លោក គង់ សំអុន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

# ឧបសម្ព័ន្ធ

## សាក្សី

### លោក ហ៊ីម ហ៊ុយ ហៅ ហ៊ឹម ហ៊ុយ

សួរដោយ លោក សេង ប៊ុនឃាង ផ្តើមពី........................ទំព័រ ២
សួរដោយ លោក វីលៀម ស្មីត ផ្តើមពី........................ទំព័រ ១០
សួរដោយ លោក អាឡាំង វែនណឺ ផ្តើមពី........................ទំព័រ ១៩
សួរដោយ កញ្ញា ទី ស្រ៊ីនណា ផ្តើមពី........................ទំព័រ ២៤
សួរដោយ លោកស្រី ស៊ីលឃីស្ទួត ហ្សិនស្គី ផ្តើមពី........................ទំព័រ ២៧
សួរដោយ លោកស្រី ម៉ាទីន ហ្សាកកាំង ផ្តើមពី........................ទំព័រ ៣៤
សួរដោយ លោក គឹម ម៉េងឃី ផ្តើមពី........................ទំព័រ ៣៧
សួរដោយ លោក ហុង គឹមសួន ផ្តើមពី........................ទំព័រ ៣៩
សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី........................ទំព័រ ៤៥
សួរដោយ លោក ការ សាវុត្ថ ផ្តើមពី........................ទំព័រ ៤៩
សួរដោយ លោក ហ្វ្រង់ស្វ័រ រូ ផ្តើមពី........................ទំព័រ ៥៣
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី........................ទំព័រ ៦៥

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក ហ៊ឹម ហ៊ុយ | ខ្មែរ |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រ៉ូ | បារាំង |
| លោក សេង ប៊ុនឃាង | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# **កិច្ចដំណើរការនីតិវិធី**

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០៧:១៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មសាក្សីនៅក្នុងរឿងក្តី០០១ តទៅទៀត ។

មុននឹងដំណើរការនីតិវិធី ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គលដែលត្រូវអញ្ជើញឲ្យចូលរួមនៅក្នុងដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធានភាគី ដែលត្រូវចូលនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការ និងបុគ្គលដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ មានវត្តមានគ្រប់ចំនួន ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វីលៀម ស្មីត៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ។ ខ្ញុំចង់លើកមតិខ្លីមួយព្រឹកនេះ គឺទាក់ទងទៅនឹងវិធាន២៨.៨ ទាក់ទៅនឹងចម្លើយដាក់បន្ទុកខ្លួនឯង គឺថាបញ្ហានេះគឺថាអាចនឹងត្រូវធ្វើសវនាការជាអសាធារណៈ ។ ហើយដូច្នេះ ដល់ចំណុចណាមួយនោះ គឺអាស្រ័យទៅលើអង្គជំនុំជម្រះជាអ្នកសម្រេចថាត្រូវអសាធារណៈ អាចនឹងដប់ ឬ ដប់ប្រាំម៉ីនុត ឬម្ភៃម៉ីនុត សូមជម្រាបអ៊ីចឹង ។

[០៩:០៩:២៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះនឹងយកសំណូមពររបស់តំណាងសហព្រះរាជអាជ្ញានេះយកមកពិចារណានៅក្នុងអំឡុងពេលនៃដំណើរការសវនាការ ហើយការពិភាក្សានេះ គឺយើងនឹងធ្វើនៅក្នុងពេលណាមួយនៅពេលខាងមុខនេះ ។ ជាពិសេសអាចនឹងក្រោយពេលដំណើរការមួយរយៈ ឬក៏ក្រោយពេលឈប់សម្រាក ។

មន្ត្រីតុលាការអញ្ជើញសាក្សី ហ៊ឹម ហ៊ុយ ឲ្យចូលមកកាន់បន្ទប់សវនាការ ។

អរុណសួស្តីលោក ហ៊ីម ហ៊ុយ ថ្ងៃនេះអង្គជំនុំជម្រះបន្តស្តាប់សក្ខីកម្មរបស់លោក ក្នុងនាមលោកជាសាក្សី ហើយមុននឹងផ្តល់វេទិកានៃការសួរព័ត៌មានផ្សេងៗពីលោកទៅតំណាងសហព្រះរាជអាជ្ញា ខ្ញុំសូមធ្វើការរំឭកអំពីសិទ្ធិ និងករណីកិច្ចរបស់លោកក្នុងនាមលោកជាសាក្សីៗលោកអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ឬក៏អំណះអំណាងមួយ ឬច្រើនដែលនាំឲ្យដាក់ពិរុទ្ធភាពទៅលើខ្លួនលោក ។

សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថា ដោយសារតែចម្លើយឬអំណះអំណាងនោះនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់ ។ នេះយើងបានប្រាប់លោកតាំងពីដើមហើយ ហើយជាការរំឭកសាជាថ្មី ។

ទីពីរ អំពីករណីកិច្ចក្នុងនាមលោកជាសាក្សី លោកមានករណីនិយាយតែកាលណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ ហើយដោយលោកមិនត្រូវសេចក្តីសន្និដ្ឋាននូវអ្វីដែលលោកមិនបានដឹង មិនបានឃើញ មិនបានឮនោះឡើយ ។

លោក យល់ទេ? យល់ទេ ហ៊ីម ហ៊ុយ?

[០៩:១២:៥៣]

**លោក ហ៊ីម ហ៊ុយ៖**

បាទ ខ្ញុំយល់ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះសូមប្រគល់វេទិកានេះទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីធ្វើការសាកសួរដល់សាក្សីរូបនេះ ។ អង្គជំនុំជម្រះសូមជម្រាបថា សហព្រះរាជអាជ្ញាមានពេលវេលាមួយម៉ោងដើម្បីធ្វើការសាកសួរនេះ ។ សូមអញ្ជើញ ។

**សួរដោយលោក សេង ប៊ុនឃាង៖**

សូមអរគុណលោកប្រធាន ។ អរុណសួស្តីលោក ហ៊ីម ហ៊ុយ ខ្ញុំមានសំណួរមួយចំនួនចង់ឲ្យលោកជួយបញ្ជាក់ ។ លោកបានជម្រាបជូនអង្គសវនាការថា កាលបញ្ជូនអ្នកទោសមកដល់កន្លែងទទួលអ្នកទោស ដែលបច្ចុប្បន្នជាវិទ្យុសំបុកឃ្មុំ ហើយគេបែងចែកអ្នកទោសសំខាន់ចូលគុកស-២១ ហើយអ្នកទោសដែលមិនសំខាន់គឺបញ្ជូនទៅព្រៃស ។

**ស៖** សំណួរថា តើពេលនោះអ្នកណាជាអ្នកសម្រេច ថាអ្នកណាជាមនុស្សសំខាន់? ហើយមនុស្សណាដែលមិនសំខាន់?

[០៩:១៤:១៧]

**ឆ៖** បាទ ខ្ញុំសូមជម្រាបថា អ្នកសំខាន់ ហើយនិងអ្នកមិនសំខាន់គឺដែលគេបញ្ជូនមកដល់កន្លែងពួកខ្ញុំគឺឲ្យធ្វើឈ្មោះបាទ ។ ឲ្យធ្វើឈ្មោះ អ្នកណាធ្វើឈ្មោះហើយ អ្នកណាសំខាន់គេឲ្យយកចូលក្នុងអ្នកណាមិនសំខាន់គេឲ្យដក គេដកឈ្មោះ គេចុចឈ្មោះហ្នឹងហើយគេឲ្យបញ្ជូនទៅព្រៃស ។

**ស៖** អរគុណ ។ ចង់សួរថាតើអ្នកណាគេជាអ្នកសម្រេចពេលនោះ?

**ឆ៖** បាទ, ខ្ញុំសូមបន្ថែម អ្នកសម្រេចគឺមន្ទីរ ស-២១ គឺតាឌុច ជាអ្នកសម្រេច ។

**ស៖** អរគុណ ។ អ៊ីចឹងមានន័យថា អ្នកទោសដែលមុននឹងបញ្ជូនមកដល់កន្លែងទទួលហ្នឹង គឺគេបានសម្រេចហើយ ថាអ្នកទោសណាដែលជាមនុស្សសំខាន់ ហើយអ្នកទោសណាដែលជាមនុស្សមិនសំខាន់ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** អរគុណ ។ អ្នកទោសដែលត្រូវគេបញ្ជូនមកគុកស-២១ ហើយ តើធ្លាប់មានគេដោះលែងទៅព្រៃសដែរទេ?

[០៩:១៥:៥៦]

**ឆ៖** ខ្ញុំសូមជម្រាបថា អ្នកទោសដែលដោះលែងទៅព្រៃសតែជាប់គុកហើយគេអត់ដោះទេ។

**ស៖** សំណួរសួរថា អ្នកទោសដែលគេបញ្ជូនចូលគុកមន្ទីរស-២១ តើធ្លាប់មានអ្នកទោសហ្នឹងគេបញ្ជូនទៅព្រៃសដែរទេ?

**ឆ៖** បាទ, អត់មានបញ្ជូនទៅទេ ។

**ស៖** អរគុណ ។ ជនជាប់ចោទគាត់ធ្លាប់បានបញ្ជាក់ថា នៅមន្ទីរស-២១ ក៏មានឡានដែលជាប្រភេទឡាំប្រ៊ីតាដែរ ។ តើលោកអាចបញ្ជាក់បានទេ ថាឡានឡាំប្រ៊ីតានោះធ្លាប់យកចេញទៅចាប់មនុស្សនៅទីក្រុងភ្នំពេញដែរទេ? មានទេឡានឡាំប្រ៊ីតានុ៎ង?

**ឆ៖** ខ្ញុំសូមជម្រាបថា ឡានឡាំប្រ៊ីតាមួយហ្នឹង ខ្ញុំថាឡានតូចដឹកបន្លែហ្នឹងគឺឡាននុ៎ង សម្រាប់ដឹកបន្លែអត់មានសម្រាប់យកទៅចាប់អ្នកទោសទេ ។

**ស៖** អរគុណ ។ ទាក់ទងនឹងទាហានវៀតណាមៗដែលបញ្ជូនមកស-២១ ហើយ ជាទូទៅគេទុកប៉ុន្មានថ្ងៃដើម្បីសួរចម្លើយ?

[០៩:១៧:៣០]

**ធ៖** បាទ,ខ្ញុំសូមជម្រាបលោកថា រឿងទុកប៉ុន្មានថ្ងៃៗគឺខ្ញុំអត់ដឹងទេ ។ ខ្ញុំដឹងតែខ្ញុំទទួលយកមកបញ្ជូនទៅដាក់ ឲ្យគេដាក់គុកហ្នឹង ត្រង់ថាប៉ុន្មានថ្ងៃៗខ្ញុំអត់បានដឹងដែរ ។

**ស៖** អរគុណ ។ លោកដឹងទេថា ចម្លើយសារភាពដែលអ្នកទោសវៀតណាមហ្នឹងបានឆ្លើយតើគេយកចម្លើយនុ៎ងទៅធ្វើអ្វីខ្លះ?

**ធ៖** ខ្ញុំសូមជម្រាបលោក! ចម្លើយដែលគេសួរបានមកហើយគេយកទៅចាក់ផ្សាយតាមវិទ្យុ ។

**ស៖** អរគុណ ។ លោកធ្លាប់ស្តាប់ឮទេតាមវិទ្យុហ្នឹង?

**ធ៖** ខ្ញុំសូមជម្រាបលោក! វិទ្យុគឺបើកស្តាប់ឮសួរនិយាយភាសាវៀតណាម ចង់រាល់តែថ្ងៃ ។

**ស៖** អរគុណ ។ តើលោកដឹងទេថាធ្លាប់មានទាហានវៀតណាមដែលគេចាប់បញ្ជូនមកស-២១ ហើយ គេចាប់យកទៅបណ្តើរតាមផ្លូវដើម្បីឲ្យគេមើល តើមានអ៊ីចឹងដែរទេ?

[០៩:១៩:០៥]

**ធ៖** បាទ, គឺអ៊ីចឹងមែនលោក ។

**ស៖** តើលោកដឹងថា មូលហេតុអ្វីទេដែលគេយកទាហានវៀតណាមទៅបណ្តើរតាមផ្លូវអ៊ីចឹង?

**ធ៖** បាទ, ពេលនោះគេដាក់ទាំងជួរ គេដាក់ទាហានវៀតណាមស្លៀកពាក់ជាខោអាវជាឯក-សណ្ឋានជាទាហានហ្នឹង ហើយគេថតៗយកទៅបញ្ចាំងកុន ។

**ស៖** អរគុណ ។ ទាក់ទងនឹងកន្លែងសួរចម្លើយ តើលោកធ្លាប់ឃើញកន្លែងសួរចម្លើយនិងកន្លែងធ្វើទារុណកម្មទេ? ហើយកន្លែងទាំងនោះមានទាំងអស់ប៉ុន្មាន? ហើយស្ថិតនៅកន្លែងណាខ្លះ? លោកអាចដឹងទេ?

**ធ៖** បាទ, ខ្ញុំសូមជម្រាបលោក! កន្លែងសួរចម្លើយគឺនៅខាងមុខៗនែ៎! កន្លែងគុកហ្នឹងចំហៀងខាងកើតជិតលូទឹកស្អុយនោះ តែកន្លែងគេមានប៉ុន្មានៗខ្ញុំអត់ដឹងដែរ ។

[០៩:២០:១៣]

**ស៖** អរគុណ ។ លោកមានដឹងទេថានៅកន្លែងសួរចម្លើយ ឬក៏កន្លែងធ្វើទារុណកម្មនុ៎ងមានទុកឧបករណ៍ធ្វើទារុណកម្មជាប្រចាំនៅក្នុងបន្ទប់នោះដែរទេ?

**ធ៖** បាទ, ខ្ញុំសូមជម្រាបលោក! រឿងឧបករណ៍អីហ្នឹង គឺខ្ញុំអត់បានដឹងអីទេ ព្រោះពួកផ្នែកការពារ គឺដោយឡែកអត់មានទៅទាក់ទិនជាមួយនឹងអ្នកសួរចម្លើយទេ ។

**ស៖** អរគុណ ។ ទាក់ទងទៅនឹងការរៀបចំអ្នកទោសដើម្បីបញ្ជូនយកទៅសម្លាប់នៅជើងឯក ដែលលោកថា ត្រូវបណ្តើរអ្នកទោសទាំងនោះឡើងឡាន តើមានអ្នកទោសណាដែលមិនអាចដើររួចទេ? ហើយអ្នកទោសដែលមិនអាចដើររួចនោះដោយខ្លួនឯងនោះ តើគេធ្វើយ៉ាងម៉េចដែរទៅលើអ្នកទោសនុ៎ង?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! អ្នកទោសដែលដើរមិនរួចនុ៎ង គឺអ្នកយាមគឺក្រៀកអ្នកទោសម្នាក់ គឺពីរនាក់ អ្នកយាមពីរនាក់ក្រៀក ធ្វើម៉េចឲ្យបានឡើងដល់ឡាន ។

**ស៖** អរគុណ ។ នៅពេលដែលរៀបចំដឹកអ្នកទោសចេញយកទៅសម្លាប់នោះ តើលោកបានឃើញ ឌុច ឈរមើលឬក៏បញ្ជាឲ្យធ្វើនេះធ្វើនោះអីទេ?

**ឆ៖** បាទ,ខ្ញុំសូមជម្រាបលោក! ពេលដែលដឹកអ្នកទោសយកទៅជើងឯកហ្នឹង តាឌុច អត់បានមកឈរមើលទេ តែឈ្មោះដែលអ្នកដែលត្រូវយកទៅហ្នឹង គឺគាត់អ្នកសម្រេច អ្នកបញ្ជាឲ្យគេដឹកយកទៅ ។

**ស៖** អរគុណ ។ តើលោកធ្លាប់ដឹងថាមានមន្ទីរឈ្មោះ ៩៨ ដែរទេ?

**ឆ៖** បាទ,ខ្ញុំសូមជម្រាបលោក! ខ្ញុំអត់ដែលបានទៅដល់ពេទ្យហ្នឹងទេ ប៉ុន្តែប្រពន្ធ តាឌុច ហ្នឹងគឺប្រធានពេទ្យ ព-៩៨ ហ្នឹង ។

**ស៖** អរគុណ ។ លោកដឹងទេថា មន្ទីរពេទ្យព-៩៨ ហ្នឹងមានទំនាក់ទំនងអ្វីខ្លះជាមួយនឹងមន្ទីរ ស-២១?

[០៩:២២:៥៣]

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក គឺខ្ញុំអត់បានដឹងដែរទេ ។

**ស៖** អរគុណ ។ អ៊ីចឹងលោកដឹងទេថា ទាហានខ្មែរក្រហមដែលត្រូវរបួសនៅក្នុងសង្គ្រាម ភាគច្រើនគេបញ្ជូនទៅមន្ទីរពេទ្យណា តើលោកដឹងទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក គឺខ្ញុំអត់បានដឹងដែរ ។

**ស៖** អរគុណ ។ អ៊ីចឹងថា តើនៅ ស-២១ មានការបូមឈាមអ្នកទោសដែរទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក គឺខ្ញុំអត់បានដឹងដែរ រឿងបូមឈាមបូមអីហ្នឹង ព្រោះខ្ញុំនៅខាងក្រៅនេះ ។

**ស៖** អរគុណ ។ នៅពេលមានអ្នកទោសឈឺធ្ងន់ តើធ្លាប់មានអ្នកទោសនោះទៅសង្គ្រោះនៅទីណាដែរទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! អ្នកទោសដែលឈឺធ្ងន់ គឺមានតែនៅក្នុងគុកហ្នឹងទេ ដែលពេទ្យចាក់ថ្នាំចាក់អី ពេទ្យនៅគុកនុំងដែលអ្នកចាក់ថ្នាំចាក់អីហ្នឹង ។

**ស៖** អរគុណ ។ កាលពីសប្តាហ៍មុន ថ្ងៃព្រហស្បតិ៍ លោកបានជម្រាបជូនអង្គសវនាការថា ក្រុមរបស់ ប៉េង ជាអ្នកយកក្មេងៗដែលមកជាមួយម្តាយ ដែលត្រូវគេចាប់បញ្ជូនខ្លួនមកស-២១ ហ្នឹង យកទៅសម្លាប់ តើលោកដឹងទេថាការសម្លាប់ក្មេងៗទាំងនោះ គឺធ្វើឡើងដោយវិធីអ្វីខ្លះ? យ៉ាងម៉េចខ្លះ?

**ឆ៖** បាទ,ខ្ញុំសូមជម្រាប! ថ្ងៃមួយដែលគេត្រូវបញ្ជូនម្តាយ បញ្ជូនឪពុកហ្នឹងយកទៅសម្លាប់នៅជើងឯកហ្នឹង គឺពួក ប៉េង គេយកក្មេងៗហ្នឹងទៅបាត់តាំងពីមុនហើយៗ តែដឹងគេយកសម្លាប់តាមយុទ្ធវិធីណាក៏ខ្ញុំអត់ដឹងដែរ ។

**ស៖** អរគុណ ។ លោកធ្លាប់ដឹងទេ ថាតើមានបុគ្គលិក ស-២១ ណាធ្លាប់ប្រព្រឹត្តខុសសីលធម៌លើអ្នកទោសដែលជាស្ត្រីដែរទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក គឺមានកងការពារម្នាក់ដែលរំលោភ គឺក្មេងទេៗរំលោភនារីហ្នឹងដល់ហើយគេចាប់ដាក់គុកដែរទៅ ។

**ស៖** អរគុណ ។ លោកបាននិយាយថា ការចាប់ខ្លួនអ្នកដែលមកពីបរទេស ជាពិសេសមកពីប្រទេសបារាំង គឺ ប៉ង់ ដែលជានីរសារក្រុងហ្នឹង ជាអ្នកចាប់បញ្ជូនមកស-២១ តើលោកដឹងទេថា ប៉ង់ នោះបម្រើការងារនៅអង្គភាពណា ហើយ ប៉ង់ ហ្នឹងមានតួនាទីធ្វើអ្វីខ្លះ?

[០៩:២៦:២៦]

**ឆ៖** បាទ,ខ្ញុំសូមជម្រាបលោក អ្នកដែលមកពីប្រទេសបារាំង គឺ តាប៉ង់ ហ្នឹងបញ្ជូនយកមកឲ្យកន្លែងពួកខ្ញុំចាប់ហ្នឹង គឺគេថាគាត់ជានីរសារក្រុង ប្រធាននីរសារក្រុង ។

**ស៖** តើលោកដឹងទេថា ប៉ង់ ហ្នឹងនីរសារក្រុងហ្នឹង នៅក្នុងអង្គភាពអ្វី ហើយគាត់មានតួនាទីអ្វីផ្សេងទៀតទេ?

**ឆ៖** បាទ, ខ្ញុំដឹងតែគាត់ថានីរសារក្រុង ហើយដឹងគាត់ទទួលនាទីជាអ្វី ក៏ខ្ញុំអត់បានដឹងពីគាត់ដែរ។

**ស៖** អរគុណ ។ ទាក់ទងនឹងការងាររដ្ឋបាលនៅក្នុងមន្ទីរស-២១ ដូចជាការវាយតម្លៃអំពី ស្នាដៃការងាររបស់បុគ្គលិកស-២១ ជាដើម តើលោកដឹងទេថា ការឡើងឋានៈរបស់បុគ្គលិកស-២១ ហ្នឹងសម្រេចឡើងដោយរបៀបណា? ហើយតើមានលិខិតតែងតាំងអីទេ?

**ឆ៖** បាទ,ខ្ញុំសូមជម្រាបលោក អ្នកដែលធ្វើការនៅកន្លែងបុគ្គលិកនៅ ស-២១ ហ្នឹងគឺគ្មានលិខិតស្នាមអីបញ្ជាក់ពីអ្វីមួយ គឺគ្មានទេ គឺដូចថាគេចាត់តាំងឲ្យធ្វើតែម្តង ។

**ស៖** អរគុណ ។ អ៊ីចឹងមានន័យថា បើចង់ឲ្យអ្នកណាឡើងឋានៈអ្វីមួយគឺមានគេចាត់តាំងតែម្តងអ៊ីចឹងមែនទេ?

**ឆ៖** បាទ, គឺអ៊ីចឹងមែន ។

**ស៖** អរគុណ ។ តើលោកដឹងទេថា ហ៊ី មានសិទ្ធិសម្រេចតែងតាំង ឬក៏ដំឡើងឋានៈបុគ្គលិក ស-២១ ដែរទេ?

**ឆ៖** បាទ, ខ្ញុំអត់បានដឹងថា គាត់ទាក់ទងរបៀបយ៉ាងម៉េចជាមួយដែរ ប៉ុន្តែដូចខ្ញុំគេចាប់កម្មាភិបាលចង់អស់ហើយ នៅសល់ប៉ុន្មានពីរនាក់ តាហ៊ី អ្នកឲ្យខ្ញុំឡើង អនុកងរយបណ្តោះអាសន្ន ។

**ស៖** អរគុណ ។ លោកដឹងទេថា តើ ឌុច ធ្លាប់រារាំង ឬក៏ដាក់ទណ្ឌកម្មដល់បុគ្គលិករបស់ខ្លួនដែលបានធ្វើទារុណកម្មទៅលើ ដ៏អមនុស្សធម៌ទៅលើអ្នកជាប់ឃុំដែរឬទេ?

**ឆ៖** បាទ, គឺពិតប្រាកដមែន ។

**ស៖** បានន័យថា ឌុច ធ្លាប់មានដាក់ទណ្ឌកម្មដែរ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ។

**ស៖** នៅ ស-២១ តើមានរៀបចំបុគ្គលិករបស់ខ្លួនឲ្យរៀបការអ្វីទេ?

[០៩:២៩:៤៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ !

**លោកស្រី ស៊ីលឃី ស្ទូតហ្សិនស្គី៖**

សូមអភ័យទោស សុំរំខានលោកសហព្រះរាជអាជ្ញា ថាតើសំណួរចុងក្រោយនេះ សូមឲ្យលោកព្រះរាជអាជ្ញាសួរឡើងវិញ ហើយនិងឆ្លើយវិញ ដោយសារក្នុងការបកប្រែអត់ទាន់ស្តាប់បាន ដោយសារចៅក្រម ឡាវែន៍ គាត់ស្តាប់មិនបាន ។ សូមលោកសហព្រះរាជអាជ្ញា តំណាងសហព្រះរាជអាជ្ញាសួរឡើងវិញ ។

**ប្រធានអង្គជំនុំ៖**

លោក ហ៊ីម ហ៊ុយ អំមិញអាចច្រឡំ ហើយសូមរំឭកលោកម្តងទៀតថា មុននឹងឆ្លើយលោកបង្អង់

បន្តិចរង់ចាំក្បាលមេក្រូហ្នឹងមានភ្លើងពណ៌ក្រហម នោះទើបលោកអាចនិយាយទៅឮដល់អ្នកប្រតិចារឹក អ្នកធ្វើការកត់ត្រា ហើយអ្នកបកប្រែភាសា ។ យល់ទេ?

សូមអញ្ជើញបន្តទៀត ។

**លោក ហ៊ីម ហ៊ុយ៖**

បាទ, ខ្ញុំយល់ ។

**សួរដោយលោក សេង ប៊ុនឃាង៖**

**ស៖** អ៊ីចឹងខ្ញុំសូមអនុញ្ញាតសួរសំណួរនោះឡើងវិញ ។ តើលោកដឹងទេថា ឌុច ធ្លាប់បានរារាំង ឬក៏ដាក់ទណ្ឌកម្មដល់បុគ្គលិករបស់ខ្លួន ដែលបានធ្វើទារុណកម្មដ៏អមនុស្សធម៌លើអ្នកជាប់ឃុំដែរឬទេ? លោកស្តាប់យល់ទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! គឺ តាឌុច គាត់អត់មានរារាំងទេ ។

**ស៖** អរគុណ ។ សំណួរបន្តសួរថា នៅស-២១ តើមានការរៀបចំឲ្យបុគ្គលិករៀបការដែរទេ?

**ឆ៖** បាទ,ខ្ញុំសូមជម្រាបលោក គឺក្នុងមន្ទីរស-២១ ហ្នឹងគឺរៀបចំឲ្យមានគ្រួសារមានតែគ្នាប៉ុន្មាននាក់ ប្រហែលជាបួនប្រាំនាក់ហ្នឹងទេ ក្រៅពីហ្នឹងគ្មានទាំងអស់ ។

[០៩:៣២:២៨]

**ស៖** អរគុណ ។ តើការរៀបការហ្នឹង មានការស្ម័គ្រចិត្ត ឬក៏ព្រមព្រៀងរវាងគូស្រករទាំងសងខាងដែរទេ? ហើយអ្នកណាគេជា អ្នកណាជាអ្នករៀបចំកម្មវិធីហ្នឹង?

**ឆ៖** បាទ,ខ្ញុំសូមជម្រាប! គឺ តាឌុច អ្នករៀបចំកម្មវិធីហ្នឹង ។

**ស៖** តើគូស្រករដែលគេរៀបចំឲ្យរៀបការហ្នឹង តើព្រមព្រៀងនឹងការរៀបចំនេះដែរទេ?

**ឆ៖** បាទ,ខ្ញុំអត់ដឹងដែរ ឃើញរៀប ដល់ពេលគេស៊ីបាយស៊ីអីបានគេឲ្យខ្ញុំទៅ ស៊ីបាយស៊ីអីហ្នឹងគេហ្នឹងទៅ ។

**ស៖** អរគុណ ។ ទាក់ទងនឹងរូបលោក តើរូបលោកហ្នឹងធ្លាប់ធ្វើការទិតៀនអ្វីទៅលើ ឌុច លើបញ្ហាណាមួយដែរទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក! ខ្ញុំអត់ហ៊ានទិតៀនគាត់ទេ ខ្លាចកំបុតក្បាល ។

**ស៖** អរគុណ ។ លោកដឹងទេថានៅស-២១ ហ្នឹងតើមាននរណាដែលបញ្ជា ឌុច ជាប្រចាំដែរទេ?

**ឆ៖** បាទ, នៅ ស-២១ នេះគ្មាននរណាបញ្ជាគាត់ទេ មានតែគាត់បញ្ជាគេ ។

**ស៖** អ៊ីចឹង តើលោកដឹងទេថា បើសិនជា ឌុច ចង់ដោះលែងនរណាម្នាក់ដោយខ្លួនឯង តើគាត់អាចធ្វើបានទេ? ផ្ទុយទៅវិញបើសិនជា ឌុច ចង់ចាប់ខ្លួននរណាម្នាក់ទោះបីជាគ្មានបញ្ជាថ្នាក់លើក៏ដោយ តើ ឌុច អាចធ្វើអ៊ីចឹងបានទេ?

**ឆ៖** បាទ,ខ្ញុំសូមជម្រាប គឺគាត់ធ្វើបានទាំងអស់ ព្រោះកន្លែងហ្នឹងសេចក្តីសម្រេច គឺនៅលើគាត់ធំជាងគេគឺគាត់ហើយ បាទ ។

**ស៖** អរគុណ ។ តើលោកដឹងទេថា ឌុច មានកាន់អាវុធជាប់ខ្លួនដែរទេ?

**ឆ៖** ខ្ញុំសូមជម្រាបលោក អាវុធគាត់កាំភ្លើងខ្លីមួយដើម ប៉ុន្តែមិនដឹងម៉ាកអីទេ គឺគាត់មិនដែលដើរចោលកាំភ្លើងរបស់គាត់ទេ តាមខ្លួនគាត់ ។

[០៩:៣៤:៥៨]

**ស៖** ហើយលោកធ្លាប់ឃើញគាត់យកកាំភ្លើងហ្នឹង យកទៅប្រើធ្វើអ្វីដែរទេ?

**ឆ៖** បាទ, ខ្ញុំដឹងថាគាត់ដាក់តាមខ្លួនរហូត ការពារខ្លួនគាត់ ។

**ស៖** អរគុណ ។ លោកបានជម្រាបជូនអង្គសវនាការថា កាលពីលើមុនថា ជនជាតិថៃក៏ត្រូវបានគេចាប់បញ្ជូនមកស-២១ដែរ តែត្រូវដោះលែងទៅវិញ ។ តើលោកដឹងថា ជនជាតិថៃនោះ ត្រូវគេចាប់នៅកន្លែងណា? ហើយអង្គភាពណាជាអ្នកចាប់? ចាប់ដោយសារមូលហេតុអី? លោកដឹងទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ជនជាតិថៃនោះ ក៏មិនដឹងគ្នាប៉ុន្មាននាក់ដែលទៅចាប់យកមកហ្នឹង ហើយក៏មិនដឹងថាអង្គភាពណាចាប់មក គឺថាចាប់មកពីដែនពីសមុទ្រ ។

**លោក សេង ប៊ុនឃាង៖**

អរគុណ ។ លោកប្រធានខ្ញុំអស់សំណួរសួរទៅលើសាក្សី ហ៊ឹម ហ៊ុយ ហើយ ប៉ុន្តែសុំអនុញ្ញាតលោកប្រធាន ដើម្បីសួរសំណួរមួយ ឬក៏ច្រើនប្រសិនជាមានពាក់ព័ន្ធទៅជនជាប់ចោទ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។ ជនជាប់ចោទចាំស្តាប់នូវសំណួរ ហើយឆ្លើយតបទៅនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាជាតិ ។

**លោក សេង ប៊ុនឃាង៖**

អរគុណលោកប្រធាន ។ លោក ហ៊ឹម ហ៊ុយ បាននិយាយថា ជនជាតិថៃក៏ត្រូវបានចាប់បញ្ជូនមកស-២១ ដែរ ហើយត្រូវបានដោះលែងទៅវិញ តើលោកបានដឹងពីបញ្ហានេះដែរទេ? ប្រសិនជាមាន

ការដោះលែងវិញមែននោះ តើលោកអាចបញ្ជាក់បានទេថា ហេតុអ្វីបានជាត្រូវដោះលែងអ៊ីចឹង?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ជនជាតិថៃនេះក៏ដូចជាពួកមន្ត្រីមកម្ពុជាដែរ ។ ខ្ញុំអត់ឃើញនឹងភ្នែកទេ តែបញ្ជីវានៅសល់សម្រាប់ឲ្យខ្ញុំវិភាគ ។ មន្ត្រីមកម្ពុជាទាំងប៉ុន្មាននាក់នោះក៏ស្លាប់ ជនជាតិថៃនេះក៏ស្លាប់ តែចូលមកដល់ស-២១ហើយ អត់មានដោះលែងទេ នេះសូមបញ្ជាក់ដោយខ្លីប៉ុណ្ណេះ ។

[០៩:៣៧:៥៥]

**លោក សេង ប៊ុនឃាង៖**

អរគុណ ។ លោកប្រធានខ្ញុំអស់សំណួរហើយ សូមខាងសហការីអន្តរជាតិបន្តសំណួរបន្ថែម ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។

**ស៖** លោក ហ៊ឹម ហ៊ុយ អរុណសួស្តី! ខ្ញុំចង់សួរលោកមួយចំនួន ថាតើលោកមានអារម្មណ៍យ៉ាងម៉េច នៅពេលដែលអនុវត្តការងាររបស់លោកនៅស-២១? ថាតើលោកនៅ-- កាលដែលលោកនៅស-២១ នោះ គឺលោកជាអ្នកសរសេរកំណត់ហេតុប្រវត្តិរូប របស់លោកខ្លួនឯងផ្ទាល់ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមជម្រាប! ខ្ញុំអត់ចេះសរសេរទេ ឲ្យ ហេង ដែលជាអ្នកកាន់តេអូ សរសេរឲ្យខ្ញុំ ។

**ស៖** ខ្ញុំសូមនិយាយដកស្រង់ចេញពីប្រវត្តិរូបនោះ ហើយឲ្យលោកផ្តល់យោបល់ ។ លោកថា នៅថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ឯកសារលេខ D5 លេខ ERN 0052499 រហូតដល់ 00052406 ។ អង់គ្លេស 0014104-0014108 ហើយនិងបារាំង 0028003 ទៅដល់លេខ 002800102 ។

ខ្ញុំដកស្រង់ចេញពីជាភាសាអង់គ្លេស ដែលមាន 001410407 រហូតដល់លេ 08 នៅចុង ។ លោក ហ៊ឹម ហ៊ុយ នៅក្នុងប្រវត្តិរូបរបស់លោក លោកបានបញ្ជាក់ថា ខ្ញុំកំណត់សម្គាល់ឃើញអត្តចរិតរបស់ខ្ញុំ ហើយខ្ញុំធ្វើការងារដើម្បីបំពេញការងាររបស់ខ្ញុំ ដែលបានដាក់ការងារមកជូនខ្ញុំ ដោយមិនខ្វល់ថាវាលំបាកប៉ុនណា ការលំបាកនោះគឺវាមានភាពពាក់ព័ន្ធស្មុគស្មាញណាស់នៅក្នុងការងារនេះ ។ ខ្ញុំព្យាយាមធ្វើហើយនៅចុងក្រោយខ្ញុំបានបំពេញដោយសម្រេចដើម្បីជូនបក្ស ។ ហើយបន្ទាប់មកលោកនិយាយអំពី

ការខ្វះខាតរបស់លោក លោកនិយាយមិនសូវមានសុជីវធម៌ទៅសមមិត្តរបស់លោក ហើយលោកឆាប់ខឹង ។ ហើយការដឹកនាំរបស់ខ្ញុំនោះ គឺមិនជាយកចិត្តទុកដាក់ប៉ុន្មានទេ ហើយខ្ញុំធ្វើការងារយាមផ្សេងៗ គឺខ្ញុំមានការមិនប្រុងប្រយ័ត្ន ហើយដែលឲ្យមានការរត់គេចខ្លួនផ្សេងៗរបស់សត្រូវ ហើយឲ្យគេឆក់អាវុធបានសម្លាប់ខ្លួនគេ ។ ហើយការវិភាគរបស់ខ្ញុំ និងការតាមដាន គឺខ្ញុំដូចជាមិនធ្វើការតាមដានឲ្យបានកៀកជាដរាប ហើយមិនក្លាហានក្នុងការតាមដានទៅលើសកម្មភាពរបស់ខ្មាំង ។ ខ្ញុំបន្តមើលស្រាលទៅលើសកម្មភាពរបស់ខ្មាំង ហើយខ្ញុំនៅខ្វះការបំពេញការងារភ្លាមៗមួយចំនួន ហើយខ្ញុំមិនក្លាហាននៅឡើយនៅក្នុងការអនុវត្តការងារ ។ ខ្ញុំមិនបានសិក្សាមេរៀនដែលទទួលបានពីការបំពេញការងារ ហើយខ្ញុំនៅតែមានភាពខ្វះខាត ការធ្វេសប្រហែស ហើយនៅពេលដែលថ្នាក់លើផ្ដល់សេចក្ដីណែនាំនោះ គឺខ្ញុំមិនមានភាពក្លាហានផ្សេងៗក្នុងការដឹកនាំមហាជន ។

[០៩:៤២:៣៤]

នៅពេលដែលខ្ញុំឃើញនៅការខ្វះរបស់ខ្ញុំនេះ ខ្ញុំសូមបញ្ជាក់អំពីសេចក្ដីសម្រេចរបស់ខ្ញុំ ដែលឆ្លុះបញ្ចាំងអំពីខ្លួនខ្ញុំផ្ទាល់ ដែលវាមិនមែនជាបុគ្គលិកលក្ខណៈបដិវត្តន៍ ហើយខ្ញុំនឹងព្យាយាមលាងខ្លួនឯង និងធ្វើការកសាងខ្លួនឯង ដើម្បីធ្វើការងារវណ្ណៈអធនបដិវត្តន៍ ។

លោក ហ៊ីម ហ៊ុយ តើលោកនៅស្គាល់និងចាំទៅលើប្រវត្តិរូបនេះដែរឬទេ? ថាវាជាប្រវត្តិរូបរបស់លោក ហើយអ្វីដែលលោកបានលើកឡើងនៅពេលនោះ គឺពិតដែរឬទេក្នុងវិធីដែលលោកបំពេញការងាររបស់លោក?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ប្រវត្តិរូបនៅក្នុងរបបខ្មែរក្រហមហ្នឹង ទោះបីយើងយ៉ាងម៉េចក៏ដោយក៏គេឲ្យដាក់តែរឿងខុសតែម្ដង ។ មិនធ្វើខុសក៏ជំរុញឲ្យយើងដាក់ថា ខុស ។ ធ្វើម៉េចគេចាក់តែពីក្រោយឲ្យតែលោតតាមគេរហូត ។ ខ្ញុំសូមអស់យោបល់ ។

**ស៖** នៅពេលដែលលោកអនុវត្តការងារនៅស-២១ លោកបានលើកឡើងថា នៅពេលដែលទៅដល់ដំបូង គឺលោកមានការភ័យខ្លាច ។ តើលោកមានបំណងចង់បំពេញការងារដែរឬទេ? ហើយថាតើលោកមានវិន័យត្រឹមត្រូវក្នុងការអនុវត្តការងារនោះដោយពេញលេញដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាប! ខ្ញុំទៅដល់ដំបូងហ្នឹង ឃើញគុកអ៊ីចឹង ខ្ញុំខ្លាចណាស់ ។ នៅយូរៗបានគេឲ្យយាមទៅ ចេះតែធ្វើតាមអ៊ីចឹងទៅ ដល់ថ្ងៃមួយ ដូចថា សុន សេន មកប្រជុំអ៊ីចឹង ។ ខ្ញុំឃើញគាត់មកប្រជុំកន្លែង តាឌុច ហៅពួកខ្ញុំទាំងពួកអ្នកនៅស្រែ ព្រៃសហ្នឹង ហៅមកប្រជុំ ដល់អ៊ីចឹងខ្ញុំលើកដៃសុំគាត់

ទៅទ័ពវិញ នៅកន្លែងនេះច្បាស់ជាងាប់ហើយ ព្រោះឃើញកន្លែងនេះកន្លែងគុកទៅហើយ ។ សុំ សុន សេន ទៅទ័ពវិញ គាត់អត់ឲ្យទៅ អស់ការជ្រើសកន្លែងហ្នឹង។ ហើយមួយទៀតខ្វល់ខ្វាយរហូត ដែលធ្វើការនៅកន្លែងហ្នឹង តាំងពី តាន្ទួន ឆ្លើយដាក់ តាំងពីចាប់កម្មាភិបាល ចាប់បុគ្គលិកធ្វើការហ្នឹង គឺអត់មានអារម្មណ៍មួយថា សប្បាយចិត្តកន្លែងណា ដេកលក់បានភ្លេច នៅដឹងខ្លួន គឺនៅតែភ័យខ្លួនរហូត ។

**ស៖** ថាតើលោកពេញចិត្តនិងស្រលាញ់ការងាររបស់លោកនៅស-២១ ដែរទេ?

[០៩:៤៥:១៩]

**ឆ៖** បាទ, ដូចខ្ញុំសូមជម្រាប! អម្បាញ់មិញអ៊ីចឹងថា ខ្ញុំអត់មានពេញចិត្តនឹងការងារនៅកន្លែងហ្នឹងទេ គឺខ្ញុំជ្រើសរើសលែងបានហើយការងារដែលខ្ញុំត្រូវចាកចេញពីទីនេះ ព្រោះសុំ សុន សេន មិនឲ្យចេញហើយ មានអីមានចាំដល់ថ្ងៃងាប់នៅកន្លែងហ្នឹង ។

**ស៖** ថាតើលោកមានអារម្មណ៍ចូលចិត្តខ្លាំងក្នុងការងាររបស់លោកដែរទេ? លោកធ្វើការងារហ្នឹងច្រើនជាងអ្វីដែលលោកចង់ធ្វើ ឬក៏លោកធ្វើត្រឹមតែអ្វីដែលលោកចង់ធ្វើតែប៉ុណ្ណោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! តាំងពីចាប់ពីអីបុគ្គលិកធ្វើការនៅកន្លែងហ្នឹងទៅ គឺម្នាក់ៗគេឲ្យតាមដានគ្នា យុទ្ធជនតាមដានកម្មាភិបាល កម្មាភិបាលតាមដានយុទ្ធជន ។ យុទ្ធជនប៊ានរាយការណ៍កម្មាភិបាលឲ្យគេចាប់ដាក់គុកបានទៀត ។ អ៊ីចឹងម្នាក់ៗត្រង់ភ្លឹងទាំងអស់ គ្មាននរណាមួយគេចពីមិនត្រង់ភ្លឹងទេ ។

**ស៖** នៅក្នុងប្រវត្តិរូបរបស់លោកបានលើកឡើងថា មានការរត់គេចខ្លួនរួចនៅស-២១ ថាតើការនៅពេលដែលមានការរត់គេចខ្លួននោះ តើលោកមាននៅទីនោះដែរឬទេ? មានឃើញទៅលើចំណុចហ្នឹងដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមបញ្ជាក់ម្តងទៀត គេចខ្លួនយ៉ាងម៉េច? ខ្ញុំសូមបញ្ជាក់ម្តងទៀត ។

**ស៖** ថាតើនៅពេលដែលលោកនៅស-២១ តើលោកមានឃើញអ្នកទោសរត់ចេញពីមន្ទីរនោះដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ខ្ញុំអត់បានឃើញទេ ខ្ញុំនៅតែក្រៅទេ ។ អ្នកយាមនៅខាងក្នុងធ្វើឲ្យរួចអ្នកទោស ។ ហ្នឹងខ្ញុំបានដឹងតាមគេប្រាប់ខ្ញុំ ។

**ស៖** ថាតើអ្នកទោសរត់រួចម្នាក់ ឬក៏រត់រួចច្រើនជាងម្នាក់?

**ឆ៖** បាទ ខ្ញុំដឹងថា រត់រួចម្នាក់ហ្នឹង ។

**សៈ** នៅក្នុងប្រវត្តិរូបរបស់លោក លោកបានលើកឡើងថា ខ្មាំងមួយបានចាប់យកអាវុធ ហើយបាញ់ខ្លួនឯងស្លាប់ ។ តើលោកបានដឹងព្រឹត្តិការណ៍នោះដែរឬទេ?

**ឆៈ** បាទ, ខ្ញុំបានដឹងព្រោះនៅក្រៅ គេមកហៅពួកខ្ញុំទៅ ព្រោះអ្នកទោសនោះ គឺនៅចំមុខអគារខ្លោងទ្វារចូលគុកទួលស្លែងហ្នឹង កន្លែងផ្ទះតាហ៊ី ហ្នឹង ។ មិនដឹងអ្នកណាសួរចម្លើយទេ ហើយអាវុធនៅកន្លែងហ្នឹង អ្នកទោសយកកាំភ្លើងបាន គឺបាញ់តែម្តងទៅ ដល់ហើយបានគេមកហៅពួកខ្ញុំ ប្រមូលពួកកងការពារមកនាំគ្នាព័ទ្ធកន្លែងអ្នកទោសបាញ់កាំភ្លើងហ្នឹង យកកាំភ្លើងបាញ់ហ្នឹង ។ ម្ល៉ោះហើយបានពួកកងការពារយកកាំភ្លើងមក ហើយនិងយកផេះអីទេ យកបាចចូលបានកងការពារបាញ់អ្នកទោសនោះបាន ។

**សៈ** ថាតើអ្នកទោសនោះបាញ់ខ្លួនឯង ឬក៏ឆ្មាំយាមបាញ់អ្នកទោស?

**ឆៈ** បាទ, ពេលដែលបាញ់ហ្នឹង មិនដឹងជាអ្នកណាបាញ់មុនអ្នកណាទេ ព្រោះគេបាញ់ពីចំហៀងខាងជើងមក ហើយអ្នកទោសកាន់កម្លាំងមួយដើមដែរ គ្រាប់មួយបង់ ។ កាលហ្នឹង គេបាញ់ចេញមកដែរ មិនដឹងអ្នកណាបាញ់អ្នកណា ប៉ុន្តែតាមស្មានរបស់ខ្ញុំ គឺអ្នកដែលកងការពារថា គេបាញ់ត្រូវ ថាកងការពារហ្នឹងបាញ់ត្រូវមុន ។

[០៩:៤៩:៣៩]

**សៈ** សូមអរគុណ ។ ពីមុនលោកបាននិយាយថា អ្នកយាមនៅស-២១ ត្រូវបានគេចាប់ខ្លួន ហើយបន្ទាប់មកលោកត្រូវបានគេដំឡើងថ្នាក់ឲ្យ ហើយចង់ឲ្យលោកយោបល់នៅលើបុរសម្នាក់ដែលគេឲ្យលោកចាប់ខ្លួននៅស-២១ គឺលេខនោះ ឯកសារនោះមាននៅក្នុងឯកសារលេខ D52200235765 លេខERN ខ្មែរ 00 ដល់លេខ 00235766 លេខERN ជាភាសាអង់គ្លេស គឺ00104993 រហូតដល់លេខ00104940 ។ ខ្ញុំចង់លើកលេខERN នៅក្នុងភាសាអង់គ្លេស 00104921 ដល់ 22 ហើយលោកបានលើកឡើងថា លោកបានផ្តល់សម្ភាសន៍ឲ្យលោកមួយនោះ គឺលោកបានលើកឡើងដូច្នេះថា នៅក្នុងភ្នំពេញ នៅទួលស្លែងគេបញ្ជាខ្ញុំឲ្យយកបុរសម្នាក់ទៅញាត់គុក ប៉ុន្តែខ្ញុំមិនធ្វើទេ ។ ខ្ញុំមានអារម្មណ៍ គាត់មានអារម្មណ៍ខ្លាំងមួយ បើសិនបើគាត់ចង់ធ្វើ គឺធ្វើ ហើយគាត់បើសិនជាគាត់ដេក គឺដេក ប្រសិនបើគាត់ថា ឈឺ គាត់ឈឺមែន ។ ហើយគឺដោយសារតែ គេចាប់នីរសារពីមុនៗ ហើយបុរសមួយនោះ គឺគាត់ព្យួរកខ្លួនឯង ហើយគេមិនទាន់ដាក់គុកគាត់នោះទេ ។ ហើយគាត់និយាយថា គាត់ទៅកាត់ស្មៅសម្រាប់ទន្សាយ ហើយប្រសិនបើលោកមកពីអាហារមិនទាន់ទេ គេហូបអាហារលោកទាំងអស់ ។ ហើយបន្ទាប់

មក គឺគាត់បានរឹតកខ្លួនឯង ។ ហើយគេហៀបនឹងញាត់គាត់ចូលគុកហើយ ប៉ុន្តែខ្ញុំប្រាប់ថា យកគាត់ទៅឲ្យគាត់លត់ដំខ្លួន ហើយបន្ទាប់មកគឺគាត់បាត់ខ្លួន ហើយលោកទៅរកមើលគាត់ឃើញគាត់ ចងកគាត់ស្លាប់ ។ ហើយលោកបានលើកឡើងថា លោកមិនដឹងទេចំពោះការងារនោះ លោកបាននិយាយជាមួយ ហ៊ិ នៅពេលដែលគេមកប្រាប់ខ្ញុំអំពីបញ្ហានេះ ខ្ញុំមានអារម្មណ៍រន្ធត់ ហើយខ្ញុំដឹងថា គេនឹងញាត់គុកខ្ញុំដោយសារតែខ្ញុំធានាទៅលើបញ្ហានោះ ។ ខ្ញុំរត់ទៅកន្លែងផ្សេង ហើយខ្ញុំប្រាប់ថា លោក ចឹក ហ្នឹងគឺគាត់បានចងកខ្លួនឯង ។ ហើយលោកទទួលខុសត្រូវទៅលើបញ្ហានេះ ហ៊ិ បាននិយាយដូច្នោះ គេប្រាប់ខ្ញុំឲ្យរាយការណ៍ទៅ ឌុច ខ្ញុំអត់ទៅទេ ហ៊ិ គឺជាអនុប្រធានបន្ទាប់ពី ឌុច ។ ខ្ញុំមិនប៊ានមើលមុខគាត់ទេ ។

[០៩:៥២:៤៨]

បន្ទាប់មកគេសួរលោក "ថាតើគេសម្លាប់លោកទេប្រសិនបើ លោកមើលមុខគាត់?" លោកឆ្លើយថា "អត់ទេ" ។ ហើយគឺខ្ញុំជាអ្នកប្រព្រឹត្តខុសនោះ ។ បងថ្លៃរបស់ខ្ញុំក៏ជាប់គុកនៅទួលស្លែងដែរ ។ ខ្ញុំចង់សួរថា ថាតើការឆ្លើយនោះត្រឹមត្រូវដែរឬទេ គេបញ្ជាលោកឲ្យចាប់បុគ្គលម្នាក់ ហើយបន្ទាប់មកលោកជំរុញឲ្យគេធ្វើ ក៏ឲ្យគេយកគាត់ទៅលត់ដំជាជាងដាក់គាត់ញាត់គុក តើត្រឹមត្រូវដែរឬទេអ្វីដែលលោកនិយាយនោះ?

**ឆ៖** បាទ ខ្ញុំសូមជម្រាប ។ បង ចឹក ហ្នឹងនៅកូនក្រុមជាមួយខ្ញុំ ។ ពេលតា ហ៊ិ ប្រាប់ថា ចឹក ហ្នឹងដកចេញហើយ "អ្អែងដក ចឹក ចេញឲ្យទៅស្រែ" ។ ខ្ញុំថា "បងកុំអាលដកគាត់អីបើខ្ញុំមិនទាន់បានកសាងគាត់ផង ចាំខ្ញុំកសាងគាត់សិន បើគាត់មិនកែទេចាំយកគាត់ទៅ" ។ "អ្អី អ្អែងកសាងណ៎ា ទទួលខុសត្រូវ" ។ ថា "បាទ" ។ ដល់រំលងបានមួយយប់ស្អែកឡើង សុំខ្ញុំទៅរកស្មៅយកមកឲ្យ រកស្មៅ រកត្រកួនយកមកឲ្យទន្សាយស៊ី ទៅរហូតៗទល់ម៉ោងមួយ ពួកខ្ញុំហៅបាយ អ្អីចុះបាត់អីយូរម្ល៉េះ! ឆ្ងល់ៗគ្រប់គ្នាដើររកតិចខ្យល់ចាប់អីទៅ ។ រកចុះរកឡើងរកអត់ឃើញ ដល់ពេលទៅរកឃើញៗនៅក្នុងផ្ទះអាផ្ទះនៅក្នុងអូរ ដាក់កៅអីមួយឡើងចងកខ្លួនឯងសម្លាប់ខ្លួនតែម្តងទៅ ។ ដល់ហើយនាំគ្នារកៗមិនឃើញដល់ពេលនេះម្នាក់រកឃើញរត់មកប្រាប់ខ្ញុំ ខ្ញុំក៏រត់ទៅប្រាប់តាហ៊ិ ខ្ញុំថា បងៗ ខ្ញុំចាប់ផ្តើមភ័យខ្លួនឯងហើយ "បងៗ បងចឹក ចងក" ។ "អ្អីបើ ចឹក ចងកឥឡូវគិតម៉េច? ព្រោះអញបានប្រាប់អ្អែងហើយថាឲ្យដកវាទៅស្រែ" ។ ខ្ញុំថា "អ្អីអត់ដឹងគាត់អីចឹងទេបងអើយ" ។ "អីចឹងអ្អែងចូលគុកខ្លួនឯងទៅ" ។ ខ្ញុំថា "អ្អីមិនដឹងធ្វើម៉េចទេបើគាត់អីចឹង ខ្ញុំមិនដឹងគាត់អីចឹងផង" ។ ហើយខ្ញុំក៏ដើរមកកន្លែងវិញ ។ ហើយតាហ៊ិ ប្រាប់ខ្ញុំថា "អ្អែងទៅរាយការណ៍ទៅបង ឌុច ខ្លួនឯងទៅ" ។ ខ្ញុំថា "អត់ប៊ានទៅទេបង" ។ សុំ

អស់ប៉ុណ្ណឹង ។

[០៩:៥៥:៣៩]

**ស៖** ហេតុអ្វីបានជាលោកខ្លាចមិនហ៊ានរាយការណ៍ទៅជូន ឌុច?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា រឿងនេះវាពាក់ព័ន្ធស្មុគស្មាញមកដល់ខ្លួនខ្ញុំ ព្រោះគាត់អ្នកធំឲ្យដកដកយកទៅ ។ ហើយខ្ញុំសុំគាត់នឹកឃើញអាណិត កុំឲ្យទៅស្រែអី តែទៅស្រែបកមកវិញ គឺងាប់ហើយ ។ បានខ្ញុំចេះអង្វរតាហ៊ី សុំ តាហ៊ីទុក ។ ហើយដល់ហើយគ្រោះថ្នាក់អ៊ីចឹងទៅ ខ្ញុំវិលវល់ចិត្តខ្លួនឯងថា ខ្ញុំទទួលគ្រោះថ្នាក់ទៀតបន្តពីគេហើយ ចេះតែព្រួយបារម្ភរហូតស្មុគស្មាញវាច្រើនរឿងហើយ ។

**ស៖** នៅក្នុងចម្លើយដែលលោកឆ្លើយនោះដែរគឺ D55/22 ខ្ញុំលើកឡើងលេខERN ជាភាសាអង់គ្លេស 00104923 រហូតដល់លេខហ្នឹងដដែល គឺលោកគេសួរលោកអំពីការចាប់ខ្លួន និងការសម្លាប់នៅស-២១ ។ ហើយលោក ភីធ័រ ម៉ាខ្វាយ បានសួរលោកថា នៅពេលដែលមេបានដំឡើងឲ្យហើយគេឲ្យសម្លាប់ចោលនោះ គឺខ្ញុំមានការភ័យខ្លាចណាស់ ។ លោកបាននិយាយថា “ខ្ញុំក៏បានគិតអំពីបញ្ហានេះដែរ ។ ខ្ញុំភ័យខ្លាចថា ខ្ញុំនឹងប្រឈមបញ្ហានេះដូចគ្នា ដោយសារតែអ្នកដែលនៅធំខាងយោធានោះគឺត្រូវបានគេដំឡើងហើយបន្ទាប់មកជាប់គុក ។ ហើយដូចគ្នាដែរអ្នកទួលស្លែង នៅពេលដែលគេដំឡើងឋានៈឲ្យពួកគេនោះ ពួកគេជាប់គុក ។ ខ្ញុំគិតបញ្ហានេះរហូតដល់ថ្ងៃរំដោះ ។ រាល់ថ្ងៃខ្ញុំចាំបញ្ហានេះ ដូចមិត្តរបស់ខ្ញុំមួយដែលត្រូវបានគេជ្រើសរើសមកពីជួរយោធា ហើយគាត់ស្នើសុំឲ្យរៀបការ គាត់មានប្រពន្ធហើយគាត់ស្នើឲ្យខ្ញុំហ្នឹងសុំអ៊ីចឹងដែរ ប៉ុន្តែខ្ញុំនិយាយថា ខ្ញុំមិនចង់ទេ ។ បន្ទាប់មកនៅទួលស្លែង គឺគាត់ជាប់នៅទួលស្លែងនៅឆ្នាំ១៩៧៨ ។ មេប្រធានឌុចនោះឲ្យខ្ញុំរៀបការ ប៉ុន្តែខ្ញុំនិយាយថា ខ្ញុំមិនចង់រៀបការទេ ដោយសារតែកម្មាភិបាលនៅទីនោះគេស្លាប់ និងត្រូវយកទៅសម្លាប់ចោលប្រសិនបើមានប្រពន្ធដែរ ប្រសិនបើខ្ញុំការនោះប្រពន្ធនិងប្តី គឺនឹងធ្វើកំហុសរួមគ្នា ។ ចំណុចនេះហើយដែលធ្វើឲ្យយើងស្លាប់ងាយៗប្រសិនបើប្រពន្ធ ឬប្តី មានកំហុសគេសម្លាប់ទាំងពីរ ។ គេសួរលោកថា នៅពេលណាដែលគេនិយាយថា លោកមិនចង់រៀបការនោះ ថាតើនិយាយយ៉ាងម៉េច? គេមិននិយាយអ្វីទាំងអស់ ។ អ៊ីចឹងបានន័យថា គាត់មិនសាហាវទេ ។ អត់ទេ គឺគាត់នឹងធ្វើអ្វីទៅតាមដែលគាត់ចង់ធ្វើ ។ គេចង់នាំខ្ញុំមកវិញជាច្រើនដង ហើយប្រហែលជាគេចង់សាកល្បងខ្ញុំ ។

ហើយមានបុរសម្នាក់ទៀត គាត់ស្នើចង់ការ។ ដូច្នេះសមមិត្ត ហ៊ុយ ក៏ការដែរនៅពេលនោះ” ។ លោកមិនខ្លាចក្នុងនិយាយអត់ទេនោះទេ លោកគិតថា ប្រសិនបើលោកការនោះ លោកនឹងងាប់ នឹងស្លាប់

លឿនបំផុត ។ ខ្ញុំចង់សួរថា តើលោកមាននិយាយដូច្នេះជាមួយ ឌុច ដែរឬទេ? ហើយ ឌុច មានប្រាប់លោកឲ្យលោករៀបការដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ថ្ងៃមួយដែលរៀបចំកម្មាភិបាលជាគ្រួសារហ្នឹង ពេលដែលហូបបាយហូបអីហ្នឹង ខ្ញុំទៅក្រោយគេខ្ញុំបានហូបបាយជាមួយគេដែរ ដល់ហើយ តាឌុច គាត់សួរថា "មិត្តហ៊ុយឯង ចង់បានគ្រួសារនឹងគេដែរឬអត់?" ខ្ញុំថា "អ្ហឺ!អត់ចង់បានទេបង ដឹងយកមកធ្វើអីផង" ។ ពេលហ្នឹងហើយដែលធ្វើឲ្យខ្ញុំនឹកឃើញ គេគ្រប់គ្នាដែលជាប់គុក ហើយការរៀនសូត្រចាប់ទាំងខ្សែ ។ ហ្នឹងហើយដែលខ្ញុំមិនអាចយកប្រពន្ធបាន សុខចិត្តនៅរហូត ។ អ្នកដែលយកប្រពន្ធ ខ្ញុំថាជាទ្រូក្បាលពីរហើយ ។ ខាង-- បើយើងយកប្រពន្ធ គឺជាប្រពន្ធរបស់យើង បើប្រពន្ធយើងជាប់គុក យើងក៏ត្រូវតែជាប់គុកដែរ ។ ហើយវាលឿនបំផុតនឹងការជាប់គុកស្លាប់ អ៊ីចឹងខ្ញុំអត់យកទេ អ្នកណាយកប្រពន្ធ គឺអ្នកហ្នឹងមានគ្រោះថ្នាក់ហើយ ។ អ៊ីចឹង ខ្ញុំថាអត់ចង់បានទេ ពិតមែនអ្នកដែលយកប្រពន្ធប៉ុន្មាន គឺជាប់គុកស្លាប់ទាំងអស់ ។ គេចាប់ទាំងខ្សែ ខ្សែខាងប្រពន្ធ គឺត្រូវតែជាប់គុក ខ្សែខាងប្ដីក៏ត្រូវតែជាប់គុក អ៊ីចឹងគឺឆាប់លឿនបំផុតហើយ ។

**សៈ** ដូច្នេះ តើលោកមានការព្រួយបារម្ភពីការរៀបការ គឺថាអាចនឹងប្រពន្ធឆ្លើយដាក់ ឬក៏ការព្រួយបារម្ភរបស់លោក គឺថាប្រពន្ធរបស់លោកត្រូវនឹងគេចោទដាក់ថា មានការពាក់ព័ន្ធនឹងលោក ឬក៏លោកព្រួយបារម្ភថា ការរៀបការហើយទៅ គឺថាទាំងពីរនាក់អាចនឹងគេឆ្លើយដាក់ងាយជាងម្នាក់ឯង ហើយគេនឹងចាប់បន្ទាប់ពីនោះ ឬយ៉ាងម៉េច?

[១០:០១:០៦]

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ជំនាន់ហ្នឹង នៅក្នុងរបបហ្នឹង គឺអ្នកណាយកប្រពន្ធវាកាន់តែលឿនទៅទៀត ព្រោះខ្សែ ។ គេចាប់ខ្មាំងចាប់ជាខ្សែ បើយើងយកប្រពន្ធក៏ជាខ្សែរបស់យើងដែរ ។ ប្រពន្ធខ្សែខាងប្រពន្ធ ដូចថា ឆ្លើយមកបើប៉ះប្រពន្ធ អ៊ីចឹងគេ អាប្ដីអត់ទាន់មានជាស្អីជាមួយប្រពន្ធផង ក៏ត្រូវជាខ្សែរបស់ប្រពន្ធហ្នឹង ជាប់ជាមួយគ្នាទៀត អ៊ីចឹងអាហ្នឹងហើយគេចាប់ជាខ្សែ ។ អ៊ីចឹងបានខ្ញុំអត់យកទេ ថាខ្ញុំអត់ចង់បានមិនដឹងយកធ្វើអី ។

**សៈ** សូមអរគុណ ។ ហើយលោកបានផ្ដល់សក្ខីកម្មថា លោកបានទទួលបញ្ជាផ្ទាល់ពីឌុច ខ្ញុំដកស្រង់នៅក្នុងប្រតិចារឹកនៅថ្ងៃ២៤ នៅពេលចៅក្រមសួរសំណួរ "តើលោកធ្លាប់បានទទួលបញ្ជាផ្ទាល់ពីឌុច ដែរទេ?" លោកបានឆ្លើយថា "ខ្ញុំក៏បានបានទទួលបញ្ជាផ្ទាល់ពីគាត់" ។ ហើយគាត់បន្តទៀតថា ក្នុង

កាលៈទេសៈខ្លះថៅក្រមសួរថា "នៅក្នុងកាលៈទេសៈណា សូមលោកពន្យល់បន្ថែមនៅពេលដែលលោកទទួលបញ្ជាផ្ទាល់ពី ឌុច នោះ?" លោកបានឆ្លើយថា "ពេលខ្លះការបញ្ជាឲ្យទៅស្វាយរៀង ដើម្បីដឹកជញ្ជូនទ័ពវៀតណាម ឬក៏ហើយឲ្យចាប់មនុស្សខ្លះ គឺជាបញ្ជាផ្ទាល់ពីគាត់" ។ សំណួររបស់ខ្ញុំទៅលោកហ្នឹងគឺថា ក្នុងឱកាសមួយនៅពេលដែលលោកនិយាយទៅ ឌុច ផ្ទាល់ តើ ឌុច និយាយផ្ទាល់ទៅឲ្យលោកធ្វើអ្វី? ហើយតើមានកាលៈទេសៈណាក្រៅពីហ្នឹង គឺថាតើគាត់បានបញ្ជាឲ្យលោកផ្ទាល់ធ្វើអំពើអ្វីមួយ ឬធ្វើការអ្វីមួយនៅក្នុងស-២១ ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ដូចទៅស្វាយរៀង គឺទទួលបញ្ជាពីគាត់ឲ្យខ្ញុំទៅ ទៅយកអ្នកទោសវៀតណាម ដែលគេចាប់បាននៅខាងខេត្តស្វាយរៀងហ្នឹង ខ្ញុំក៏នាំកម្លាំងរបស់ខ្ញុំទៅៗយក ។ សុំអស់ ។

**ស៖** នៅក្នុងពេលដែលលោកធ្វើការនៅស-២១ តើលោកបានជួប ឌុច ញឹកញាប់ប៉ុនណា? ថាតើលោកបានធ្វើដំណើរអមជាមួយនឹងគាត់នឹងញឹកញាប់ប៉ុនណា? ទៅកន្លែងណាខ្លះ?

**ឆ៖** ខ្ញុំដែលបានទៅជាមួយគាត់ គឺចាប់អ្នកទោសនៅផ្ទះគាត់ហ្នឹងតែម្តង ចាប់ តាប៉ង់ ហ្នឹង ។

**ស៖** លោកបានបញ្ជាក់ថា លោកបានចូលរួមក្នុងវគ្គសិក្សា ពីដំបូងរៀនជាមួយ ហ៊ី បន្ទាប់មករៀនជាមួយ ឌុច នៅក្នុងវគ្គសិក្សា ថាតើលោកបានចូលរួមវគ្គសិក្សាជាមួយ ឌុច ហ្នឹង ញឹកញាប់ប៉ុនណានៅស-២១ នោះ?

[១០:០៤:៣៨]

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ពេលដែលបើកវគ្គសិក្សាតាឌុច ហើយតាហ៊ី បងហ៊ុយ គឺក្នុងមួយអាទិត្រម្តង ឬមួយក៏មួយខែ ឬកន្លះខែម្តង គឺហៅតាំងពីព្រៃសយកមកឲ្យរៀនសូត្រជាមួយគ្នានៅកន្លែងគាត់ធ្វើសាលាមួយនៅក្បែរផ្ទះគាត់ ខាងត្បូងផ្ទះគាត់ហ្នឹងឲ្យរៀនសូត្រទាំងអស់គ្នា ។ ជួនកាលមួយអាទិត្យម្តង គឺតែពួកសួរចម្លើយ ហើយនិងពួកការពារ រៀនដោយឡែកពីគេ ។

**ស៖** អ៊ីចឹងយើងអាច ការយល់ជារួមទៅទាក់ទងការស្គាល់ ឌុច នៅស-២១ តើរយៈពេលមួយឆ្នាំកន្លះ ដែលលោកនៅធ្វើការនៅទីនោះ តើលោកបានជួប ឌុច ប៉ុន្មានដង ឬក៏ប៉ុន្មានដងដែលលោកធ្លាប់ធ្វើដំណើរជាមួយគាត់ទៅកន្លែងណា ឬក៏មានឱកាស មានប៉ុន្មានដង មួយដង ប្រាំដង ឬម្ភៃដង ឬក៏លើសពីហ្នឹង?

**ឆ៖** បាទ, គឺពីរដង ចាប់នៅកន្លែងផ្ទះគាត់ម្តង ហើយទៅពេលយប់ ហើយនៅត្រង់ណា ម៉ុំផ្សារថ្មីអីហ្នឹង ម្តងហ្នឹង គឺចេញពីចាប់ពីរដងផ្ទាល់ជាគាត់ ហើយក្រៅពីហ្នឹង គឺទៅជាមួយ តាហ៊ី ។ ថាតើ

ចាប់ណា ចាប់ណាៗ ទៅទទួលឯណា គឺទៅជាមួយ តាហ៊ិ ។

**ស៖** នៅស-២១ ក្នុងចំណោមអ្នករួមការងារ ហើយនិងបុគ្គលិកផ្សេងទៀត តើការដឹងអំពីអត្តចារិក ឬក៏កេរ្តិ៍ឈ្មោះរបស់ ឌុច ហ្នឹង លោកអាចយល់បានដូចម្ដេចដែរនៅពេលនោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! អប្បកិរិយារបស់គាត់ គឺសម្ដីសំដៅរបស់គាត់ ទន់ភ្លន់ណាស់ និយាយសឹងតែមិនឮផង ។ ប៉ុន្តែ ការងារនៅកន្លែងគាត់គឺច្បាស់លាស់បំផុត បានជាខ្ញុំថាច្បាស់លាស់ អ្នកទោសដែលចាប់យកមកហើយ គឺច្បាប់តឹងតែងរបស់គាត់ហើយ អ្នកធ្វើការបុគ្គលិកនៅកន្លែងហ្នឹង គឺគាត់សម្រេចចាប់ខ្លួនទាំងអស់ ។ គ្មានអ្នកណាប៉ានសម្រេចចាប់ខ្លួនទេ មានតែគាត់ អ៊ីចឹងពួកខ្ញុំឃើញអ៊ីចឹង គឺមិនសូវប៉ានមើលគាត់ទេ គ្រាន់តែឮសូរម៉ូតូគាត់ជិះមក ក៏គេចដែរ ។

**ស៖** នៅថ្ងៃព្រហស្បត្តិ៍អាទិត្យមុន ចៅក្រម ឡាវែន៍ បានសួរលោកឲ្យបញ្ជាក់ថា តើលោកស្គាល់ជនជាប់ចោទដែរឬទេ? នៅថ្ងៃនោះ ហើយលោកបានបញ្ជាក់ថា លោកស្គាល់គាត់ ហើយចៅក្រមសួរលោកថា គាត់ជាអ្នកណា? លោកឆ្លើយថា “គាត់ជាមេរបស់ខ្ញុំ” ។ តើលោកនៅតែមានការភ័យខ្លាច ឌុច ទេពេលនេះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោកត្រង់ៗ តែឃើញគាត់ នឹកឃើញកាលខ្ញុំ ពួកខ្ញុំនៅជាមួយគាត់ ខ្ញុំខ្លាចណាស់ ។ សូម្បីថ្ងៃមុន ក៏ខ្ញុំមិនប៉ានមើលគាត់ផង ថ្ងៃនេះក៏ខ្ញុំមិនមើលដែរ ព្រោះខ្ញុំមិនសងសឹកអីជាមួយគាត់ទេ ឃើញខ្លាចគាត់តែម្ដង ។ កុំតែបែក៧មករា ខ្ញុំក៏ងាប់ដែរ ។ ខ្ញុំមិនស្មានថា ខ្លួនខ្ញុំរស់ទេ ព្រោះ ឌុច និយាយថា “សម្លាប់ទាំងអស់ៗ” ខ្ញុំបានរស់ទាំងអស់ ។ *(សំឡេងយំ)*

[១០:០៩:០០]

**ស៖** ខ្ញុំនៅសល់សំណួរតែពីរ ឬបីទេ ទាក់ទងទៅនឹងការងារចាប់ខ្លួន ហើយនិងការងារប្រមូលអ្នកទោស ហើយនិងការទៅយកអ្នកទោសនៅក្រៅភ្នំពេញ ។

តើលោកសាក្សីអាចនឹងឆ្លើយសំណួរតទៀតបានទេ ឬក៏លោកត្រូវការសម្រាក?

លោក ហ៊ឹម ហ៊ុយ តើលោកអាចបន្តឆ្លើយសំណួរបាន ឬក៏លោកត្រូវការសម្រាក?

**ឆ៖** បាទ, ខ្ញុំសុំបន្តទៀត ។

**ស៖** លោកបានបញ្ជាក់ថា កងរបស់លោកបានធ្វើការចាប់ខ្លួននៅស្វាយរៀង គឺបានទៅពីរដងនៅស្វាយរៀង បានទៅបាត់ដំបង ហើយបានទៅកំពង់សោម ទៅទទួលអ្នកទោស ហើយយកមក ស-២១ ។ នៅក្នុងនោះ គឺការងារប្រាំលើក តើមានការងារគេបញ្ជូនក្រៅពីហ្នឹងទៀតដែរឬទេ នៅពេលដែល

លោកធ្វើការនៅស-២១? តើអង្គភាពរបស់លោក ដែលគេបញ្ជូនឲ្យទៅយកអ្នកទោសនៅក្រៅភ្នំពេញ ហ្នឹងមាន ឬក៏គ្រាន់តែមានប្រាំដងហ្នឹង ឬក៏ច្រើនជាងហ្នឹង? បើសិនជាលោកនៅចាំ ថាតើប៉ុន្មានដង លើសពីហ្នឹងទៀត?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! មិនមែនតែប្រាំដងហ្នឹងទេ គឺច្រើនដង ដែលពួកខ្ញុំទៅជាមួយតាហ៊ ជាមួយ តាហ៊ ជាមួយផល ជាមួយ ប៉េង ហ្នឹង គឺច្រើនដង ។

**ស៖** ខ្ញុំគិតថា លោកមិនទៅគ្រប់តែពេលទាំងអស់ដែលគេបញ្ជាឲ្យទៅទេ ប៉ុន្តែ ភាគច្រើនលោក នៅធ្វើការនៅភ្នំពេញ នៅចាំទទួល តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ, អ៊ីចឹងមែន ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ គឺថាតាមការចងចាំរបស់លោក តើលោកនៅចាំចំនួនទេ តើការ ងារដែលចុះទៅធ្វើការហ្នឹង លោកប៉ុន្មានដងដែលថា អង្គភាពរបស់លោកដែលធ្វើការ បានន័យថាទៅ ភូមិភាគ ទៅភូមិភាគដើម្បីទៅយកអ្នកទោស យកមកភ្នំពេញហ្នឹង តើមានប៉ុន្មានដង តើលោកគិតមើល ថាប៉ុន្មានដងជាសរុប?

**ឆ៖** បាទ, ខ្ញុំអត់ដឹងថា មានប៉ុន្មានដងទេ ព្រោះខ្ញុំអត់មានកត់ទុកទេ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ខ្ញុំមិនមានសំណួរអ្វីទៀតទេ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តនេះ សូមប្រគល់វេទិកាទៅមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីអាចមានឱកាស ក្នុងការសួរដល់សាក្សីរូបនេះ ប្រសិនបើមាន ។ សូមអញ្ជើញមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុម មួយ លោកមានឱកាសម្តែនាទី ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំនឹងចែករំលែកមេធាវីជាតិ ទី ស្រ៊ីនណា ។ ខ្ញុំសូមជម្រាបសួរ លោកសាក្សី ខ្ញុំឈ្មោះ លោក អាឡាំង វ៉ែនណឺ ខ្ញុំតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីជាមួយមេធាវី ទី ស្រ៊ីនណា ។

**ស៖** ខ្ញុំនៅមានសំណួរមួយចំនួន ប៉ុន្តែខ្ញុំនឹងអាចនូវចម្លើយរបស់លោកមួយចំនួនដែលលោកបាន ឆ្លើយទៅមនុស្សចំនួនពីមុន ហើយខ្ញុំសួរឲ្យលោកបញ្ជាក់ថា តើលោកបានបញ្ជាក់នោះដែរឬទេ ហើយថា

តើការបញ្ជាក់នោះត្រឹមត្រូវ ឬមិនត្រឹមត្រូវ ខ្ញុំនឹងចាប់ផ្ដើមជាមួយនៅក្នុងកងពល៧០៣ ហើយ ហ៊ី បាននិយាយថា-- ពីថ្ងៃព្រហស្បតិ៍ លោកបាននិយាយបន្តិចអំពីជនជាប់ចោទ ដែលថាចាប់ផ្ដើមធ្វើការចាប់ខ្លួនមនុស្សដែលមកពីកងពល៧០៣ ហើយនៅក្នុងប្រតិចារឹកនោះ យើងមើលឃើញថា លោកបាននិយាយថា បន្ថែមលើសហ្នឹងទៀត ខ្ញុំនឹងបញ្ជាក់ក្នុងបទសម្ភាសន៍លោកលោកបានឆ្លើយនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៩៦ ហើយក្នុងអត្ថបទអង់គ្លេស ក្នុងERNនោះ គឺចំណុចដែលខ្ញុំនឹងដកស្រង់នោះ គឺ00104944 ។ ហើយនេះគឺជាចំណុចដែលលោកបាននិយាយនោះ គឺថា ថាតើលោកបាននិយាយអ៊ីចឹងមែនឬអត់?

ហ៊ី បានមកពីខេត្តកណ្ដាល មកពីភូមិភាគនិរតី ហើយគាត់គឺជាប្រធានកងវរៈ៧០៣ ដែលមានមេបញ្ជាការមួយចំនួនត្រូវបានចាប់ខ្លួនបញ្ជូនមក ស-២១ ដោយសារ ហ៊ី មានការពាក់ព័ន្ធទៅនឹងវរៈ៧០៣ ឌុច មិនមានទុកចិត្តលើគាត់ទៀតទេ ។ ហើយនៅក្នុងឆ្នាំ១៩៧៨ ហើយបានចាប់ផ្ដើមធ្វើការស៊ើបអង្កេតទៅលើ ហ៊ី ។ ហ៊ុយ បានរកឃើញថា គឺពេលដែលគេសួរអ្នកទោសមកពីវរៈ៧០៣នោះ គឺគេបានប្រាប់ ហ៊ី ថា “គាត់នោះបាននៅក្នុងបញ្ជីអ្នកទោស” តើលោកអាចបានបញ្ជាក់ទេ នៅពេលដែលនោះថាតើសេចក្ដីថ្លែងការណ៍ដែលលោកបញ្ជាក់ហ្នឹងត្រឹមត្រូវតាមការពិតដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ខ្ញុំខ្វល់ខ្វាយណាស់នៅកន្លែងហ្នឹង។ ៧០៣ចាប់ខ្លួនច្រើនណាស់យកមកដាក់គុកស-២១ ។ ៧០៣នៅ ស-២១ ក៏ច្រើន អ៊ីចឹង៧០៣ ឆ្លើយដាក់អ្នកនៅស-២១ ហើយដូច តាប៉ាង ចាប់មក ។ ខ្ញុំលួចសួរ តាប៉ាង កុំឲ្យយុទ្ធជនខ្ញុំដឹង លាក់ ។ សួរ តាប៉ាង ថា តាឯងមកកន្លែងនេះ តាឯងឆ្លើយដាក់អ្នកណាគេ ។ គាត់ប្រាប់ខ្ញុំថា អញឆ្លើយដាក់ អាហ៊ី ។ រឿងហ្នឹងហើយ ដែលឲ្យខ្ញុំកាន់តែភ័យទៅៗ ដល់ពេលហើយខ្ញុំបណ្ដើរគាត់យកទៅឲ្យគេ ។ ខ្ញុំក៏រូតមកប្រាប់ តាហ៊ី “បងៗ បងឯងប្រយ័ត្នខ្លួន ឥឡូវតាប៉ាងគេចាប់យកមកហើយ គាត់ឆ្លើយដាក់បងឯងហើយ”។ នឹកឃើញថា បើកាលណាមិនប្រាប់ តាហ៊ី ពេលដែល តាប៉ាង ឆ្លើយដាក់ ត្រូវចាប់ខ្លួន តាហ៊ី ទៀត ហើយពួកខ្ញុំអីប៉ុន្មានក៏តាឌុច ត្រូវចាប់ខ្លួនអស់ ។ អ៊ីចឹងបានឲ្យគាត់ដឹងខ្លួន ដើម្បីឲ្យគាត់ត្រិះរិះពិចារណា តើយើងត្រូវធ្វើយ៉ាងម៉េចទៀត ដើម្បីឲ្យរួចខ្លួនយើងទាំងអស់គ្នា ។ គាត់ក៏លែងមាត់ លែងក៏ជាមួយខ្ញុំ ខ្ញុំក៏មិនដឹងធ្វើម៉េច ខ្ញុំទៅកន្លែងផ្ទះខ្ញុំទៅ ។

[១១:១៧:០៥]

**ស៖** បន្ទាប់មក លោកបានបញ្ជាក់ថែមទៀត ឃើញនៅក្នុងការបទសម្ភាសន៍ដូចគ្នារបស់សហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៨ លេខERN លេខ00161598 សំណួរសួរថា

តើហ៊ីនៅរស់ដែរឬទេ? លោកបានឆ្លើយថា "ហ៊ី ហើយនិង ឌុច នៅក្នុងឆ្នាំ១៩៧៩ បានរត់គេចខ្លួនជាមួយគ្នាពេលដែលវៀតណាមមកដល់ ហើយ ប្រាក់ ខន ថានិយាយថា ឌុច បានសម្លាប់ហ៊ី ហើយ" ខ្ញុំមិនបានចាំច្បាស់ទេថាតើ ប្រាក់ ខន ឬក៏អ្នកណាទេ ដែលយើងបានជួបគ្នានៅពេលដែលថតភាពយន្ត ឬទ្វី ប៉ាន់ នោះ ។ តើ ប្រាក់ ខន ជាអ្នកប្រាប់លោកថា ជនចោទនៅពេលដែលរត់គេចខ្លួនទៅក្នុង៧៩នោះបានសម្លាប់ ហ៊ី ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបលោក! តាហ៊ីហ្នឹង ពេលរត់ចូលព្រៃ ក៏ខ្ញុំបបួលមកវិញដែរ ខ្ញុំថា "បងកុំនៅខំធ្វើបដិវត្តន៍ជាមួយគេ បើយើងធ្វើបដិវត្តន៍ជាមួយគេ ច្បាំងឈ្នះ គេនឹងសម្លាប់យើងដូចមុនទៀត" គាត់ថា អញមិនទៅទេ វាមិនមែនធ្វើបដិវត្តន៍ម្នាក់វាទេ ។ ខ្ញុំថា អ៊ីចឹងខ្ញុំអត់ដឹងទេ ខ្ញុំក៏ចេញពីគាត់ ចេញគាត់ ខ្ញុំក៏នាំកម្លាំងទាំងនារី ដែលនៅព្រៃស ព្រៃអី ដែលប្រមូលរត់ទៅហ្នឹង នាំនារី ហើយយុទ្ធជនរបស់ខ្ញុំគ្នាប៉ុន្មាននាក់ ជាច្រើន ប្រហែលជាពីរបីក្រុម នាំកម្លាំងហ្នឹងរត់មកបណ្ដោយ ។ ដល់អាពេលបែកក្រោយ១៩៧៩ហ្នឹង ពេលដែលខ្ញុំធ្វើការថតភាពយន្ត បានជួបជាមួយបង ខន បងខនប្រាប់ខ្ញុំថា "តាហ៊ី តាឌុច បានសម្លាប់ចោលនៅព្រៃហើយ" ។ ខ្ញុំថាឃើញទេ ហ្នឹងហើយបបួលមកមិនមក នៅខំធ្វើជាមួយគេ ឲ្យគេសម្លាប់បាន ។

[១១:១៩:២០]

**ស៖** សូមអរគុណ ។ លោកបានបញ្ជាក់ចំណុចមួយទៀត ទាក់ទងអំពីទារុណកម្ម តើលោកបានចូលរួមនៅក្នុងការ លោកបានចូលទៅក្នុងពិនិត្យឡើងវិញ ឬក៏សម្តែងឡើងវិញនៅក្នុងស-២១ ហើយដែលមានសហព្រះរាជអាជ្ញា មានមេធាវីការពារ ហើយមានសហចៅក្រមស៊ើបអង្កេត នេះជាសម្តីដែលលោកបាននិយាយ ហើយយើងអាចរកឃើញនៅក្នុងលេខ ERN00198004 ហើយនៅក្នុងការសម្តែងឡើងវិញហ្នឹង នៅក្នុងថ្ងៃទី២៧ ខែ០២ ឆ្នាំ២០០៨ អ្វីដែលយើងកត់ត្រានោះគឺថាសាក្សី ហ៊ឹម ហ៊ុយ បានទទួលស្គាល់ថាខ្លួនគាត់បានចូលរួមនៅក្នុងការសួរចម្លើយ ហើយនិងធ្វើទារុណកម្ម ។ ហើយគាត់បន្ថែមថា តាមធម្មតា គាត់មិនត្រូវចូលរួមក្នុងការ សួរចម្លើយទេ គឺគ្រាន់តែយាមនៅខាងបរិវេណខាងក្រៅប៉ុណ្ណោះ។ គាត់និយាយថា គាត់បានភ្លេចរឿងនេះអស់ទៅហើយ តែគាត់នៅតែទទួលស្គាល់ដដែល ។ តើលោកពិតជាបាននិយាយអ៊ីចឹងទេ ពេលដែល ទៅសម្តែងឡើងវិញនៅទួលស្លែងនោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ខ្ញុំគេឲ្យខ្ញុំទៅសួរចម្លើយ ដល់ហើយខ្ញុំថា ខ្ញុំអត់ចេះអក្សរផងហ្នឹងសួរម៉េចអីម៉េចទេ? ឲ្យខ្ញុំទៅសួរចម្លើយសួរម៉េចចេញទៅ? អ៊ីចឹងគេក៏អត់ឲ្យខ្ញុំទៅសួរចម្លើយ គេឲ្យខ្ញុំ

នៅជាអ្នកយាមវិញ ។ អាហ្នឹងគឺខ្ញុំនិយាយពិតមែនអ៊ីចឹង ។ ត្រង់ថា ទៅសួរចម្លើយ ខ្ញុំមិនដែលទៅសួរចម្លើយទេខ្ញុំ ។

**ស៖** អ៊ីចឹងអ្វីដែលលោកបានបញ្ជាក់នូវដែលខ្ញុំអានអំមិញនោះគឺមិនត្រូវទេ តើអ៊ីចឹងមែនឬទេ?

**ឆ៖** បាទ, គឺមិនត្រូវទេ ខ្ញុំអត់ដែលទៅសួរផង ។ គេឲ្យខ្ញុំទៅសួរតែខ្ញុំអត់ចេះមិនដឹងសួរយ៉ាងម៉េច? ខ្ញុំថាខ្ញុំអត់ចេះទេ ខ្ញុំនៅតែក្រៅការពារអ៊ីចឹងទៅ ។

**ស៖** ខ្ញុំមានសំណួរសួរពីរចំណុចទៀត ខ្ញុំនឹង ចំណុចទីមួយលោកបាន--

**ប្រធានអង្គជំនុំ៖**

មេធាវីការពារក្ដី?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមរំឭកសវនាការ ឬក៏លោក វ៉ែនណឺ ថាការដកស្រង់ចម្លើយរបស់សាក្សីដែលបានចងក្រងដោយសហចៅក្រមស៊ើបអង្កេតនោះគឺនៅក្នុងឧបសម្ព័ន្ធ D48/2 ហើយកំណត់ត្រាលាយលក្ខណ៍អក្សរនោះ ដែលចងក្រងដោយសហចៅក្រមស៊ើបអង្កេត គឺវាមានតម្លៃគឺវាពិតមានខ្លឹមសារពិតប្រាកដ ហើយចំណុចនោះគឺថាសាក្សីបានប្រកាសថា មិនពិតហើយ បើសិនជាលោកវ៉ែនណឺគាត់ចង់ដេញដោលទាក់ទងទៅនឹងកំណត់ត្រាដែលរៀបចំដោយសហចៅក្រមស៊ើបអង្កេតហ្នឹងគឺគាត់ត្រូវតែស្នើជាផ្លូវការ ដើម្បីធ្វើដូច្នោះបាន ។

[១០:២២:៥១]

**លោក អាឡាំង វ៉ែនណឺ៖**

នេះគឺជាឯកសារនៅក្នុងសំណុំរឿង ខ្ញុំមិនជំទាស់ហ្នឹងអ្វីដែលមាននោះទេ ខ្ញុំគ្រាន់តែសួរជាមួយសាក្សីថាគាត់ពិតជាបាននិយាយអ៊ីចឹងមែនឬក៏អត់? អ៊ីចឹងខ្ញុំសូមអនុញ្ញាតបន្តទៀត ដោយសារខ្ញុំមានការព្រួយបារម្ភថាពេលនៅសល់ខ្លី ។

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

**ស៖** ដូច្នេះលោក ហ៊ឹម ហ៊ុយ លោកបាននិយាយ លោកនិយាយថាតើលោក ប៊ែន យៀវនិន នៅថ្ងៃ កក្កដា ១៩៨៦ ERN00280073 ហើយសូមលោកបញ្ជាក់ថាពិត ឬក៏មិនពិត ។ លោកបាននិយាយថា ឌុច បានសម្លាប់បងប្អូនថ្លៃពីររបស់ខ្លួននៅឆ្នាំ១៩៧៨ ព្រោះប្អូនថ្លៃពីរនាក់មានឈ្មោះក្នុងសមាសភាពខ្មាំង និងមានទំនាក់ទំនងជាមួយកម្មាភិបាល ។ នៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិ

សួរលោកថ្ងៃនេះ នៅពេលដែលសួរថា សម្លាប់តែម្នាក់ ប៉ុន្តែនៅក្នុងសំណុំរឿងថា នេះមិនថា ឌុច បានសម្លាប់បងប្អូនប្រុសថ្លៃរបស់ខ្លួននោះពីរនាក់ក្នុងឆ្នាំ១៩៧៨។ តើមែន អ៊ីចឹងមែនឬទេ?

**ផ៖** បាទ, ខ្ញុំសូមជម្រាបថា នៅក្នុងជំនាន់ហ្នឹង ពេលដែលខ្ញុំមានប្រពន្ធការហើយក្រោយនេះ គឺខាងប្រពន្ធខ្ញុំទេដែលស្លាប់ ខាងបងថ្លៃខ្ញុំហ្នឹង បងខាងប្រពន្ធខ្ញុំហ្នឹងស្លាប់ពីរនាក់ គឺស្លាប់បងថ្លៃប្រពន្ធខ្ញុំមួយ ហើយបងប្រពន្ធខ្ញុំមួយ។ ខ្ញុំអត់ប្អូនខ្ញុំមួយ ដែល ឌុច សម្លាប់ ។ ហ្នឹង បងខន ប្រាប់ខ្ញុំ ។ ប្អូនខ្ញុំហ្នឹងពេលដែលកម្មាភិបាលឲ្យខ្ញុំជូនគាត់ទៅដោះកម្មាភិបាលប្រាំមួយនាក់ ដែលជាប់គុកក្បែរផ្ទះខ្ញុំ ខ្ញុំបានសុំគាត់ទៅលេងផ្ទះខ្ញុំ ទៅមើលម៉ែឪខ្ញុំ ពេលនោះឃើញប្អូនខ្ញុំឈឺ កើតខាន់លឿង ដល់ហើយខ្ញុំមកវិញៗខ្ញុំប្រាប់ ពេទ្យ រិន ប្រាប់បងរិន ថាបងៗប្អូនខ្ញុំកើតខាន់លឿងតើបានថ្នាំស្អីផឹក បើមូលដ្ឋានគេអត់មើលផង? គាត់ថាហ្អែង សុំ បងហ៊ី ទៅ សុំបងហ៊ី បងហ៊ីៗឲ្យយកមកៗ អញមើលតែមួយអាទិត្យជាហើយចាំយកទៅវិញ ។ ប្អូនខ្ញុំ ខ្ញុំក៏ទៅសុំបងហ៊ីៗ បងហ៊ីឲ្យទៅយក យកមក បងរិន គាត់មើលតែមួយអាទិត្យជាអ៊ីចឹងមែន ។ ហើយខ្ញុំសុំ តាហ៊ី បងៗសុំយកវាទៅផ្ទះវិញព្រោះម៉ែឪខ្ញុំចាំមើលយូរហើយឥឡូវវាជា គាត់ថាអញអត់ឲ្យទៅទេ ឲ្យនៅជាមួយក្អួយអញ។ ហើយប្អូនខ្ញុំនៅរហូត ខ្ញុំមិនដឹងយ៉ាងម៉េចបើគាត់អត់ឲ្យយកទៅហើយ។ នៅរហូតដល់ពេលបែកហ្នឹងក៏រត់ទៅព្រៃទៅអីហ្នឹងដល់ពេលទៅព្រៃទៅអីហ្នឹងខ្ញុំក៏រត់ មកវិញមក នាំកម្លាំងរត់មកវិញមក ប្អូនខ្ញុំនៅជាមួយតាហ៊ី ជាមួយប្រពន្ធជាមួយក្អួយគាត់តាឌុច សម្លាប់ចោល ។ ហើយ ប្រាក់ ខន ថា សម្លាប់ តាហ៊ី ចោលហើយតាឌុច ឲ្យកម្លាំងតាមមកសម្លាប់ខ្ញុំចោលទៀត។ ខ្ញុំនាំកម្លាំងរត់មក ខ្ញុំនាំកម្លាំងរត់ចូលមកគ្នា ។ សូមអស់ ។

[១០:២៦:៤៣]

**ស៖** សំណួរចុងក្រោយដែលខ្ញុំសួរទៅលោកសាក្សី បន្ទាប់មកនិងមេធាវីជាតិ ។ លោកបានផ្តល់បទសម្ភាសន៍នៅក្នុងឆ្នាំ១៩៩០ មានអត្ថបទជាភាសាអង់គ្លេស ERN00171154 ហើយនិង ខ្ញុំមានអត្ថបទជាភាសាបារាំងដែរលេខ 00251290 ហើយក្នុងភាសាខ្មែរ 00280081 អ៊ីចឹងមានសំណួរនិងចម្លើយ ។ ខ្ញុំឲ្យលោកបញ្ជាក់ថា ពិត ឬមិនពិត? សំណួរគេសួរថា តើលោកទទួលបញ្ជាពីអ្នកណាតើលោកយល់ថាបញ្ជានោះយ៉ាងម៉េច? លោកបានឆ្លើយថា បញ្ជាទាំងអស់នោះគឺចេញមកពី ហ៊ី និងពីឌុច ហើយដើម្បីបញ្ជូនអ្នកទោសចេញ ឬក៏ចូលហើយខ្ញុំមិនបានដឹងថាតើមានទារុណកម្ម ហើយឃើញថាតើអ្នកទោសនោះទទួលការឈឺចាប់ខ្លាំងដែលធ្វើឲ្យខ្ញុំមានការភ័យខ្លាចណាស់ ។ ខ្ញុំមិនដឹងថា គេបញ្ជូនទៅជើងឯកដើម្បីសម្លាប់ទេ ។ ហើយលោកបញ្ជាក់ថា នៅក្នុងស-២១ ខ្ញុំបានឮលោក ឌុច និងលោក ហ៊ី

និយាយថា យើងត្រូវសម្លាប់ទាំងអស់ ហើយទុកសម្រាប់តែមនុស្សបួនលានប៉ុណ្ណោះ ។ តើលោកបាននិយាយការណ៍ហ្នឹងទៅឱ្យ លោក ប្រាប់ទៅលោក ទឹម សៅ ហ្នឹងដែរឬទេ? កាលណោះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ដូចខ្ញុំបានជម្រាបមុនហ្នឹងអ៊ីចឹង ពេលរៀនសូត្រកន្លែងសាលារបស់តាឌុច ហ្នឹង តាឌុច បាននិយាយខ្លួនគាត់ផ្ទាល់នៅកន្លែងរៀនសូត្រហ្នឹងគាត់ថា សម្លាប់ឱ្យខ្ទេចទាំងអស់ មិនមែនថាសម្លាប់តែស-២១ ទេ បើថាសម្លាប់ខ្ទេចគឺសម្លាប់ទូទាំងប្រទេសហើយ ព្រោះគុកហ្នឹង វាគុកទូទាំងប្រទេស ។

**លោក អាឡាំង វែនណឺ៖**

សូមអរគុណដែលលោកបានឆ្លើយសំណួរខ្ញុំ ។

**សួរដោយកញ្ញា ទី ស្រ៊ុនណា៖**

**ស៖** សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម និងអង្គសវនាការទាំងមូល។ សូមជម្រាបសួរលោក ហ៊ឹម ហ៊ុយ ខ្ញុំសូមបន្តសំណួររបស់នាងខ្ញុំ ។ សំណួរទីមួយនាងខ្ញុំចង់បញ្ជាក់លោកបន្តិចទាក់ទងទៅនឹងការកម្ទេចជាលក្ខណ:ទ្រង់ទ្រាយធំ ដែលលោកបានលើកឡើងថាមានការកម្ទេចនៅក្នុងដែលបានបញ្ជូនមនុស្សពីមន្ទីរស-២១ ទៅកាន់ជើងឯកដើម្បីកម្ទេចលក្ខណ:ទ្រង់ទ្រាយធំហ្នឹង តើលោកអាចចាំបានទេ តើនៅក្នុងឆ្នាំណាដែរ?

[១០:២៩:៣៥]

**ឆ៖** បាទ, ខ្ញុំសូមជម្រាប! ក្នុងឆ្នាំ៧៧ ហ្នឹង ៧៧-៧៨ ហ្នឹង ។

**ស៖** កាលពីសប្តាហ៍មុន លោកបាននិយាយថា លោកបានឃើញជនជាប់ចោទគឺលោក ឌុច បាន ដើរទៅក្នុងបន្ទប់អ្នកគូររូប តើពេលដែលលោកឃើញហ្នឹង ឃើញក្រោយពេលដែលមានការកម្ទេចលក្ខណ:ទ្រង់ទ្រាយធំហ្នឹងហើយ ឬក៏មុនពេល?

**ឆ៖** បាទ, នៅពេលហ្នឹង ពេលដែលគេសម្លាប់ច្រើនហ្នឹង ។

**ស៖** មានន័យថា សម្លាប់ច្រើនរួចហើយ? អ៊ីចឹងមែនទេ?

**ឆ៖** បាទ, ក្នុងពេលហ្នឹងទាំងអស់ហ្នឹង ក្នុងពេលដែលសម្លាប់ហ្នឹង ។

**ស៖** អ៊ីចឹងពេលដែល ក្រោយពីពេលដែលមានការសម្លាប់ទ្រង់ទ្រាយធំហ្នឹងហើយ ក្រោយពេលដែលមានការសម្លាប់ហើយ តើលោកមានដែលបានសង្កេតឃើញអាកប្បកិរិយារបស់ជនជាប់ចោទគឺលោក ឌុច តើគាត់មានដែលបញ្ចេញអាកប្បកិរិយាថាមិនពេញចិត្តហ្នឹងសកម្មភាពដែលមានការសម្លាប់

ជាលក្ខណៈទ្រង់ទ្រាយធំហ្នឹងដែរឬទេ?

**ឆ៖** បាទ,ខ្ញុំសូមជម្រាបថា គាត់មិនមែនមិនពេញចិត្តទេ ព្រោះគាត់ជាអ្នកបញ្ជាគេហើយគាត់គឺជាអ្នកពេញចិត្ត ។

**ស៖** ខ្ញុំសូមបន្តសំណួរខ្ញុំទៀត ។ ទាក់ទងទៅនឹងមុខងាររបស់លោក លោកថា លោកធ្លាប់មានការដើរត្រួតពិនិត្យនៅក្នុងមន្ទីរស-២១ ក៏ដូចជាបរិវេណជុំវិញស-២១។ តើលោកមានដែលទៅតាមផ្ទះមានន័យថា តាមផ្ទះនៅជុំវិញរបងស-២១ ហ្នឹង តើផ្ទះ តើមានការឃុំឃាំងមនុស្សនៅក្នុងតាមផ្ទះហ្នឹងដែរឬទេ?

**ឆ៖** បាទ, គុកវាមាន អង្កាល់ដែលមុនរៀបហ្នឹងវាមានគុកនៅខាងត្បូងហ្នឹង តាមផ្ទះហ្នឹងនៅខាងត្បូងហ្នឹងបានគេរៀបចំ អគារទាំងអស់ហ្នឹងបានគេយកអ្នកទោសដែលនៅខាងត្បូងហ្នឹងទៅដាក់ជាមួយ គ្នាទាំងអស់នៅខាងក្នុងតែម្តង។

**ស៖** ខ្ញុំសូមឲ្យលោកជួយបញ្ជាក់បន្តិច គឺនៅខាងក្រៅរបងនៃមន្ទីរស-២១ ឬក៏នៅក្នុងមន្ទីរស-២១? ផ្ទះនៅក្នុង ឬក៏នៅក្រៅ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា នៅខាងត្បូងៗអគារ បណ្តោយថ្ងៃហ្នឹង ។

**ស៖** ខាងក្រៅរបង?

[១០:៣២:០៧]

**ឆ៖** កាលមុនវាអត់ទាន់ធ្វើគុក ហ្នឹងទេ ដល់ពេលចាប់ផ្តើមជាគុកហ្នឹង កាលមុនវានៅខាងត្បូងរបងហ្នឹង ខាងត្បូងអគារបណ្តោយថ្ងៃហ្នឹង ដល់ធ្វើហើយបានគេយកអ្នកទោសហ្នឹងបញ្ចូលទៅក្នុងហ្នឹងទៅ។

**ស៖** តើផ្ទះដែលគេឃុំឃាំងហ្នឹងមានចំនួនប៉ុន្មានដែរ?

**ឆ៖** មិនដឹងប៉ុន្មានទេ ខ្ញុំភ្លេចចាំហើយ ។

**ស៖** តើការឃុំខ្លួនមនុស្សនៅតាមផ្ទះហ្នឹង ជាមនុស្សប្រភេទណាដែលគេយកទៅឃុំតាមផ្ទះ ហើយមនុស្សប្រភេទណាដែលគេបញ្ជូនយកឃុំនៅក្នុងមន្ទីរស-២១? លោកអាចចាំបានទេ?

**ឆ៖** បាទ, សុទ្ធតែអ្នកសំខាន់ៗបានគេយកមកឃុំឃាំងនៅកន្លែងហ្នឹង ដល់ហើយមកបានគេចាប់ជាទូទៅតែម្តង ។

**ស៖** ពាក់ព័ន្ធជាមួយនឹងក្មេង លោកបាននិយាយថា ត្រូវបានបុគ្គលិកមន្ទីរស-២១ ហ្នឹងបញ្ជូនយកទៅសម្លាប់នៅមន្ទីរស-២១ តើក្មេងទាំងហ្នឹងមានចំនួនប៉ុន្មាននាក់ដែរ លោកអាចចាំបានទេ?

**ឆ៖** ខ្ញុំចាំមិនបានដែរទេ ប៉ុន្តែប្រហែលជាមួយរយនាក់ ។

**ស៖** តើក្មេងដែលបញ្ជូនយកទៅសម្លាប់ទាំងនុ៎ង មុននឹងធ្វើការបញ្ជូនយកទៅសម្លាប់តើមានការធ្វើប្រវត្តិរូប ឬក៏ថតរូបដើម្បីទុកនៅក្នុងមន្ទីរស-២១ ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំអត់បានដឹងទេ ។

**ស៖** ខ្ញុំសូមបញ្ជាក់លោក ទាក់ទងទៅនឹងការដែលលោកបានដើរនៅក្នុងមន្ទីរស-២១ នៅក្នុងអំឡុងពេលដែលលោកបានដើរនៅក្នុងមន្ទីរស-២១ តើលោកមានដែលបានឮសំឡេងសម្រែកថ្ងូររបស់ជនរងគ្រោះនៅក្នុងមន្ទីរស-២១ ស្រែកពីការឈឺចាប់របស់ខ្លួនដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា អ្នកទោសដែលគេយកទៅវ៉ៃសួរចម្លើយមកវិញគឺឈឺណាស់។ វ៉ៃឡើងបែកឈាម បែកអីពេញខ្លួន អ៊ីចឹងដេកវាឈឺហើយ ស្រែកហើយ ។ ហើយអ៊ីចឹងគេបញ្ជាឲ្យអ្នកយាមធ្វើម៉េច ឡូឡាកុំឲ្យអ្នកទោសស្រែកឮ ហ្នឹងគេបញ្ជាធ្វើម៉េចកុំឲ្យអ្នកទោសស្រែកឡូឡាឮ។

**ស៖** ខ្ញុំសូមសួរទៀត ទាក់ទងទៅនឹងការដើរត្រួតពិនិត្យនៅតាមបន្ទប់នីមួយៗ តើលោកពិតជាបានឃើញទិដ្ឋភាពនៃការឃុំឃាំងមនុស្ស មានន័យថាជនរងគ្រោះត្រូវបានដាក់ខ្នោះជើងជាជួរៗ ហើយនិងដាក់ជើងទល់មុខគ្នា ដាក់ជើងទល់គ្នា តើលោកមានដែលបានឃើញទិដ្ឋភាពហ្នឹងនៅក្នុងតាមបន្ទប់នីមួយៗនៃមន្ទីរស-២១ ដែរឬទេ?

[១០:៣៥:០០]

**ឆ៖** បាទ, ខ្ញុំសូមជម្រាប ពេល តាហ៊ី ឲ្យខ្ញុំដូចថា ពេលគេចាប់បានគ្នាច្រើនយកមកអ៊ីចឹងវារញ៉េរញ៉ៃ តាហ៊ី ឲ្យខ្ញុំជួយទៅមើលម្តងម្កាល ។ តែខ្ញុំអត់ចង់ទៅទេព្រោះជើងខ្ញុំរបួសឡើងគ្រប់ជាន់អ៊ីចឹងខ្ញុំ ចុកជើងណាស់ ។ ខ្ញុំរបួសជើង ស្លឹកជើងរហូតតាំងពីរបួសមកឃើញតែឡើងជាន់ណាៗ គឺឡើងមួយជាន់ ពីរជាន់ឈប់ហើយ ។

**ស៖** ខ្ញុំសូមឲ្យលោកឆ្លើយឲ្យចំទៅនឹងសំណួរខ្ញុំបន្តិច ព្រោះកន្លែងហ្នឹងប្រហែលជាមានការភាន់ច្រឡំបន្តិចសុំទោស សុំឲ្យលោកឆ្លើយថា តើលោកមានធ្លាប់បានឃើញគេដាក់ខ្នោះអ្នកទោស មានន័យថានៅក្នុងបន្ទប់ឃុំឃាំងហ្នឹង មានដាក់ខ្នោះអ្នកទោសហ្នឹងជាជួរ ដោយមានដាក់ខ្នោះជើងហ្នឹងជាជួរដោយមានដែកបណ្តោយ ដែកតាមបណ្តោយហ្នឹងគេដាក់ខ្នោះជាជួរហើយ មានប្រហែលជាមួយជួរដប់

នាក់ជាងអ៊ីចឹង ហើយមួយជួរដប់នាក់ ជាងអ៊ីចឹងហើយដាក់ជើងទល់មុខគ្នា។ លោកមានបានឃើញសកម្មភាពហ្នឹងទេ?

**ឆ៖** បាទ, អ៊ីចឹងខ្ញុំសូមជម្រាបថា ពេលដែលខ្ញុំឡើងទៅហ្នឹងគឺខ្ញុំឃើញ ឃើញតាំងពីបន្ទប់តូចៗក៏មាន ឃើញដាក់ខ្នោះ ដល់អ្នកទោសច្រើនដាក់ខ្នោះក្នុងមួយរនងដែលគេដាក់កងម្នាក់មួយៗហ្នឹងគឺមិនមែនត្រឹមដប់នាក់ទេ មានតែជាងដប់នាក់។ ហើយក្នុងមួយជួរៗ មួយបន្ទប់មានតែបីជួរប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយមេធាវី ។ ឥឡូវនេះ ដល់ពេលត្រូវសម្រាកផង អង្គជំនុំជម្រះប្រកាសសម្រាក ម្ភៃនាទី ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្ទះប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចនីតិវិធីដំណើរការសវនាការ ។

*[សវនាការសម្រាកពីម៉ោង ១០:៣៧នាទី ដល់ម៉ោង ១១:០១នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោល ស្តាប់សក្ខីកម្មសាក្សី ហ៊ឹម ហ៊ុយ ។ ហើយជាកិច្ចបន្តនេះ សូមប្រគល់វេទិកាអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ បើសិនជាមានសំណួរត្រូវសួរដល់សាក្សីរូបនេះ ។ សូមអញ្ជើញ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

**ស៖** សូមអរគុណលោកប្រធាន ។ សូមជម្រាបលោក ហ៊ឹម ហ៊ុយ ខ្ញុំឈ្មោះ ស្ទូតហ្សីនស្គី ខ្ញុំជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានន័យថាតំណាងឲ្យជនរងគ្រោះ ។ ខ្ញុំចង់ជម្រាបលោកថា នៅក្នុងសវនាការនេះយើងមានជនរងគ្រោះកំពុងតែអង្គុយស្តាប់ ហើយពួកគាត់ចង់ដឹងថា មានហេតុការណ៍ខ្លះកើតឡើងនៅស-២១ ហើយនិងនៅជើងឯក ។ ហើយលោកអាចឆ្លើយ អាចជាវិភាគទានមួយស្វែងរកការពិតអំពីរឿងនោះ ដើម្បីឲ្យពួកគេអស់ចម្ងល់ គេចង់ដឹង ហើយនិងសាច់ញាតិរបស់គេបានដឹងផង ។ សំណួរទីមួយ ចំពោះលោកនោះគឺ តើលោកធ្លាប់ប្រព្រឹត្ត ឬធ្វើបាបអ្នកណាម្នាក់ឬទេនៅស-២១?

**ឆ៖ ឆ**ខ្ញុំសូមជម្រាបថា ខ្ញុំអត់ទៅធ្វើបាបអ្នកណាទេ ព្រោះដូចគេចាប់មកអ៊ីចឹង ខ្ញុំក៏មិនដឹងថាអ្នកណាមានរឿងអីមានរឿងអីដែរ ហើយខ្ញុំជួយអ្នកណាក៏ខ្ញុំជួយអត់បានដែរ ពេលគេដឹកយកទៅក៏ខ្ញុំដឹងទៅតាមដែលគេបញ្ជាឲ្យយកទៅ ។

**ស៖** លោក ហ៊ឹម ហ៊ុយ តើលោកស្គាល់លោក ប៊ូ ម៉េង ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំស្គាល់គាត់ ។ ពេលដែលគាត់សួរខ្ញុំ ពេលខ្ញុំបើកទ្វារបង្អួចកន្លែងជាងគូរគំនូរហ្នឹង គាត់សួរខ្ញុំថា ឃើញប្រពន្ធខ្ញុំអត់? ហើយគេនៅកន្លែងហ្នឹងគេមិនឲ្យប្រាប់ថា តិចទៅប្រាប់អ្នកទោសដែលជាប្ដីអីហ្នឹងថាប្រពន្ធទៅណាៗ អត់បានទេណា! ប្រាប់ថាបើសួរឲ្យនិយាយថា ប្រពន្ធអ្នែងគេយកទៅឲ្យធ្វើស្រែហើយ តិចថាយកទៅសម្លាប់ចោល អាហ្នឹងទទួលខុសត្រូវ ។

[១១:០៥:០៤]

**ស៖** អ៊ីចឹងតើត្រឹមត្រូវទេ ដែលយើងបានថាគេបានសួរលោករួចហើយនៅស-២១ នៅពេលដែលលោកយាមនៅទីនោះ គឺលោក ប៊ូ ម៉េង បានសួរលោក សួរថាប្រពន្ធគាត់នៅឯណា? តើអ៊ីចឹងមែនឬទេ?

**ឆ៖** បាទ, គឺអ៊ីចឹងមែន ។ ច្បាប់របស់គេអត់ឲ្យប្រាប់ទេ តែអ្នកណាធ្វើឲ្យបែកការណ៍អ្នកហ្នឹងចូលគុកដែរ ។

**ស៖** ថ្ងៃនេះ នៅក្នុងសាលសវនាការតើលោកអាចប្រាប់យើងបានទេ? ថ្ងៃនេះលោក ប៊ូ ម៉េង បានទេថាតើប្រពន្ធគាត់នោះទៅជាយ៉ាងណា? ថាតើគេយកប្រពន្ធគាត់ទៅសម្លាប់នៅកន្លែងណា?ហើយនិងកប់នៅកន្លែងណា?

**ឆ៖** ខ្ញុំសូមជម្រាបថា ដែលគេយកចេញទៅគេយកទៅសម្លាប់នៅជើងឯកហ្នឹងតែម្ដង ។

**ស៖** ខ្ញុំមិនសួរជាទូទៅ ខ្ញុំសួរករណីមួយ សូមឲ្យលោកប្រាប់ទៅ ប៊ូ ម៉េង ដែលគាត់អង្គុយនៅទីនេះនៅក្នុងសាលសវនាការនៅខាងក្រោយខ្ញុំនេះ ប្រសិនបើលោកងាកខាងឆ្វេងលោកនឹងឃើញគាត់ ។ ដើម្បីឆ្លើយទៅគាត់ផ្ទាល់ អំពីជោគវាសនារបស់ប្រពន្ធគាត់ មិនមែនសួរសំណួរទូទៅថា អ្នកទោសភាគច្រើនយកទៅជើងឯកនេះ យើងសួរតែប្រពន្ធរបស់លោក ប៊ូ ម៉េង មួយ ។

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំអត់មានដឹងថា អ្នកណាឈ្មោះអី ឬប្រពន្ធរបស់អ្នកទេ ប៉ុន្តែស្ត្រីដែលគេសួរចម្លើយហើយ ឬមួយក៏គេមិនសួរក៏គេយកទៅសម្លាប់នៅជើងឯកដែរ ។ អ៊ីចឹង បានខ្ញុំប្រាប់គាត់ថារឿងប្រពន្ធ គឺគេយកទៅសម្លាប់នៅជើងឯកតែម្ដង ។

**ស៖** លោក ហ៊ឹម ហ៊ុយ លោកបានជម្រាបសវនាការរួចហើយលោកបានទៅដល់ជើងឯកហើយ លោកបានធ្វើបញ្ជីរៀបចំមន្ទីរនៅកន្លែងនោះ ។ អ៊ីចឹងហើយ គ្រប់អ្នកទោសដែលជូនទៅគឺត្រូវស្រង់បញ្ជីម្តងទៀតមុននឹងសម្លាប់នោះ ។ ហើយចង់ជម្រាបលោកបន្ថែមថាឈ្មោះប្រពន្ធរបស់លោក ប៊ូ ម៉េង គឺឈ្មោះ ម៉ា យឿន ហៅ ធី ។ អ៊ីចឹង ក្រោយពីឮឈ្មោះនេះទៅ លោកអាចឆ្លើយសំណួរហ្នឹងបានឬទេ?

**ឆ៖** ខ្ញុំជម្រាបថា អ្នកទោសដែលបញ្ជូនទៅក៏មិនមែនតែខ្ញុំបញ្ជូនទៅដែរទេ គឺគេឲ្យខ្ញុំទៅជូន កាលគេមិនឲ្យខ្ញុំទៅគេឲ្យ ផល ទៅ ។ អ៊ីចឹង ខ្ញុំមិនដឹងថាលើអ្នកណាទេ ប៉ុន្តែដែលគេបញ្ជូនទៅ គេយកទៅសម្លាប់នៅជើងឯកតែម្តង ។

[១១:០៩:០១]

**ស៖** អ៊ីចឹង ខ្ញុំចង់បាន ចង់ឲ្យលោកឆ្លើយនឹងសំណួរមួយនេះហើយជនជាប់ចោទបានប្រាប់យើងពីសប្តាហ៍មុនថា លោកជាអ្នកដឹងពីទីកន្លែង ហើយនិងអំពីពេលវេលាដែលកន្លែងដែលប្រពន្ធរបស់ ប៊ូ ម៉េង នោះត្រូវគេសម្លាប់ហើយនិងកប់ ។ អ៊ីចឹងហើយដូចគាត់ជាអតីតមេរបស់លោកនោះ គាត់បញ្ជាក់អ៊ីចឹង ។ អ៊ីចឹងលោកអាចនឹងជួយផ្តល់នូវចម្លើយដើម្បីលោក ប៊ូ ម៉េង គាត់រង់ចាំចម្លើយនេះជាយូរមកហើយ ។

**ឆ៖** ខ្ញុំសូមជម្រាបដូចអម្បាញ់មិញថា គេបញ្ជាឲ្យយកទៅសម្លាប់នៅជើងឯកទាំងអស់ឲ្យដឹកយកទៅហ្នឹង ។ សូមអស់ហើយ ។

**ស៖** អ៊ីចឹង ខ្ញុំត្រឡប់ទៅការចាត់ចែងទៅលើអ្នកទោស លោកបាននិយាយថាលោកមិនដែលធ្វើបាបអ្នកទោសនោះទេ ។ លោក ប៊ូ ម៉េង បានធ្លាប់ជាអ្នកទោសនៅកន្លែងនោះ ហើយរងទារុណកម្មនៅទួលស្លែងនៅស-២១ ហ្នឹង ។ គាត់បាននិយាយថា-- គាត់និយាយថា ហ៊ឹម ហ៊ុយ បានធ្វើទារុណកម្មគាត់ក្នុងចំណោមអ្នកធ្វើទារុណកម្មមួយចំនួនទៀត ។ តើលោកអាចបញ្ជាក់បានទេថា គាត់និយាយនុ៎ងត្រឹមត្រូវ ឬមិនត្រឹមត្រូវដែលថាគាត់និយាយថា គាត់រងការធ្វើបាបហើយលោកធ្លាប់បានវាយគាត់ កាលពីគាត់ជាប់ពន្ធនាគារនោះ ។

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំអត់មានសិទ្ធិអីសម្រាប់ដូចសួរចម្លើយសួរអីទេ អ្នកទោសដែលយកមកគឺអ្នកយកមកក៏មិនអាចមានសិទ្ធិអីទៅធ្វើបាបអ្នកទោសដែរ ព្រោះនៅលើអ្នកសួរចម្លើយទាំងអស់ ដែលគឺអ្នកធ្វើសកម្មភាពនៅលើហ្នឹង ។

**សៈ** អ៊ីចឹង ខ្ញុំចូលទៅដល់ចំណុចមួយទៀត ជារបាយការណ៍នៃការសម្តែងឡើងវិញនៅក្នុងផ្នែកមួយដែលសហសេវិកខ្ញុំបានអានជូនលោកហើយ ឯកសារ D48/2 នៅក្នុងអង់គ្លេស លេខERN លេខ 00198004 ។ លោកបានឆ្លើយទៅនឹងមេធាវីរួចហើយថា លោកមិនដែលចូលរួមក្នុងការសួរចម្លើយទេ ហើយលោកបានជម្រាបចៅក្រមហើយដែរ អំពីការសម្តែងឡើងវិញអំពីរឿងការធ្វើទារុណកម្ម តើលោកបានប្រាប់ចៅក្រមក្នុងពេលធ្វើការសម្តែងឡើងវិញ ដែលលោកបានចូលរួមនៅក្នុងការធ្វើទារុណកម្មនៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលថា មួយឆ្នាំកន្លះហើយដែលយើងបានកត់សម្គាល់ឃើញថា ឥឡូវនេះ លោកបាននឹកឃើញអំពីហេតុការណ៍ដែលត្រូវធ្វើសម្តែងឡើងវិញនោះ ។

**ឆៈ** ខ្ញុំសូមជម្រាបថា ខ្ញុំអត់មានតួនាទីអីទៅសួរចម្លើយនិងធ្វើទារុណកម្មអ្នកទោសទេ ខ្ញុំនៅចាំទទួលអ្នកទោសដែលគេបញ្ជូនយកមក ។ ហើយនិងចាប់ឯណា គឺខ្ញុំទទួលបញ្ជាគេទៅចាប់ ប៉ុន្តែរឿងធ្វើទារុណកម្ម គឺផ្នែកខាងសួរចម្លើយទេ ដែលគេជាអ្នកទៅធ្វើហើយនិងសួរ ។ ព្រោះខ្ញុំបាននិយាយថា គេឲ្យខ្ញុំទៅសួរចម្លើយ ខ្ញុំថាខ្ញុំអត់ចេះសួរទេ ខ្ញុំធ្វើចម្លើយយ៉ាងម៉េច? អីយ៉ាងម៉េច? ពីព្រោះធ្វើទារុណកម្មអ្នកទោសមិនដឹងម៉េចកើត ខ្ញុំមិនចេះទេ ។

**សៈ** អ៊ីចឹងគឺថា សំណួរខ្ញុំសួរថា ហេតុបានជាលោកប្រាប់ចៅក្រមនៅពេលនោះថា នៅក្នុងខែកុម្ភៈ ឆ្នាំ២០០៨ ហេតុអ្វីបានលោកទទួលស្គាល់ថា អ្វីដែលលោកបញ្ជាក់នោះ ប៉ុន្តែថ្ងៃនេះលោកបញ្ជាក់មិនដែលបានធ្វើ ។ ចុះហេតុអ្វីពេលនោះលោកប្រាប់ចៅក្រមថាលោកបានធ្វើនោះ?

**ឆៈ** ខ្ញុំបានជម្រាបថា តាំងមុនមកគឺខ្ញុំអត់ដែលបានទៅសួរអ្នកទោសទេ ហើយសួរធ្វើទារុណកម្មអ្នកទោសទេ ព្រោះខ្ញុំអត់ចេះៗធ្វើទេ ។ ខ្ញុំថាឲ្យខ្ញុំទៅសួរចម្លើយម៉េច បើខ្ញុំមិនចេះសួរ ហើយឲ្យធ្វើទារុណកម្មយ៉ាងម៉េច? ក៏ខ្ញុំអត់ចេះដែរ នឹកឃើញថា ខ្ញុំនៅតែក្រៅទៅយាមទៅវារួចខ្លួនហើយ ។ សួរចម្លើយគិតគូរចង់ងាប់ចង់រស់ ដឹងធ្វើម៉េចត្រូវ? ព្រោះខ្ញុំអក្សរក៏ខ្ញុំមិនសូវចេះដែរ ។

**សៈ** ខ្ញុំមិនគិតថា ដើម្បីឲ្យធ្វើទារុណកម្មបានទាល់តែចេះអានចេះសរសេរនោះទេ ប៉ុន្តែជាថ្មីម្តងទៀតខ្ញុំសួរការឆ្លើយតបទៅនឹងសំណួរ ។ ខ្ញុំគ្រាន់តែចង់ដឹងថា ហេតុអ្វីបានលោកប្រាប់ការកុហកហ្នឹងទៅសហចៅក្រមស៊ើបអង្កេតនៅក្នុងខែកុម្ភៈ កាលពីឆ្នាំទៅនោះ ។

**ឆៈ** បាទ ខ្ញុំសូមជម្រាបថា--

**លោក គង់ សំអុនៈ**

លោកប្រធានសុំអនុញ្ញាត ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីជំនួយសាក្សី ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបានដំបូងសូមឲ្យអ្នកស្រីមេធាវីចង្អុលបង្ហាញចំណុចដែលថាមិនស្របគ្នារវាងចម្លើយសាក្សីពីចម្លើយដែលបានផ្តល់សក្ខីកម្មជាមួយចៅក្រមស៊ើបអង្កេត និងចម្លើយនៅពេលនេះសិន ។ ដើម្បីឲ្យសាក្សីពិនិត្យមើលថា តើវាជាចម្លើយដែលបានឆ្លើយដោយត្រឹមត្រូវដែរឬអត់?

សូមអរគុណ ។

**សួរដោយលោកស្រី ស៊ីលយ៉ី ស្ទួតហ្សីនស្គី៖**

**ស៖** ខ្ញុំសូមអនុញ្ញាតបន្ត ។ ខ្ញុំសួរសំណួរហ្នឹងឡើងវិញ ខ្ញុំបានដកស្រង់រួចហើយដោយមេធាវីដើមបណ្តឹងរដ្ឋប្បវេណីពីខាងដើម ។ ខ្ញុំចង់ដឹងថា ហេតុអ្វីបានជាលោកកុហកទៅសហចៅក្រមស៊ើបអង្កេតនៅក្នុងខែកុម្ភៈ ឆ្នាំ២០០៨ នៅពេលដែលលោកឆ្លើយថា “បាទ, ខ្ញុំបាទចូលរួមក្នុងការសួរចម្លើយហើយនិងធ្វើទារុណកម្ម” ហេតុអ្វីបានលោកឆ្លើយបែបនោះ? ដែលជាការមិនពិតនូវការកុហសហ្នឹង ។

[១១:១៦:៤២]

**ឆ៖** ខ្ញុំសូមជម្រាបថា អង្កាល់ពេលនោះដែលគេរើសអ្នកសួរចម្លើយចូលទៅហ្នឹង គេថា ហ៊ុយឯងចេះសួរចម្លើយអត់? ឥឡូវរើសចូលសួរចម្លើយជាមួយគេ ខ្ញុំថាសួរចម្លើយម៉េច? ទៅធ្វើទារុណកម្មអ្នកទោសយ៉ាងម៉េច? បើខ្ញុំអត់ចេះផងហ្នឹង អត់ចេះអក្សរផង សរសេរម៉េច? ធ្វើរបៀបយ៉ាងម៉េចអីយ៉ាងម៉េច? ខ្ញុំនឹកឃើញថា បើខ្ញុំទៅសួរចម្លើយខ្ញុំអត់ទៅទេ សុខចិត្តនៅយាមនៅអីហើយ ។ រួចគេសួរខ្ញុំអីចឹង ហើយខ្ញុំអត់ដែលបានទៅសួរចម្លើយអ្នកទោសរបៀបម៉េច? ខ្ញុំអត់ដែលបានដឹងផង ។

[១១:១៧:២១]

**លោកស្រី ស៊ីលយ៉ីស្ទួត ហ្សីនស្គី៖**

អូខេ-- *(គ្មានការបកប្រែ)* ។

**លោក គង សំអុន៖**

លោកប្រធាន?

**ប្រធានអង្គជំនុំ៖**

ខាងមេធាវីជំនួយសាក្សី ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន ។ អម្បាញ់មិញអ្នកស្រីមេធាវីនូវមិនទាន់បានបញ្ជាក់ថា តើចំណុចណាដែលសាក្សីនិយាយកុហសនោះទេ? ហើយលោកស្រីមេធាវីខាងដើមបណ្តឹងរដ្ឋប្បវេណីសន្និដ្ឋានថាហេតុអ្វីបានសាក្សីនិយាយកុហក។ ដូច្នេះ ហាក់ដូចជាសាក្សីហ្នឹងកំពុងតែនិយាយកុហករួចទៅហើយ ។ មុននឹងបញ្ជាក់ថាសាក្សីនិយាយកុហសទាល់តែយកសម្តីដែលពិតប្រាកដដែលមាននៅក្នុងកំណត់អះអាង ឬក៏កំណត់ហេតុដែលបានធ្វើពីលើកមុនមកបញ្ជាក់ថា តើជាពាក្យសម្តីបែបណាខ្លះ? នៅត្រង់ទំព័រណា? ចំណុចណា? ដើម្បីឲ្យសាក្សីពិនិត្យ ។ ហើយម្យ៉ាងទៀត ការនិយាយខុសគ្នាមិនប្រាកដទេ ពីព្រោះវាអាចជាកុហសដោយការកត់ច្រឡំ ឬក៏ស្តាប់ច្រឡំ ឬឆ្លើយដោយការភ្លេចភ្លាំងណាមួយ ។ សូមអរគុណ ។

[១១:១៨:៣២]

**ប្រធានអង្គជំនុំ៖**

សូមមេធាវី ស្ទួតហ្សីនស្គី ធ្វើតាមនេះឲ្យបានត្រឹមត្រូវ ពីព្រោះយើងមិនអាចទៅនិយាយរួមៗបានទេ ។ ចង្អុលនៅមាត្រា នៅបន្ទាត់ នៅឯកសារឲ្យបានច្បាស់លាស់នៅខ្លឹមសារ នៅកថាខណ្ឌណាជាក់លាក់ ដើម្បីធ្វើសួរ ឬក៏ធ្វើការបកស្រាយរឿងបញ្ហាកុហកនៅចំពោះមុខអង្គជំនុំជម្រះដូច្នេះ ។

**សួរដោយលោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។ ធម្មតាខ្ញុំទទួលការឱវាទនោះ គឺថាកុំឲ្យនិយាយឡើងវិញដដែល ប៉ុន្តែខ្ញុំសូមបញ្ជាក់-- ប៉ុន្តែគឺថាឯកសារ D48/2 នៅក្នុងអត្ថបទអង់គ្លេសលេខERN ដែលខ្ញុំបានអានម្តងហើយអាចមាននៅក្នុងប្រតិចារឹក00198004 ដែលសាក្សីបានបញ្ជាក់ទៅសហចៅក្រមស៊ើបអង្កេត គឺថានៅត្រង់ចំណុច8.9 ហើយគាត់ទទួលស្គាល់ថាគាត់បានចូលរួមក្នុងការសួរចម្លើយនិងធ្វើទារុណកម្ម ហើយការដកស្រង់នោះក៏បានលើកឡើងដោយលោក អាឡាំង វ៉ែនណឺ គឺពីមុនពេលសម្រាកនេះ ហើយខ្ញុំគិតថា នៅក្នុងអត្ថបទបកភាសាខ្មែរនោះត្រឹមត្រូវ ។

អ៊ីចឹងខ្ញុំសូមបន្តទៅទៀត បើសិនមិនអ៊ីចឹងទេ ខ្ញុំខាតពេល គឺថាមានការរំខានពីរដង អ៊ីចឹងខ្ញុំត្រូវការពេលបីមីនុតថែមទៀតដើម្បីបន្តទៅទៀត ។ ខ្ញុំត្រឡប់មកលោក ហ៊ីម ហ៊ុយ ដែលលោកមិនចង់ឆ្លើយសំណួរៗនេះទេ ។ ហើយខ្ញុំកត់សម្គាល់ឃើញថា ទោះបីជាចម្លើយដែលបានផ្តល់ទៅសហចៅក្រមស៊ើបអង្កេតនោះត្រូវ ឬក៏សក្ខីកម្មថ្ងៃមិនត្រឹមត្រូវ? អ៊ីចឹងទាក់ទងទៅនឹង ខ្ញុំបានជម្រាបលោករួចហើយថា លោក ប៊ូ ម៉េង បាននិយាយថាលោកជាអ្នកបានធ្វើទារុណកម្មលើគាត់ ។

**ស៖** តើលោកបាននឹកឃើញទេ ថាលោក ប៊ូ ម៉េង បើមិនមែនពិតទេ? ហេតុអីបានជា ប៊ូ ម៉េង បាន-- ថាតើហេតុអីបានជា ប៊ូ ម៉េង -- លោក ប៊ូ ម៉េង គាត់និយាយអ៊ីចឹង? គាត់និយាយកុហក ឬមិនកុហកដែលគាត់ប្រាប់តុលាការអ៊ីចឹង តើលោកអាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំសូមជម្រាបអីចេះថា អង្កាល់នោះគាត់ដែលគេចាប់យកមក ហើយពួកអ្នកធ្វើការនៅកន្លែងហ្នឹងថា ឃើញគាត់តូចអ៊ីចឹងថា គឺថាមិនដែលឃើញមនុស្សអីតូចអ៊ីចឹងមានប្រពន្ធ? ដល់ហើយគាត់ថា គាត់-- ពួកនុ៎ងថា កម្លាំង! ប៉ុណ្ណឹងសោះហើយថាខ្លាំងៗ ហើយពួកនោះសូមថា បើឥឡូវបើខ្លាំងជិះសាកមើល!ៗជិះដល់ហើយ គាត់នែ គាត់លើរួចលើរួចបានឈប់ទៅ ។ ថា ចុម!មនុស្សតូចន៎អីខ្លាំងៗបានតែប៉ុណ្ណឹង ។

**ស៖** តើបានសួរគាត់បានខ្លាំង ឬមិនខ្លាំងទេមុននឹងលោកបានឡើងជិះលើកៗឲ្យឡើងលើជណ្តើរនោះ? តើគាត់បានបង្ហាញថា គាត់ខ្លាំងមុននឹងលោកឡើងជិះដែរឬទេ?

**ឆ៖** ខ្លាំង ។ គាត់ថា សាកមើល! មើល៍បើៗលីមិនរួច អាហ្នឹងខ្ញុំនៅចាំៗគាត់ដែរ ត្រង់ថាទៅវ៉ៃធ្វើទារុណកម្មខ្ញុំអត់មានទេ ហើយខ្លាំងអ៊ីចឹងមែន ហើយពួកនុ៎ងនាំគ្នាសើចគ្រប់គ្នា ចុម! មនុស្សតូចសោះហើយខ្លាំងអីខ្លាំង ។ ចុះគាត់កាលនុ៎ងគាត់នៅពេញកម្លាំងគាត់ដែរ ។ បានតែប៉ុណ្ណឹងគាត់ ហើយគាត់នៅនិយាយជាមួយខ្ញុំនៅពេលដែលជួបគ្នាគាត់ហ្នឹងគាត់និយាយអ៊ីចឹងដែរ ។

[១១:២៣:១៤]

**ស៖** សំណួរ ខ្ញុំត្រឡប់មកសំណួរពីខាងដើមម្តងទៀត ។ តើលោកគិតថា លោក ប៊ូ ម៉េង កុហកទេ? ដែលគាត់និយាយថា លោកធ្លាប់បានវាយគាត់នោះ?

**ឆ៖** ខ្ញុំអត់ដែលបានទៅវ៉ៃទៅអីទេ ព្រោះខ្ញុំអត់មានសិទ្ធិមានអំណាចអីវ៉ៃនៅកន្លែងហ្នឹងទេ ។ ព្រោះតែវ៉ៃអ្នកទោស គឺយើងត្រូវតែទទួលកន្លែងហ្នឹងមានតែអ្នកសួរចម្លើយទេ យកទៅសួរចម្លើយគេមានសិទ្ធិសម្រាប់វ៉ៃយ៉ាងម៉េចៗគឺនៅលើគេ ។ ផ្នែកការពារនិងចាប់បើអ្នកទោសមានសកម្មភាពអីគេឲ្យវ៉ៃ ។

**ស៖** លោក ហ៊ីម ហ៊ុយ គឺថា បើសិនជាលោកអាចឆ្លើយដោយត្រង់ទៅនឹងសំណួរចុងក្រោយមួយ គឺខ្ញុំព្យាយាមជាលើកចុងក្រោយ ។ តើលោកគិតថា លោកមិនដែលធ្វើបាប មិនដែលវាយដំលោក ប៊ូ ម៉េង ហេតុអីបានជាលោក ប៊ូ ម៉េង និយាយអ៊ីចឹង ។ បើអ៊ីចឹងតើលោក ប៊ូ ម៉េង និយាយកុហសពីរឿងហ្នឹង ឬយ៉ាងម៉េច?

**ឆ៖** ខ្ញុំអត់ដឹងដែរ ដល់គាត់និយាយអ៊ីចឹង ។

**លោកស្រី ស៊ីលឃី ស្ទូតហ្សិនស្គី៖**

ខ្ញុំមិនមានសំណួរអ្វីទៀតទេ លោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ មេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី បើមានសំណួរសួរដល់សាក្សីរូបនេះ ។

**សួរដោយលោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរលោក ហ៊ីម ហ៊ុយ ។ សូមអរគុណលោក ហ៊ីម ហ៊ុយ ដែលលោកបានអញ្ជើញមក ។ តាមដែលខ្ញុំយល់ច្បាស់នោះអំពីការពន្យល់ដែលលោកបានផ្តល់ពីអាទិត្យមុននោះ មុខងាររបស់លោកគឺៗនាំអ្នកទោសមក-- ជូនអ្នកទោសទៅដល់មាត់ទ្វារ ស-២១ ហើយនិងយាមខាងក្រៅជុំវិញ ស-២១ ហើយម្តងម្កាលលោកបានគេយកលោកទៅជំនួសបុគ្គលិកខ្លះដែលបានមិននៅស-២១ នៅពេលដែលមានអ្នកទោសច្រើន ។

**ស៖** អ៊ីចឹងសំណួរខ្ញុំសួរថា អ្នកទោសទាំងអស់ក្រៅពីស្ត្រីនោះ តើអ្នកទាំងអស់ហ្នឹង តើគេដោះខោអាវចេញទុកតែខោខ្លីមួយអ៊ីចឹងមែនឬទេ?

[១១:២៦:០៦]

**ឆ៖** ក្នុងកន្លែងគុកហ្នឹងច្បាប់របស់គេអត់ឲ្យអ្នកទោសស្លៀកពាក់ខោអាវទេលោក ។ ឲ្យស្លៀកតែខោខ្លីទេ ។ គេស្រណុកថា ឲ្យអ្នកទោសស្លៀកខោខ្លីរត់រួច គឺគេស្គាល់ ។ ហើយមួយទៀត គេខ្លាចអ្នកទោសមានខោអាវ មានអាវនឹងខ្លួនអាចចងកសម្លាប់ជាមួយហ្នឹងកន្លែងហ្នឹងបាន ។

**ស៖** នៅពេលដែលលោកយកអ្នកទោសទៅឲ្យសួរចម្លើយនៅក្នុងផ្ទះនោះ តើគេស្លៀកខោខ្លី ឬក៏គេស្លៀកមានខោវែងអាវវែងដែរ?

**ឆ៖** ខ្ញុំឃើញគេបណ្តើរយកទៅហ្នឹង គឺមានតែខោខ្លីទេ ។ បើអ្នកខ្លះដូចថា អ្នកធ្វើការនៅកន្លែងហ្នឹងគេយកភួយឃ្លុំជិតឈឹងអត់ឲ្យអ្នកគ្នាឯងហ្នឹងដឹងស្គាល់ទេ ។ ហើយអ្នកដែលពីក្រៅ គឺអ្នកមិនមែនពួកអ្នកធ្វើការហ្នឹង គឺគេបណ្តើរចងមុខធម្មតាស្លៀកខោខ្លីអ៊ីចឹងយកទៅ ។

**ស៖** សូមអរគុណចំពោះចម្លើយដែលលោកបានឆ្លើយទៅនឹងសំណួរខ្ញុំ ។ នៅពេលដែលយកអ្នកទោសទៅឲ្យគេសួរចម្លើយ តើគេស្លៀកពាក់ឬក៏-- តើនៅពេលដែលគេយកទៅសួរចម្លើយថា តើមានតែ

ខោខ្លីឬក៏មានស្លៀកពាក់អ្វីដែរ?

**ឆ៖** ខ្ញុំមិនបានចាំដែរទេ ។ ប៉ុន្តែ ភាគីច្រើនគឺមានតែខោខ្លីហ្នឹងទេ ដែលគេបណ្ដើរយកទៅសួរចម្លើយនោះ ។

**ស៖** នៅពេលដែលលោកនៅក្បែរបន្ទប់សួរចម្លើយនោះ តើលោកបានឮសំឡេងយំថ្ងូរស្រែកជាញឹកញាប់ទេ? នៅពេលដែលគេសួរចម្លើយនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា អ្នកទោសដែលយំស្រែកនោះ គឺពេលដែលគេសួរចម្លើយហើយយកមកកន្លែងគុកហ្នឹង គេធ្វើទារុណកម្មបែកឈាម បែកអីពេញខ្លួនហ្នឹងគឺយំ ។ ស្រែកនៅក្នុងគុកហ្នឹង ត្រង់ថាកន្លែងសួរចម្លើយនោះខ្ញុំអត់ដឹងទេ ព្រោះផ្ទះខ្ញុំនៅឯងផ្លូវត្បូងកន្លែងផ្ទះសំបុកឃ្មុំឯនោះ ។

**ស៖** នៅពេលដែលយកអ្នកទោសត្រឡប់មកវិញក្រោយពីសួរចម្លើយ តើអ្នកទោសហ្នឹងមិនអាចដើរបានទេ នៅពេលដែលថា គេដកក្រចកអីគាត់អ៊ីចឹងហ្នឹង?

**ឆ៖** ខ្ញុំសូមជម្រាបថា រឿងដកក្រចកក៏ខ្ញុំអត់បានដឹងដែរ ។ ប៉ុន្តែ មកឃើញដូចថា អ្នកទោសដែលចងមុខអត់មានយកអីមកឃុំខ្លួន ឃើញបែកឈាមពេលដែលខ្ញុំជួបម្ដងម្កាល ដែលខ្ញុំចូលទៅ ។ ហើយពេលល្ងាចអ៊ីចឹងយកទៅដាក់ក្នុងគុកអ៊ីចឹងឮសួរ ពេលដែលខ្ញុំទៅជួយយាមគេម្ដងម្កាលហ្នឹងឮសួរស្រែកយុំស្រែកអី ក្នុងបន្ទប់ហ្នឹង ។

[១១:៣០:២០]

**ស៖** សូមអរគុណលោក ។ ទាក់ទងទៅនឹងក្មេងៗលោកបាននិយាយថា មានក្មេងៗពីអាយុ១ឆ្នាំទៅដល់៨ឆ្នាំ ដែលនៅជាមួយម្ដាយ ហើយស្ថិតនៅក្នុងមន្ទីរឃុំឃាំងដូចគ្នាជាមួយនឹងម្ដាយ។ ថាតើមានក្មេងដែលមានវ័យ អាយុលើសពី៨ឆ្នាំដែរឬទេ? ហើយពួកគេត្រូវបានឃុំខ្លួនដែរឬទេ?

**ឆ៖** បាទ, គឺតែយកមកឃុំខ្លួនទាំងអស់ហ្នឹង លើសអាយុ៨ឆ្នាំហ្នឹង ក៏ឃុំខ្លួនជាមួយគ្នាហ្នឹងដែរ ។ ដល់ហើយពួក ប៉េង ដល់ ឌុច គេយកថា សរុបប្រមូលយកទៅសម្លាប់ទាំងម្ដាយទាំងឪពុកអ៊ីចឹងហ្នឹងក្មេងៗដូចនៅជាមួយម្ដាយហ្នឹងគេដកយកចេញមុនហើយៗ ។ ពួក ប៉េង យកទៅសម្លាប់ក្រោយគុកទួលស្លែងហ្នឹង ។

**ស៖** ថាតើមានក្រុមក្មេងៗដែលមានអាយុដប់ ដប់ពីរ ឬក៏ដប់បីឆ្នាំដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ខ្ញុំមិនបានពិនិត្យមើលច្បាស់លាស់ទេកន្លែងនុំង ព្រោះទៅម្ដងម្កាលដើរមើលសំខាន់ជាងគេ គឺឲ្យមកដើរមើលអ្នកយាមខ្លាចអ្នកយាមងក់ ។

**ស៖** លោកបានជម្រាបយើងថា នៅពេលដែលមានអ្នកទោសច្រើនមកដល់នោះ ពួកគេត្រូវដាក់ចូលទៅក្នុងបន្ទប់ឃុំតែម្តងដោយមិនថតរូប តាមដែលលោកដឹង ថាតើក្រោយមកអ្នកទាំងអស់នោះត្រូវបានគេថតដែរឬទេ? ឬក៏ពួកគេនោះត្រូវបានយកទៅសម្លាប់ចោលដោយមិនបាច់ថតរូបតែម្តង?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា អ្នកទោសគឺយកចូលមកកន្លែងហ្នឹង គឺថតទាំងអស់ ។

**ស៖** លោកបានជម្រាបយើងថា នៅពេលមួយនោះបន្ទាប់ពីគេចាប់ ហ៊ុយ លោកមានការភ័យខ្លាចគេចាប់លោក នេះលោកនិយាយថា លោកខ្លាចគេចោទថាលោកបានរៀបចំធ្វើការបះបោរដោយប្រើអាវុធ តើលោកអាចជម្រាបទៅលើចំណុចនេះដែរទេ? លោកបាននិយាយចំណុចនេះនៅថ្ងៃព្រហស្បតិ៍អាទិត្យមុន ។

**ឆ៖** បាទ, ខ្ញុំសូមជម្រាប គឺខ្ញុំចាប់ផ្តើមភ័យខ្លួនតាំងពីតាឌុច គាត់និយាយប្រាប់ខ្ញុំពេលរៀនសូត្រគាត់ថា ណុប ងួន ឆ្លើយដាក់ មិត្តហ៊ុយ ឯងថាមិត្តហ៊ុយ ឯងធ្វើការបះបោរ ហើយខ្ញុំក៏សើច ខ្ញុំសើចដើម្បីអី ដើម្បីកុំឲ្យគាត់ថាខ្ញុំអ៊ីចឹង ។ សើចហើយខ្ញុំថា "ខ្ញុំមិនៗធ្វើអ៊ីចឹងទេបង" ។ ក្រោយមកទៀតខ្ញុំភ័យខ្លួនឯងតាំងពីហ្នឹងមករហូតនឹកឃើញថា គេឆ្លើយដាក់ហើយអញចប់សាច់រឿងត្រឹមហ្នឹងហើយ ។ ដល់ក្រោយមកទៀត ខ្ញុំទៅធ្វើការម្តងៗ ខ្ញុំសុំៗតាហ៊ី ដូរកាំភ្លើង សុំកូនសោកាំភ្លើងនៅលើ តាហ៊ី ឃ្លាំងកាំភ្លើង ។ ខ្ញុំសុំដូរកាំភ្លើងរហូត ។ ដល់ក្រោយមកចាប់ន៉ែ ចាប់ តាប៉ាង មួយទៀតៗក៏ខ្ញុំចាប់ផ្តើមភ័យខ្លួនទៀតហើយ ។ អ៊ីចឹងឆ្លើយដាក់ តាហ៊ី វាកាន់ឆាប់នឹងគេចាប់ខ្លួនទៀតហើយ ខំប្រាប់ តាហ៊ី ទៀតថាបងៗ តាប៉ាង ឆ្លើយដាក់បងឯងហើយប្រយ័ត្នណ៎ា ប្រយ័ត្នគេចាប់បងឯង ។ អាហ្នឹងរឿងមួយ ចុះដល់ខ្ញុំកាន់តែភ័យបន្តទៀត ។

ហើយរឿងមួយទៀតខ្ញុំការពារ បងចឹក នុំងទុក មិនការពារសុំថា "កុំយកគាត់ទៅឲ្យធ្វើស្រែបងអើយ ឲ្យគាត់នៅហ្នឹងសិន ព្រោះខ្ញុំអត់ទាន់បានកសាងគាត់ផង" តាមការពិតខ្ញុំមិនចង់ឲ្យគាត់ទៅឲ្យនៅជាមួយខ្ញុំ ។ ដល់ហើយ បងចឹក នោះក៏ចង់កស្លាប់ទៀត ខ្ញុំកាន់តែ-- បន្ទុកកាន់តែច្រើនឡើងហើយអ៊ីចឹងកាន់តែភ័យ ។ ដល់ពេលឲ្យខ្ញុំទៅធ្វើស្រែ ចាប់ បងហ៊ុយ ទៀត ចាប់បង ហ៊ុយ អើ!ទៀតហើយតែចាប់បង ហ៊ុយ គឺៗដល់ខ្លួនឯងហើយ ត្រូវតែគេចាប់ទៀតហើយ ចាប់ទាំងខ្សែ៧០៣ ទាំងអស់ ។

[១១:៣៥:០១]

**ស៖** តើលោកធ្លាប់ឃើញមនុស្សដែលលោកស្គាល់ចូលមកដល់ស-២១ ដែរឬទេ តើលោកគិតយ៉ាងម៉េច បើសិនជាពួកគេមកដល់នោះ?

**ឆ៖** បាទ, ខ្ញុំឃើញអ្នកដែលធ្លាប់ស្គាល់គ្នាចូលមក គឺខ្ញុំភ័យណាស់ ដូចនៅ៧០៣ ចូលមកនឹកឃើញថា គេនឹងឆ្លើយដាក់ពួកខ្ញុំហើយ ព្រោះពួកខ្ញុំចេញពី៧០៣មក វាជាខ្សែជាមួយគ្នា ។ អ៊ីចឹង តែមកដល់នេះគេនឹងធ្វើការឆ្លើយដាក់ពួកខ្ញុំបន្តទៀត ។

**ស៖** លោកបានដឹងថា មន្ទីរសន្តិសុខស-២១ ជាមន្ទីរសម្ងាត់ ថាតើលោកនិយាយ អាចនិយាយទេ ថាមន្ទីរនោះជាមន្ទីរនយោបាយផងដែរ?

**ឆ៖** បាទ, កន្លែងដែលរៀនសូត្រហ្នឹង គឺមិនមែនកន្លែងសម្ងាត់ទេគឺរៀនជាសាធា តាំងពីពួកព្រៃសអីមក ពួកការពារ ពួកសួរចម្លើយ រៀនជាមួយគ្នាទាំងអស់នៅកន្លែងហ្នឹង ហើយកន្លែងសម្ងាត់ណាទៀតខ្ញុំអត់ដឹងទេ ។

**ស៖** តើលោកអាចនិយាយទេថា មន្ទីរស-២១ នេះជាគុក ឬក៏ជាទីកន្លែងដែលគេយកមកឃុំខ្លួនធ្វើទារុណកម្ម ហើយសម្លាប់ចោល?

**ឆ៖** បាទ,កន្លែងនេះគុកក៏គុក ហើយកន្លែងទារុណកម្មសម្លាប់ក៏កន្លែងទារុណកម្មសម្លាប់ដែរ ។

[១១:៣៦:៥៦]

**ស៖** មុនពេលដែលខ្ញុំផ្តល់វេទិកាទៅជូនសហសេវិករបស់ខ្ញុំ ។ នៅក្នុងឆ្នាំ១៩៨៣ ហេតុអ្វីបានជាគេគិតថាលោកជាប្រធានស-២១?

**ឆ៖** បាទ, ខ្ញុំអត់ដឹងដែរ ដល់គេចាប់ខ្ញុំ ហើយថាខ្ញុំប្រធានគុក ខ្ញុំថាហ្អីប្រធានគុកអីបើប្រធានគុកអត់រត់ពីព្រៃចូលមកទេ ព្រោះខ្ញុំមិនមែនប្រធានផង ហើយមួយទៀតខ្ញុំមិនសុំគេចូលទៅហ្នឹងផង ។ ហើយគេយកខ្ញុំចូលទៅ ដល់ពេលសុំគេចេញវិញ គេមិនឲ្យខ្ញុំចេញផង បើខ្ញុំចេញវិញទៅទ័ពវិញខ្ញុំសុខចិត្តងាប់ ខ្ញុំមិនទៅនៅកន្លែងហ្នឹង កន្លែងហ្នឹងឆាប់ងាប់ ។ អ៊ីចឹងបានខ្ញុំ គេយកដាក់ឃុំឃាំងក៏ខ្ញុំនៅ ខ្ញុំអត់រត់ទេ នៅហ្នឹងរហូតដល់តែលែងធ្វើអីណាទៅ ទៅកាប់ខសក៏ទៅកាប់ខស លីខសក៏ទៅលី ទៅធ្វើស្រូវក៏ខ្ញុំ ទៅធ្វើស្រូវ ឲ្យខ្ញុំទៅផ្ទះថ្ងៃណាខ្ញុំទៅផ្ទះថ្មើហ្នឹង រឿងរត់ចេញពីហ្នឹងអត់រត់ ។

**សួរដោយលោក គីម ម៉េងឃី៖**

សូមគោរព លោក លោកស្រីចៅក្រម! ជម្រាបសួរលោក ហ៊ឹម ហ៊ុយ ។ បន្តសំណួរពីសហមេធាវីអន្តរជាតិ ខ្ញុំសុំសួរលោកមួយពាក់ព័ន្ធទៅនឹងលោកនិយាយថា ពាក្យថាច្បាប់តឹងរ៉ឹង ។

**ស៖** តើច្បាប់តឹងរឹងហ្នឹង មានន័យថាយ៉ាងម៉េច? ហើយអ្នកណាជាអ្នកចែងច្បាប់តឹងរឹងហ្នឹង?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប ដែលខ្ញុំនៅសន្តិសុខស-២១ ហ្នឹងគឺច្បាប់គេតឹងតែងណាស់ ។ គ្មាននរណាចែងទេ មានតែតា ឌុច អ្នកចែងច្បាប់ហ្នឹង ។ ថ្នាក់ប្រហែលតា ហ៊ី មិនអាចធ្វើអ៊ីចឹងបានទេ មានតាឌុច ។

**ស៖** តើច្បាប់ហ្នឹងមានរៀបរាប់ពីអ្វីខ្លះនៅក្នុងហ្នឹង ដែលលោកចង់និយាយហ្នឹង?

**ឆ៖** ច្បាប់គេនិយាយថា យើងជាកូនចៅរបស់អង្គការ យើងជាកូនរបស់បក្ស មិនមែនកូនរបស់ម៉ែឪយើងទេ ។ យើងមកធ្វើការ យើងត្រូវគោរពអង្គការ តាំងពីដើរហើរ ស៊ីដេក ធ្វើយ៉ាងម៉េចគោរព អង្គការវិន័យឲ្យបាន អ្នកណាគោរពមិនបាន អ្នកហ្នឹងជាខ្មាំងរបស់បក្ស ។ បើធ្វើឲ្យអ្នកទោសរួចគឺអ្នកហ្នឹង គឺត្រូវតែជាប់គុក ។ អាហ្នឹងច្បាប់របស់គេ គេធ្វើអ៊ីចឹង ។

**ស៖** សូមអរគុណ។ ពាក់ព័ន្ធទៅនឹងការរៀនសូត្រ លោកថាបានចូលរួមរៀនសូត្រជាញឹកញាប់ តើមនោគមន៍វិជ្ជាអ្វីខ្លះពាក់ព័ន្ធទៅនឹងការចាប់ខ្លួន ការឃុំខ្លួនអ្នកទោស ឬក៏ការបញ្ជូនអ្នកទោសដែលគេបណ្តុះបណ្តាលទៅដល់លោក?

[១១:៤០:០៣]

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ការរៀនសូត្រនេះ គឺគេរៀនសូត្រទាំងអ្នកសួរ ទាំងអ្នកការពារ ធ្វើម៉េចឲ្យការពារឲ្យបាន ធ្វើម៉េចសួរចម្លើយឲ្យបាន អ្នកណាសួរចម្លើយមិនបាន ការពារមិនបាន អ្នកហ្នឹងគឺថាមិនគោរពផែនការមួយរយភាគរយរបស់បក្សទេ ។ អ៊ីចឹង ម្នាក់ៗគេធ្វើឲ្យទាល់តែត្រង់ភ្លឹងហ្នឹង ហើយឲ្យ-- មុនដំបូងអត់ទាន់តឹងតែងទេ នៅនិយាយគ្នាលេងបាន ។ ក្រោយមកទៀត ដាក់វិន័យមួយតឹងតែង គឺអ្នកតាមដានម្នាក់ កម្មាភិបាលតាមដានយុទ្ធជនរាយការណ៍ យុទ្ធជនតាមដានកម្មាភិបាលរាយការណ៍ឲ្យថ្នាក់លើទាំងអស់ ។ អ៊ីចឹង ដល់អ៊ីចឹងដូចៗសេះគេដាក់ស្នឹបាំងមុខកុំឲ្យៗមើលចំហៀងកើតទៀត ។ លែងទុកចិត្តគ្នាទាំងអស់ លែងទុកចិត្តអ្នកណា អ្នកណាក៏លែងទុកចិត្តអ្នកណាដែរ ។

**ស៖** តើលោកអាចបញ្ជាក់បានទេចំពោះជោគវាសនារបស់បុគ្គលិកមន្ទីរស-២១ទាំងឡាយដែលមិនគោរពទៅតាមច្បាប់ និងមនោគមន៍វិជ្ជាដែលៗគេដាក់ឲ្យនោះ តើជោគវាសនារបស់ពួកគាត់នឹងយ៉ាងម៉េចទៅ? ហើយលោកអាចរៀបរាប់អំពីអ្នកទាំងអស់នោះបានទេ?

**ឆ៖** បាទ, ខ្ញុំដឹងច្បាស់ណាស់ ជោគវាសនានៃអ្នកធ្វើការនៅកន្លែងហ្នឹង គឺរង់ចាំតែថ្ងៃស្លាប់ទាំងអស់គ្នាតែម្តង ហ្នឹងជាទីបញ្ចប់របស់ពួកខ្ញុំ ។

**សៈ** តើជាទូទៅ នៅក្នុងការដាក់ ការប្រើច្បាប់ចំពោះបុគ្គលិកស-២១ ហ្នឹង តើគេមានវិភាគអំពីទង្វើច្បាស់លាស់ទេ ឬក៏គេគ្រាន់តែយកទទួលតែពីការឆ្លើយដាក់របស់អ្នកដទៃ ដែលដាក់ចំពោះបុគ្គលិកដែលថាមានកំហុសហ្នឹង?

**ឆៈ** បាទ, ខ្ញុំសូមជម្រាបថា ម្នាក់ៗទោះបីឆ្លើយមិនឆ្លើយ ពាក់ព័ន្ធយ៉ាងម៉េចៗ គឺច្បាប់របស់គេចាប់ដាក់គុកទាំងអស់ហ្នឹង ។ គេគ្មានពិចារណាពីបញ្ហាអីមួយទេ បើគេនិយាយថា ចាប់ជាខ្សែចង្វាក់ខុសអីបន្តិចបន្តួចក៏ចាប់ដែរ ។

**សៈ** សូមលោកបញ្ជាក់បន្តិចមើល ថាតើចាប់ជាខ្សែចង្វាក់ហ្នឹងមានន័យថាម៉េច? មានន័យថាចាប់ពីមេដល់កូន ឬក៏ចាប់អ្នកដែលគេឆ្លើយដាក់?

**ឆៈ** បាទ, ខ្ញុំសូមជម្រាបថា គេនិយាយថាចាប់ជាខ្សែៗ ហើយអ៊ីចឹងពួកខ្ញុំដូចថា ខ្សែពី៧០៣អ៊ីចឹងមកមកធ្វើការ ខាង៧០៣ចូលមកឆ្លើយដាក់ពួកខ្ញុំ ដល់ពេលចាប់ពួកខ្ញុំនេះ ពួកខ្ញុំឆ្លើយដាក់ពួកគ្នាឯងហ្នឹង ចាប់អាគ្នាឯងហ្នឹងទៀត ។

**សៈ** សូមអរគុណ ។ សំណួរចុងក្រោយពាក់ព័ន្ធទៅនឹងការធ្វើសក្ខីកម្មរបស់លោក តើអ្វីៗទៅដែលលោករំពឹងអំពីការធ្វើសក្ខីកម្មនៅថ្ងៃនេះអំពីអង្គជំនុំជម្រះ?

**ឆៈ** បាទ, ខ្ញុំសូមជម្រាបថា ពួកខ្ញុំដូចជាបានកើតមកវិញអ៊ីចឹង អ្នកដែលបានរស់ប៉ុន្មានគឺសំណាងហើយ ចង់បានតែយុត្តិធម៌ទេ ព្រោះស្លាប់ៗដល់ហើយ មនុស្ស ។

[១១:៤៤:៣២]

**ប្រធានអង្គជំនុំៈ**

ជាកិច្ចបន្ត សូមប្រគល់វេទិកាទៅមេធាវី អ្នកតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណីក្រុមបួន ប្រសិនបើមានសំណួរត្រូវសួរដល់សាក្សីរូបនេះ សូមអញ្ជើញ ។

[១១:៤៤:៥៥]

**សួរដោយលោក ហុង គឹមសួនៈ**

សូមអរគុណលោកប្រធាន ។ ជាដំបូងខ្ញុំបាទសូមគោរពលោកប្រធាន លោកស្រី លោកចៅក្រម និងអង្គសវនាការនៃ អ.វ.ត.ក ជាទីគោរព ។ សូមជម្រាបសួរលោក ហ៊ីម ហ៊ុយ! សូមចាំស្ដាប់សំណួររបស់ខ្ញុំ ដែលសួរទាក់ទងជាមួយនឹងប្រវត្តិ ទាក់ទិននៅមន្ទីរស-២១ ដែលលោកធ្វើការនៅទីនោះតទៅនេះ ។

**សៈ** ពីថ្ងៃដំបូងលោកបានជម្រាបជូនលោកប្រធាន ក៏ដូចអង្គសវនាការអំពីការងាររបស់លោក មុនចូលមកដល់ទីក្រុងភ្នំពេញ គឺថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ សំណួររបស់ខ្ញុំកន្លែងនេះចង់សួរថា នៅថ្ងៃនោះគឺថ្ងៃ១៧ មេសា ១៩៧៥ អង្គភាព ឬកងទ័ពដែលលោកចូលមកនោះ ដល់ក្រុងភ្នំពេញតែម្តងទេ? ហើយបើដល់នៅចំណុចណា?

**ឆៈ** បាទ, ខ្ញុំជម្រាប! គឺខ្ញុំមកដល់ក្រុងភ្នំពេញ ដល់ចំណុចកន្លែងសាលាយុគន្ធរ កន្លែងពេទ្យចិនហ្នឹង ពេលហ្នឹងហើយ ពេលល្ងាចប្រហែលជាម៉ោងបី គឺខ្ញុំឱ្យខាង លន់ នល់ យកកាំភ្លើង យកឡានដឹកកាំភ្លើងយកអស់ ។ ដល់ពេលល្ងាចម៉ោងប្រហែលជាប្រាំមួយជាង ក៏ខ្ញុំបានត្រូវគ្រាប់តែម្តងទៅ ។

**សៈ** សូមអរគុណ ។ សំណួរបន្តទៅទៀត សួរថា ថ្ងៃដែលលោកថា ប្រមូលកាំភ្លើងពីពួកលោក លន់ នល់ តើមានការបង្គាប់បញ្ជាមុនទេ មុនដែលពេលចូលមកដល់នឹងអនុវត្តការងារនេះ? ហើយបើមានអ្នកណាអ្នកបង្គាប់បញ្ជា?

**ឆៈ** បាទ, ខ្ញុំសូមជម្រាបថា តាហ៊ី មួយអនុប្រធានរបស់ តាឌុច ហ្នឹង ជាកងវរៈរបស់ខ្ញុំ។ ពួកខ្ញុំមានបីក្រុម ដើរជាមួយពួកគាត់ហ្នឹង ដល់ពេលថ្ងៃៗដូចថា មេៗគេចាប់បានខាងមេ លន់ នល់ គេឱ្យដើរប្រកាស ជិះឡានប្រកាសឱ្យទាហានទម្លាក់អាវុធអស់ៗ ដល់ហើយក៏ស្ងាត់ទៅៗ គរពេញតាមផ្លូវជាតិទាំងអស់ ដល់ហើយ តាហ៊ី ប្រាប់ខ្ញុំថា “ហ៊ុយ ឯងទៅប្រាប់ខាង លន់ នល់ ខាងទាហាន លន់ នល់ នៅកន្លែងសាលារៀន យុគន្ធរ” ។ ខ្ញុំដើរទៅម្នាក់ឯង ស្ពាយកាំភ្លើងដើរទៅម្នាក់ឯង ខ្ញុំប្រាប់-- ខ្ញុំចូលទៅខ្ញុំថា”បងៗខាងបង ណាទទួលខុសត្រូវ?” គាត់ថា “ខ្ញុំអ្នកទទួលខុសត្រូវ” “ឥឡូវបងយកឡាន ទៅប្រមូលតាមផ្លូវជាតិទាំងអស់ទាំងប្អូនជ្រុងហ្នឹងយកទៅ” ។ ខ្ញុំក៏ប្រាប់អ៊ីចឹង ក៏ខ្ញុំដើរចេញវិញមក ហើយនៅអង្គុយអាខាងជើងផ្លូវសាលាយុគន្ធរហ្នឹង បីក្រុមនៅហ្នឹង ។

[១១:៤៨:00]

**សៈ** សូមអរគុណ ។ សុំសួរសំណួរហ្នឹងឡើងវិញបន្តិចក្រែងលោកស្តាប់មិនទាន់ ឬមិនច្បាស់។ សំណួរខ្ញុំសួរថា មុនអនុវត្តការប្រមូលកាំភ្លើង ឬក៏ការដើរប្រាប់មេៗនៃរបបលោក លន់ នល់ ក៏ដោយនោះ ។ ចង់និយាយថា មុនពេលចូលនោះ តើមានមេឈ្មោះអ្វី ឬអ្នកណាដែលប្រជុំឬបង្គាប់ថា ពេលចូលទៅដល់ហ្នឹង ត្រូវធ្វើអី? ដូចប្រមូលកាំភ្លើង ចាប់មនុស្ស ជម្លៀសមនុស្ស អ្នកណារឹងទទឹងបាញ់ឧទាហរណ៍អ៊ីចឹង ។ តើអ្នកណាអ្នកបង្គាប់ ឬឱ្យដំបូន្មានមកលោក?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលដែលខ្ញុំចូលមក គឺខ្ញុំអត់បានដេញប្រជាជនឲ្យថយចេញទេ ចេះចូលៗមក ចូលរហូត ហើយក៏គ្មានបាញ់គ្រាប់បាញ់អីដែរ បាញ់ត្រឹមតែកន្លែងស្ទឹងនឹងបាញ់គ្នា ។ ដល់ពេលហើយមកខាង លន់ នល់ ក៏ចុះចាញ់ទៅ រត់ទៅ ក៏ពួកខ្ញុំចេះតែចូលៗមកៗ ដល់កន្លែងពេទ្យចិន កន្លែងសាលាយុគន្ធរតែម្ដងទៅ ។

**ស៖** អរគុណ ។ អ៊ីចឹងមានន័យថា លោកមិនបានដឹងអំពីផែនការណ៍ជាមុនទេ ឬយ៉ាងម៉េច?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប ដូចខ្ញុំចាប់បានឡានពីរគ្រឿង ដែលមានកាំភ្លើងធំ១៥៥នុ៎ង ក៏ខ្ញុំក៏អត់មានទៅធ្វើបាបគាត់ អីស័ក្តិ៥ ហ្នឹងដែរ នៅក្រាបយន្តហោះអីជាមួយគ្នាហ្នឹង ។ ហើយខ្ញុំគាត់ថា ទុកឡានហ្នឹងចោលហ្នឹងទៅ ហើយផ្ទះសម្បែងណាទៅហ្នឹងទៅ ។ ខ្ញុំមិនដឹងផែនការគេធ្វើយ៉ាងម៉េចៗ ខ្ញុំអត់ដឹងទេ ដូចមកដល់កន្លែងនេះអ៊ីចឹង កន្លែងសាលាយុគន្ធរហ្នឹង ខំតែប្រាប់ខាង លន់ នល់ ឲ្យយកកាំភ្លើងទៅ ខ្ញុំមិនដឹងថាគេមានផែនការអីគេ ក៏ខ្ញុំអត់ដឹង ។

**ស៖** ខ្ញុំសូមអរគុណ ។ សំណួរខ្ញុំសួរបន្តទៅទៀត ពីដំបូងលោកបានជម្រាបជូនលោកប្រធាន និងអង្គសវនាការអំពីការងាររបស់លោកដែលចូលមកដល់ហើយ គេឲ្យទៅកាប់ដីដាំដំណាំជាដើមនោះ។ សំណួរខ្ញុំសួរថា តាំងពីមេរបស់លោកបញ្ជូនលោកចូលមកធ្វើការនៅមន្ទីរស-២១ភ្នំពេញ ហើយឈរជើងនៅចំណុចមួយ ដែលជាកន្លែងទទួលអ្នកទោស ដែលសព្វថ្ងៃហៅថា ប៉ុស្តិ៍វិទ្យុសំបុកឃ្មុំនេះ តើការងារនៅចំណុចប៉ុស្តិ៍វិទ្យុសំបុកឃ្មុំរបស់លោកនោះ មានមនុស្សប៉ុន្មាននាក់? ហើយអាយុក្នុងចន្លោះណាជាសមាជិកនៃក្រុមរបស់លោក?

**ឆ៖** បាទ, គឺនៅក្រុមរបស់ខ្ញុំ ចំនួនគ្នា បួនដប់នាក់ទាំងជាងឡាន ជាងអីនៅជាមួយនៅខ្ញុំហ្នឹង អ្នកបើកឡាននៅជាមួយខ្ញុំ ។ អ្នកកាន់តេអ្វូ ក៏គេនៅកាន់តេអ្វូយូរយាំងដែរ ក៏នៅជាមួយខ្ញុំដែរ ដល់ខ្ញុំទៅនៅក្រោយនៅជាមួយគ្នាហ្នឹងទៅ ។ ហើយអ្នកដែលមានអាយុដែលនៅជាមួយខ្ញុំខ្លះ គេបងខ្ញុំបួនប្រាំឆ្នាំនៅជាមួយខ្ញុំ ។ ខ្លះក៏ប្អូនខ្ញុំពីរបីឆ្នាំអ៊ីចឹងនៅជាមួយគ្នាហ្នឹង ។

**ស៖** សូមអរគុណ ។ សំណួរជាបន្តទៅទៀត លោកបានជម្រាបលោកប្រធាន និងអង្គសវនាការអំពីពាក្យពេចន៍ស្មើរតែញឹកញាប់ទៅហើយថា មេដែលមានអំណាច និងអ្នកបង្គាប់បញ្ជា គឺលោក ឌុច នៅក្នុងមន្ទីរស-២១ភ្នំពេញនេះ ហើយខ្ញុំសួរថា មុនពេលដែលលោកទទួលអ្នកទោសដែលគេបញ្ជូនមកដល់ចំណុចទទួលអ្នកទោសនៃប៉ុស្តិ៍វិទ្យុសំបុកឃ្មុំសព្វថ្ងៃនេះ លោកថា មាននីរសារគេឲ្យព័ត៏មានមកមុន ឬអ្នកខាងក្រៅគេទៅប្រាប់មុន ។ អំមិញនេះ ខ្ញុំគ្រាន់តែសួរបញ្ជាក់កន្លែងអំមិញថា ការបែងចែកមនុស្ស

ទៅខាងព្រៃសផ្សេង ចូលមកក្នុងមន្ទីរស-២១ភ្នំពេញផ្សេង ខ្ញុំឮសួរពីរហ្នឹង ។ តើការបែងចែកទៅតាមផ្ទះដែលជាកន្លែងឃុំពិសេសនៅជុំវិញមន្ទីរ ស-២១ ភ្នំពេញនេះ សម្រេចនៅកន្លែងលោកដែរឬទេ? ហើយអ្នកណាជាអ្នកសម្រេច?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា មុនដែលគេបញ្ជូនមក គឺគេមាន១ឈ្មោះរបស់គេមកហើយ១ ។ អ្នកណាដែលគេបញ្ជូនមក ដូចថាសំខាន់ គេយកមកចូលមកកន្លែងហ្នឹង ហើយអ្នកមិនសំខាន់ គឺឡានគេនៅក្រៅឯណោះ១ ហើយគេនឹងបញ្ជូនទៅព្រោះឈ្មោះមានទាំងអស់ហើយ គេនឹងបញ្ជូនអ្នកណាដែលមិនសំខាន់យកទៅព្រៃសទៅធ្វើស្រែ ហើយអ្នកសំខាន់គេបញ្ជូលមកខាងនេះ ហើយបញ្ជូនចូលទៅក្នុងឱ្យគេ ។

[១១:៥៣:០៣]

**ស៖** អរគុណ ។ លោកបានជម្រាបអង្គសវនាការអំពីថា មានពេលខ្លះលោកបានជូន ឬក៏នាំអ្នកទោសចូលទៅដល់ក្នុងបរិវេណនៃមន្ទីរស-២១ ឬដែលយើងហៅឱ្យចំឈ្មោះពីដើមដូចលោក ឌុច ថា វិទ្យាល័យពញាយ៉ាតនោះ តើលោកបានឃើញ ឬបានដើរទៅឃើញខាងក្រោយនៃអគារក្នុងវិទ្យាល័យពញាយ៉ាតឬទេ? ថាតើមានកន្លែងដាំបាយ កន្លែងរោងជាងឈើ ជាងដែកជាដើម លោកបានទៅដល់នោះដែរឬទេ?

**ឆ៖** បាទ, គឺខ្ញុំបានទៅកន្លែងខាងក្រោយហ្នឹង ។

**ស៖** សូមអរគុណ ។ តើនៅកន្លែងនោះ បើក្នុងអង្គសវនាការយើងសូមជម្រាបឡើងវិញ ដែលគេថា នៅខាងលិច ឬខាងក្រោយនៃវិទ្យាល័យពញាយ៉ាតនោះ គឺជាសាលាបឋមសិក្សាទួលស្វែង ដែលរបបលោក លន់ នល់ ដាក់ឈ្មោះអ៊ីចឹង ។ នៅក្នុងនោះ មានកន្លែងសួរចម្លើយ ឬកន្លែងឃុំមនុស្សដែរឬទេ?

[១១:៥៤:២៥]

**ឆ៖** បាទ, កន្លែងហ្នឹង អត់មានទេ ខ្ញុំចាំមិនច្បាស់ទេកន្លែងហ្នឹង ប្រហែលគេធ្វើកន្លែងពេទ្យរបស់គេហើយកន្លែងហ្នឹង ។

**ស៖** សូមអរគុណ ។ នៅក្នុងការងារក្នុងមន្ទីរស-២១ ឬក៏អតីតវិទ្យាល័យពញាយ៉ាតនេះ លោកថា លោក ឌុច ជាប្រធានធំជាងគេ បន្ទាប់មកឈ្មោះ ហ៊ី ហើយមួយទៀតឈ្មោះ ហ៊ុយ ដែរប៉ុន្តែ ហ៊ុយ ស្រែ អ៊ីចឹងមែនទេ? នេះសូមបញ្ជាក់បន្តិច ។

**ឆ៖** បាទ, ស-២១ គឺ តាឌុច ប្រធានធំជាងគេ បន្ទាប់មកបង ហ៊ី ខ្វាក់ភ្នែកម្ខាង ហើយបានបង ហ៊ុយ សមាជិកនៅធ្វើស្រែព្រៃសហ្វ៊ីង ។

**ស៖** អ៊ីចឹងខ្ញុំសូមសួរលោកទាក់ទងជាមួយនឹងចម្លើយ ដែលលោកឆ្លើយជាមួយលោកសហចៅក្រមស៊ើបសួរ ឬក៏សហចៅក្រមស៊ើបអង្កេតកាលពីថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០០៧ វេលាម៉ោងប្រាំបួនព្រឹក ដែលមានឯកសារលេខ D19/V នៅក្នុងទំព័រ ១, ២, ៣, ៤, ៥ ទំព័រទី៥ ជាភាសាខ្មែរ ។ ខ្ញុំសូមអានបន្តិចនៅក្នុងបន្ទាត់លើគេ ក្នុងនេះលោកចៅក្រមស៊ើបអង្កេតសួរថា “ឌុច និង ហ៊ី ត្រូវគ្នាទេ?” មិនដាក់ពាក្យ “ទេ” ទេ គ្រាន់តែដាក់សញ្ញាសួរ មានន័យអ៊ីចឹង ។ ហើយលោកបានឆ្លើយថា “ឌុច មកមុន ហ៊ី មកក្រោយ មានអ្នកមកពី៧០៣ គាត់មានឈ្មោះគ្នាបីដង ។ ហ៊ី ប្រាប់ខ្ញុំថា ឌុច ប្រកាន់បក្ខពួក ។ ឌុច កាន់បស្ចិម ហ៊ី ខាង៧០៣ ភូមិភាគពិសេស ។ ចាន់ ប្រាប់ខ្ញុំថា ឌុច យកកុមារមកពីបស្ចិមទុកជាបង្អែកថ្ងៃក្រោយ ហើយមានការចាប់ខាង៧០៣ បើអ្នកទោសឆ្លើយដាក់៧០៣ នោះ ឌុច ឲ្យគេចាប់សួររួចសម្លាប់ចំណែកខាងបស្ចិមពុំមានទេ ។ នេះគឺមានបញ្ហាពី ឌុច នៅកន្លែងនេះមានតែ ឌុច ជាអ្នកសម្រេច ។ ខ្ញុំមើលឃើញថា ក្នុងគុកនេះ ឌុច អ្នកសម្រេច ហ៊ី មិនប៉ានថាអ្វីទេ” ។ អ៊ីចឹងសំណួររបស់ខ្ញុំសួរថា ដែលលោកបានថ្លែងសក្ខីកម្មជូនលោកចៅក្រមស៊ើបអង្កេតនេះ តើការអះអាងនោះនៅពិតដដែលឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាប គឺជារឿងពិត ពិតប្រាកដអ៊ីចឹងមែន ។

**ស៖** សូមអរគុណ ។ ទាក់ទងនឹងឯកសារចម្លើយជាមួយនឹងសហចៅក្រមស៊ើបអង្កេតផងដែរ លេខឯកសារ D19/VI ជាភាសាខ្មែរ ដែលលោកឆ្លើយកាលពីថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ វេលាម៉ោងប្រាំបួនព្រឹក ។ ឯកសារភាសាខ្មែរនេះ នៅទំព័រទី៥ នៃសំណួរមួយដែលទាក់ទងនឹងការយកអ្នកទោសទៅសម្លាប់ ។ ខ្ញុំសូមអនុញ្ញាតលោកប្រធានអានឲ្យគាត់ស្ដាប់បន្តិច ខ្ញុំអត់បានជូនផ្ទាល់ តែយើងអានតែពីរបីបន្ទាត់ទេ ។ លោកចៅក្រមស៊ើបអង្កេតបានសួរលោក “ទាក់ទងយកអ្នកទោសសម្លាប់ តើទាហានវៀតណាមគេយកមកទុកយូរបានយកទៅសម្លាប់ឬយ៉ាងណា?” ហើយលោកឆ្លើយថា “គេទុកប្រហែលកន្លះខែ សួរចម្លើយរួចបានយកទៅសម្លាប់ ។ សម្លាប់ផ្ដុំក្រោយគុកទួលស្លែង ។ ក្រុមដែលសម្លាប់នោះ គឺក្រុម ប៉េង និងក្រុមខ្ញុំ ។ ខ្ញុំមិនបានដឹងថា អ្នកទោសដែលមិនបានសួរចម្លើយរួចយកទៅសម្លាប់ទេ” ។

ចំណុចត្រង់នេះទាក់ទងជាមួយនឹងសំណួរលោកមេធាវី អាឡាំង វែនណឺ អម្បាញ់មិញជាមួយ

កូនក្មេង ដែលកញ្ញាមេធាវី ទី ស្រ៊ីនណា គាត់សួរថា ទាក់ទងនឹងការសម្លាប់ច្រើនមានកុមារជាច្រើននោះ អ៊ីចឹងតើលោកបានដឹងទេពេលដែលយកកុមារទៅសម្លាប់នោះចម្លោះកុមារពីអាយុប៉ុន្មាន ទៅអាយុប៉ុន្មាន ដែលត្រូវបានសម្លាប់ ហើយកប់សាកសពនៅក្នុងបរិវេណនៃស-២១ ឬក៏យើងហៅថា មន្ទីរទួលស្លែង សព្វថ្ងៃនេះ?

[១១:៥៩:៤០]

**ឆ៖** បាទ, កុមារដែលគេយកទៅសម្លាប់ហ្នឹង គឺគេសម្លាប់នៅខាងលិចគុកទួលស្លែងតែម្តង ។

**ស៖** លោកដឹងទេអាយុប្រហែលប៉ុនណាទៅប៉ុនណា?

**ឆ៖** ប្រហែលពីអាយុមួយឆ្នាំឡើងទៅ ដែលជាកុមារហ្នឹង ។

**ស៖** សូមអរគុណ ។ សំណួរខ្ញុំសួរទាក់ទងជាមួយនឹងខាងចំណុចជើងឯក ដែលជាកន្លែងប្រល័យជីវិតអ្នកទោស។ នៅក្នុងចម្លើយរបស់លោកពីមុនមក ខ្ញុំគ្រាន់តែសង្ខេបថា លោកជាកងការពារផង និងដឹកជញ្ជូនអ្នកទោសទៅជើងឯក ដើម្បីផ្តល់អ្នកទោសទាំងនោះទៅក្រុមអ្នកសម្លាប់ផ្សេងទៀត ។ សំណួរខ្ញុំសួរថា កាលដែលលោកឆ្លើយបំភ្លឺនៅមុខសហចៅក្រមស៊ើបអង្កេតថា មានពេលខ្លះលោក ឌុច បានទៅមើលការសម្លាប់នោះ តើមកដល់ពេលនេះលោកនៅទទួលថា ជាសម្តីពិតដែរឬទេ?

**ឆ៖** បាទ, គឺជាការពិត ។

**ស៖** សូមអរគុណ ។ សំណួរខ្ញុំសួរបន្តទៅទៀត ។ នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ១៩៨០ វេលាម៉ោងប្រាំបួនព្រឹក លោក ហ៊ឹម ហ៊ុយ បានឆ្លើយជាមួយនឹងគណៈកម្មាធិការស្រុកនៅក្នុងជំនាន់រដ្ឋកម្ពុជា ។ ឯកសារលេខ D61/I នៅក្នុងអក្សរខ្មែរទំព័រទី៣ ដែលមានលេខ ERN 00280082 នៅក្នុងបន្ទាត់ចុងក្រោយខាងក្រោម (សុំទោស) បើរាប់ពីក្រោមទៅបន្ទាត់ទីពីរ រាប់ពីក្រោមឡើងទៅលើវិញ ។ លោកបានឆ្លើយនៅក្នុងកំណត់ហេតុនេះថា “នៅក្នុងមន្ទីរស-២១ នេះ ខ្ញុំបានឮ ឌុច និង ហ៊ី និយាយថា យើងគួរសម្លាប់ឲ្យអស់ និងទុកតែបួនលាននាក់តែប៉ុណ្ណោះ” ។ ជាចម្ងល់ខ្ញុំសួរថា ពាក្យនេះលោកនៅប្រកាន់ដដែលទេ? ហើយតើមានន័យទូលំទូលាយដល់ទូទាំងប្រទេសឬទេ? ការសល់មនុស្សនេះ?

បើលោកមិនច្បាស់សូមលោកសួរខ្ញុំមកវិញ ។

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី យ៉ាងម៉េចទៅ? ជំទាស់យ៉ាងម៉េចទៅ?

**លោក ហ្រ្វង់ស្វ័រ រូ៖**

លោកប្រធាន! ខ្ញុំជឿថា បញ្ហាសំណួរនេះ គឺសំណួរជាន់ទៀតហើយ សំណួរនេះ បានសួរទៅលោក ហ៊ីម ហ៊ុយ រួចហើយ ដូច្នេះហើយយើងធ្វើយ៉ាងណាចៀសវាងសំណួរជាន់គ្នាដដែលៗ ។

**ប្រធានអង្គជំនុំ៖**

អរគុណនូវការសង្កេតរបស់លោកមេធាវី ។ លោក ហ៊ីម ហ៊ុយ មិនបាច់ឆ្លើយនូវសំណួរនេះទេព្រោះជាសំណួរដដែល មេធាវី ហុង គីមសួន ដូរសំណួរថ្មី បើមាន ។

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន សូមអនុញ្ញាតបន្តិចសិន ព្រោះខ្ញុំបាទមិនសួរបញ្ចូលគ្រាន់តែរំឭកឡើងវិញពីលើក ដើម្បីភ្ជាប់សំណួរថា មានន័យទូលាយទៅក្នុងប្រទេស ឬក៏ទាក់ទងទៅត្រឹមស-២១ បើខ្ញុំមិនយល់ពីមុនមក តែប៉ុណ្ណឹងទេ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោក ហ៊ីម ហ៊ុយ យល់នូវសំណួរទេ ។ សំណួរនេះដដែលទេ ប៉ុន្តែ មានន័យបញ្ជាក់ន័យបន្ថែម នៅក្នុងក្របខ័ណ្ឌថា ទុកតែប្អូនលានហ្នឹង គឺក្នុងក្របខ័ណ្ឌទូទាំងប្រទេស ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ដំបូង តា ឌុច អ្នកនិយាយ ថាសម្លាប់ឲ្យអស់ ទុកតែប្អូនលាននាក់ដល់ក្រោយមកទៀតមក គាត់ថា សម្លាប់ឲ្យខ្មោចតែម្តង ។ នេះខ្ញុំចាំពីរពាក្យនេះ ចាំមិនភ្លេចទេ រហូតតាំងពីនោះមក ។

[១២:០៤:៥៧]

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ខ្ញុំបាទ មានសំណួរត្រឹមប៉ុណ្ណេះបាទ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ក្នុងការពិភាក្សាដេញដោលចុងក្រោយនេះ ដោយមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណីឃើញថា អស់ទាំងក្រុមប្អូនហើយ ហើយពេលវេលាដល់ម៉ោងដប់ពីរនិងបីនាទីហើយ ដែលជាម៉ោងត្រូវសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ។ ដូច្នេះ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ហើយអង្គជំនុំជម្រះនឹងបន្តធ្វើនៅរសៀលនេះ ចាប់ពីម៉ោងមួយកន្លះតទៅ ។ ហើយមន្ត្រីតុលាការសម្របសម្រួលដល់សាក្សីរូបនេះ ដើម្បីឲ្យបានទទួលនូវកន្លែងសម្រាកសមរម្យ ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់បន្ទប់សម្រាក ហើយឲ្យនាំគាត់មកកាន់សាលសវនាការវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ ។

*[សវនាការសម្រាកពីម៉ោង ១២:០៦នាទី ដល់ម៉ោង ១៣:៣៣នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោលស្ដាប់សក្ខីកម្មចម្លើយរបស់សាក្សីឈ្មោះ ហ៊ីម ហ៊ុយ ។ ជាបន្តនេះ អង្គជំនុំជម្រះ សូមប្រគល់វេទិកាទៅមេធាវីការពារក្ដី ប្រសិនបើមានសំណួរត្រូវសួរដល់ជនជាប់ចោទ សូមអញ្ជើញមេធាវី អ៎! ដល់សាក្សីសូមអញ្ជើញ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ សូមគោរពតុលាការ ។ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន សុំឲ្យជនជាប់ចោទធ្វើការកត់សម្គាល់ជាមុន ចាំខ្ញុំបាទមានសំណួរជាក្រោយ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទ តើមានអ្វីចង់កត់សម្គាល់លើសក្ខីកម្មរបស់សាក្សី ហ៊ីម ហ៊ុយ ដែរឬទេ? បើមានសូមអញ្ជើញ ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ខ្ញុំសូមអរគុណលោកប្រធានដែលបានអនុញ្ញាតឲ្យខ្ញុំធ្វើការកត់សម្គាល់។ ដំបូងខ្ញុំសូមបញ្ជាក់ថា មិត្តហ៊ុយ នេះពិតជាបុគ្គលិករបស់មន្ទីរស-២១ មែន ។ ខ្ញុំស្គាល់ច្បាស់ចាប់តាំងពីខ្ញុំឡើងធ្វើជាប្រធានមន្ទីរស-២១ ជំនួស ណាត បានប៉ុន្មានខែទេ តិចតួចណាស់ ខ្ញុំក៏ចាប់ផ្ដើមស្គាល់មិត្តហ៊ុយ នេះជាអនុប្រធានកងអនុសេនាតូច កងពិសេសរបស់មន្ទីរស-២១ ។ ខ្ញុំស្គាល់ច្បាស់របស់ខ្ញុំ ។ តទៅទៀតនេះ ខ្ញុំសូមបញ្ជាក់ថា សក្ខីកម្មដែល មិត្តហ៊ុយ រាយការណ៍ជូនអង្គប្រជុំ បើគាត់និយាយត្រឹមតែអ្វីដែលគាត់ធ្វើ អ្វីដែលគាត់បានធ្វើនៅសម័យនោះ មានលក្ខណៈពិតជាមូលដ្ឋាន ។ ពាក្យថាពិតជាមូលដ្ឋាននេះ មានន័យថា ពិតច្រើន ពិតត្រង់ចំណុចសំខាន់ ក៏ប៉ុន្តែក៏នៅមានលើសខ្វះតិចតួច។ ក៏ប៉ុន្តែចំណុចមិនសំខាន់ទេ ។ ក្នុងឋានៈគាត់ជាកម្មាភិបាលអនុសេនាតូច គាត់និយាយអស់ហើយភារកិច្ចគាត់

ទាំងប៉ុន្មាន ដូចគ្នានឹងភារកិច្ចគាត់ដែលខ្ញុំបានរាយការណ៍ ជូនអង្គប្រជុំជាហូរហែ គឺចាំទទួលមនុស្សដែលគេយកមកប្រគល់ឲ្យនៅនឹងត្រង់ទីស្នាក់ការរបស់គាត់ ។ មនុស្សណាត្រូវបំបែកទៅព្រៃស ក៏គេមានចំណារច្បាស់លាស់របស់គេ ។ មនុស្សណាដែលគេត្រូវឲ្យបញ្ចូលមកកន្លែងឃុំឃាំងក៏គេមានចំណារច្បាស់លាស់របស់គេ ។ នេះគាត់បានបញ្ជាក់ភារកិច្ចនេះច្បាស់លាស់របស់គាត់ ជូនអង្គប្រជុំហើយ ។

[១៣:៣៧:១២]

ភារកិច្ចមួយទៀត គឺបញ្ជូនមនុស្សពីកន្លែងទទួលទៅឲ្យខាងក្នុង នេះក៏គាត់បាននិយាយច្បាស់លាស់ ។ ភារកិច្ចមួយទៀតរបស់គាត់ គឺនាំមនុស្សទៅជើងឯក នេះក៏គាត់បាននិយាយច្បាស់លាស់របស់គាត់ ។ ខ្ញុំគ្រាន់តែសុំបញ្ជាក់ជូនអង្គប្រជុំថា ក្នុងឋានៈគាត់ជាកម្មាភិបាលអនុសេវាតូច គាត់ទទួលខុសត្រូវ ចំពោះមុនបក្សស-២១ដាច់ខាត មិនឲ្យអ្នកទោសរត់រួច មិនឲ្យបែកការណ៍សម្ងាត់ តែគ្មានបញ្ជាណាឲ្យគាត់សម្លាប់អ្នកទោសដោយផ្ទាល់ដៃទេ ការងារនេះជាការងារកូនទាហានរបស់គាត់។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

ចំណែកកុមារ ក៏អាចគាត់មិនដឹងមែន ព្រោះពេលខ្លះមិត្តហ៊ិ គាត់ប្រើ ប៉េង ដែលជាកម្មាភិបាលអនុសេនាធំ ពេលខ្លះ មិត្តហ៊ិ គាត់ប្រើ ហ៊ុយ ដូច្នេះ គាត់អាចមិនដឹងមែន ។ ចំណែកកិច្ចការខ្លះទៀត ក៏គាត់និយាយច្បាស់ដែរ នៅពេលដែលគេបញ្ជូនពួកបូព៌ាមកច្រើនៗនោះ គាត់ទៅសុំឡានគេបញ្ចូលទៅដល់ក្នុងបរិវេណវិទ្យាល័យពញាយ៉ាតហ្នឹង ក៏គាត់និយាយបានច្បាស់របស់គាត់ត្រឹមត្រូវ ។ ខ្ញុំទទួលថាត្រឹមត្រូវបញ្ហានេះ ។

ដោយឡែក នៅពេលចុងបំផុតពេលនោះប្រញាប់ណាស់ ស-២១ មានកម្មវិធីមួយតាមដានរកចម្លើយតាមចម្លើយអំពីយួនដែលចូលមក ហើយកម្មាភិបាលខ្មែរទៅលាក់យួន ពេលនោះខ្ញុំចាំថា មិត្តហ៊ិប្រើមិត្ត ហ៊ុយ ចេញទៅរកមានតេអ្វមួយគ្រឿង មានម៉ាស៊ីនថតទៅមួយគ្រឿងទៅថតសភាពការណ៍ដើម្បីរាយការណ៍ ថាតើអាចទិដ្ឋភាពលាក់កន្លែងយួនមែន ឬមិនមែន ។ បានទាំងរូបថត បានទាំងអីយើងខ្ញុំរាយការណ៍ជូនអចិន្ត្រៃយ៍មជ្ឈិមអស់ហើយ ។ នេះភស្តុតាងចុងក្រោយដែលបញ្ជាក់អំពីការងាររបស់ មិត្តហ៊ុយ ។ នៅពេលចុងក្រោយនេះរវល់ខ្លាំង គឺថ្ងៃ២ ឬថ្ងៃ៣ បញ្ចេញមនុស្សចេញឲ្យអស់ពីវិទ្យាល័យពញាយ៉ាតទៅជើងឯកនេះ ខ្ញុំជឿថាពេលនោះ មិត្តហ៊ុយ រវល់ខ្លាំងណាស់ នេះគឺរឿងពិតដែលគាត់និយាយទាំងអស់ស្ថិតនៅក្រោមបញ្ជា ។ នេះរឿងពិតដែលគាត់និយាយទាំងអស់ និយាយកិច្ចការអស់នេះ គឺស្ថិតនៅក្រោមបញ្ជាយើងខ្ញុំពិតប្រាកដ ច្បាស់លាស់ គឺឧក្រិដ្ឋកម្មនេះគាត់ធ្វើ ធ្វើនៅក្រោម

បញ្ហារបស់ខ្ញុំ ដែលជាប្រធាននៅមន្ទីរស-២១ នេះជារឿងពិត ។ ក៏ប៉ុន្តែរឿងខ្លះ វាធម្មតាទេ វាលើសលោះខ្វះខាតខ្លះហើយ ដូចគាត់និយាយថា គាត់ចាប់ មិត្តប៉ង់ ជាមួយខ្ញុំ អត់ទេ ខ្ញុំអត់ដែលបញ្ជាទៅមិត្ត ហ៊ុយ ដោយផ្ទាល់ទេអនុប្រធានខ្ញុំគឺមិត្ត ហ៊ី ខ្ញុំមិនដែលបញ្ជារំលងទេ ។ ពាក្យខ្មែរយើងគេថា "មិនបោះសន្ទូចរំលងភ្នំទេ" ខ្ញុំអត់ដែលបញ្ជាមិត្ត ហ៊ុយ រំលង មិត្តហ៊ី ខ្ញុំទេ ។

[១៣:៤០:៣២]

ខ្ញុំបានទទួលដំណឹងពីថា បក្សឲ្យខ្ញុំចាប់ មិត្តប៉ង់ ខ្ញុំពីរនាក់ មិត្តហ៊ី ពិគ្រោះគ្នា ប៉ង់ ចូលមកមិត្ត ហ៊ី ចាប់ បើសិនមានវត្តមាន មិត្តហ៊ុយ នៅកន្លែងនោះវិញ ប៉ង់ ភ័យខ្លួនហើយភ្ញាក់ ។ បើសិនជាមានវត្តមាន មិត្តហ៊ី ធម្មតាទេ ប៉ង់ តែងតែឃើញខ្ញុំនិង មិត្តហ៊ី ញឹកដែរនៅជាមួយគ្នា អនុប្រធាន និងប្រធាន វានៅជាមួយគ្នាជារឿងធម្មតា ។

ឯចំណែក មិត្តហ៊ុយ និយាយពីរឿងទៅចាប់មិត្ត ហ៊ុយ ស្រែ ពេលចាប់ នុន ហ៊ុយ នោះគ្មានវត្តមានគាត់មែន មិនត្រូវមានវត្តមាន មិត្តហ៊ុយ ទេ ព្រោះ មិត្តហ៊ុយ មិនដែលមកប្រជុំជួបនឹងខ្ញុំទេ ។ ដូច្នេះ គាត់និយាយពីរឿងចាប់មិត្ត ហ៊ុយ ស្រែ គ្មានវត្តមានគាត់ជារឿងត្រឹមត្រូវ ។

រឿងមួយទៀត ខ្ញុំសូមបញ្ជាក់ទេ មិនជជែកតវ៉ាអីដើម្បីយកឈ្នះយកចាញ់អីទេ គាត់ថា គាត់បានស្នើសុំមេខ្ញុំ អ្ហែ! មេខ្ញុំអី មេស-២១ ទាំងមូល មេទាំងគាត់មេទាំងខ្ញុំទាំងអស់គ្នាហ្នឹង គាត់ទទួលស្គាល់ហើយតើមេធំហ្នឹង អញ្ជើញមកធ្វើសន្និបាតនៅស-២១ គាត់ថាគាត់បានស្នើសុំមេធំចេញទៅ ពេលដែលមេអញ្ជើញមកធ្វើសន្និបាត មិនមានរបៀបវារៈណាឲ្យ មិត្តហ៊ុយ ស្នើសុំចេញទេ អត់ទេ ។ ហើយបើទោះជាមាន ក៏អត់ប៊ានចេញដែរ ក៏អត់ឲ្យមានរបៀបវារៈណាស្នើចេញពីអង្គភាពទេ ។ ដូច្នេះ ពាក្យនេះមិត្តពិតទេ ។ ដូច្នេះសរុប មកពាក្យមិនពិតតិចណាស់ ឯពាក្យពិតច្រើនណាស់ ច្រើនឥតគណនា ដូច្នេះខ្ញុំទទួលស្គាល់ថា សក្ខីភាពរបស់ មិត្តហ៊ុយ ត្រឹមត្រូវ ។ ដោយឡែកតែ អ្វីដែលគាត់បានគ្រាន់តែឮ ឬក៏គាត់និយាយទទេៗដូចថា ខ្ញុំ ហើយនិង មិត្តហ៊ី ទាស់គ្នា ។ ខ្ញុំមិនទាន់ឃើញឯកសារអីច្បាស់លាស់ គាត់អះអាងថាឲ្យល្អម ឲ្យខ្ញុំទទួលខ្ញុំទទួលស្គាល់ថា ពាក្យគាត់គឺជាពាក្យពិតទេ ។ ដូច្នេះ ខ្ញុំសូមសរុបដោយខ្លីប៉ុណ្ណេះ ។

នៅចុងបំផុតនេះ ខ្ញុំសូមអង្វរក មិត្តហ៊ុយ មួយម៉ាត់ សូមឲ្យមេត្តាអាណិតដល់ជនរងគ្រោះ មានម្នាក់នោះជាគ្រូខ្ញុំ ខ្ញុំអត់ដឹងទេ គាត់មកទីនោះ ខ្ញុំជឿថាមិត្តអាចឃើញគាត់ ។ ដូច្នេះ សូមមិត្តបំភ្លឺទៅតើគាត់ស្លាប់នៅភ្នំពេញដោយជំងឺ ឬយើងយកគាត់ដើងឯក? ដូច្នេះ សូមមិត្តមេត្តាបំភ្លឺត្រង់នេះឲ្យៗជន

រងគ្រោះបានអស់ចិត្តផង នេះខ្ញុំសុំអង្វរចិត្តមិត្ត ។ នេះសូមបញ្ចប់ប៉ុណ្ណេះ ។ សូមគោរព ។

[១៣:៤៣:២៧]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ។

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ និងសូមគោរពអង្គសវនាការ ។

**ស៖** លោក ហ៊ឹម ហ៊ុយ ថ្ងៃមុនលោកបានឆ្លើយថា លោកទៅដឹកអ្នកទោសនៅស្វាយរៀងជាឈ្លើយសឹកវៀតណាមចំនួនពីរដង ពីរជើង ។ លោកបានឆ្លើយបញ្ជាក់ជូនតុលាការថា អ្នកបញ្ជាឲ្យទៅដឹកគឺ តាឌុច ឲ្យនីរសារគាត់មកប្រាប់ខ្ញុំឲ្យទៅដឹក ហើយព្រឹកមិញនេះលោកបានបញ្ជាក់ថា ខ្ញុំធ្លាប់ទទួលបញ្ជាផ្ទាល់ពី តាឌុច ដូចជាបញ្ជាឲ្យទៅដឹកឈ្លើយសឹកវៀតណាមនៅខេត្តស្វាយរៀង ។ អ៊ីចឹង សូមលោកបញ្ជាក់ឲ្យច្បាស់មើល តើលោកទទួលបញ្ជាកផ្ទាល់ពីតាឌុច ឬមួយក៏លោកទទួលតាមរយៈនីរសាររបស់តា ឌុច ។ សូមលោកបញ្ជាក់ ។

**ឆ៖** បាទ, ខ្ញុំសូមបញ្ជាក់បញ្ជាហ្នឹង គឺខ្ញុំទទួលពីនីរសាររបស់គាត់ បើគាត់មិនបញ្ជានីរសាររបស់គាត់មក ខ្ញុំម៉េចនឹងបានទៅ ។ ហើយមួយទៀត ដូចខ្ញុំសុំនៃតា សុន សេន នោះ គឺតា សុន សេន មកប្រជុំនៅកន្លែងគាត់អ៊ីចឹងមែន តាឌុច គាត់ដើរទៅផ្ទះទៅ ខ្ញុំឡើងឈរសុំ សុំគាត់ នឹកឃើញថា ខ្ញុំនៅនេះក៏ងាប់ដែរ អ៊ីចឹងសុំធ្វើទ័ពវិញ សុខចិត្តទៅច្បាំងគ្នាងាប់នៅកន្លែងនេះ វាជិតគុកពេកទៅហើយ ។

**ស៖** សូមអរគុណ ។ ទីពីរ លោកបានបញ្ជាក់ថា អ្នកដែលចាប់ចូលស-២១ មិនដែលបានដោះលែងទៅវិញទេ តែចូលមកគឺចប់ហើយ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ, គឺអ៊ីចឹងមែន ។

**ស៖** សូមអរគុណ ។ លោកបានបញ្ជាក់ពីថ្ងៃមុនថា ពេលយប់ម៉ោងប្រាំបី ឬម៉ោងប្រាំបួន គេយកអ្នកទោសទៅកម្ទេចនៅខាងត្បូង និងខាងលិចគុក អ៊ីចឹងមែនទេ ថ្ងៃមុន?

**ឆ៖** បាទ, គឺអ៊ីចឹងមែន ។

**ស៖** អ៊ីចឹងសូមលោកបញ្ជាក់ឲ្យបានច្បាស់ថែមទៀត។ ចុះនៅខាងជើងគុក ប៉ែកខាងជើងអគារ "D" គេអត់មានដែលយកអ្នកទោសទៅសម្លាប់នៅទីនោះទេឬ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ខ្ញុំក្តាប់មិនបានដែរ ។ ដឹងច្បាស់ជាងគេ រឿងលិច ហើយនិងខាងត្បូង ។

**ស៖** សូមអរគុណ ។ លោកបានបញ្ជាក់ហើយថា គេសម្លាប់ហើយ នៅជើងឯកណ៉ា! គឺគេសម្លាប់ហើយ គេកប់ភ្លាម មិនទុកឲ្យនៅដល់ថ្ងៃស្អែកទេ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ, គឺអ៊ីចឹងមែន ។

**ស៖** សូមអរគុណ ។ អ៊ីចឹងគេសម្លាប់ហើយ គេកប់ភ្លាម គេអត់មានដើរចោលរណ្តៅដែលគេសម្លាប់ហ្នឹងទេ ឬយ៉ាងម៉េច?

**ឆ៖** បាទ, ក្រុមហ្នឹងតែគេសម្លាប់ហើយ គេនាំគ្នាកប់ឲ្យហើយភ្លាមគេមិនទុកដល់ស្អែកទេ ។

**ស៖** សូមអរគុណ ។ ពីព្រោះខ្ញុំសួរអ៊ីចឹង ព្រោះខ្លាចលោមានអ្នកខ្លះ គេថាកាប់ហើយ ក្រែងលោអត់ស្លាប់អី គេឡើងទៅលួចអី ក្រែងលោមានអ៊ីចឹង ។

សំណួរទីប្រាំ លោកបញ្ជាក់ថ្ងៃមុនថា ពេទ្យនៅស-២១ មានប្រាំពីរ ប្រាំបីនាក់ គឺប្រុសទាំងអស់គ្មានស្រីទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, គឺអ៊ីចឹងមែន ។

[១៣:៤៨:១៧]

**ស៖** សូមអរគុណ ។ លោកមានស្គាល់ឈ្មោះ ឡាច ដារ៉ា ហៅ ថន ទេ?

**ឆ៖** បាទ ខ្ញុំស្គាល់គាត់ គឺគាត់ហ្នឹងប្រុស ឈ្មោះ ថន ។

**ស៖** លោកមានស្គាល់ឈ្មោះ ហាក់ ផាដេត ទេ?

**ឆ៖** បាទ, ខ្ញុំអត់ស្គាល់ទេ ។

**ស៖** លោកមានស្គាល់ឈ្មោះ ជឹម សុខ ទេ?

**ឆ៖** បាទ, ខ្ញុំអត់ស្គាល់ទេ ។

**ស៖** សូមអរគុណ ពីព្រោះឈ្មោះនេះសុទ្ធតែជាពេទ្យ ប៉ុន្តែពេទ្យនេះ គឺគេសុទ្ធតែជាអ្នកទោសដែលគេយកមកឲ្យបំរើការនៅពេទ្យ ហើយស្លាប់អស់ហើយ ខ្លះយកទៅកម្ទេចនៅស-២១ ។ ហើយពីរនាក់ទៀតរត់ទៅនៅថ្ងៃ៧មករា ហ្នឹង ក៏ស្លាប់ទៅទៀត ។ សំណួរទីប្រាំមួយ ពេលចាប់ខ្លួន មិនដែលមានវត្តមាន តាឌុច ទេ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលចាប់ខ្លួន គឺតាឌុច ជាអ្នកបញ្ជាឲ្យទៅចាប់ តែគាត់មិនចេញមុខចាប់ទេ បើគេឃើញគាត់ គឺដឹងថាគាត់ជាសន្តិសុខ អ៊ីចឹងពួកខ្ញុំដែលជាអ្នកចាប់ គឺតាមបញ្ជារបស់គាត់ត្រូវចាប់ ។

**ស៖** សូមអរគុណ។ សូមលោកបញ្ជាក់មួយទៀត គឺលោកបានបញ្ជាក់ថា សម្លាប់មនុស្សដោយគេវាយនឹងកញ្ចឹងក គេវាយនឹងដំបងដែក គេវាយនឹងដែក ហើយបន្ទាប់ពីវាយរួច គេអារ-កអ្នកទោស តើគេបានស្អីយមកអារ-ក?

**ឆ៖** បាទ, ខ្ញុំបានបញ្ជាក់ពីម្សិលមិញហើយថា គេវ៉ៃនឹងដែក គេហៅថា ដែកផ្លូវរទេះ យល់ទាំងអស់គ្នា ប៉ុន្តែ ដែកខ្មោះហ្នឹង ដែកខ្មោះជាងមួយម៉ែត្រហ្នឹងយកទៅវ៉ៃ វ៉ៃហើយអ្នកទោសនោះក៏សន្លប់វឹបទៅ គឺកាំបិតចិតត្នោតហ្នឹង ដែលគេយកទៅអារ-ក ។

**ស៖** សូមទោស បានជាខ្ញុំសួរអ៊ីចឹង ពីព្រោះនៅក្នុងចម្លើយរបស់លោកឯកសារ ERN 008 1340 លេខ D48/2 លោកថា អារកអ្នកទោសនឹងធាងត្នោត នៅក្នុងទំនុងណា អ៊ីចឹងបានខ្ញុំសូមបញ្ជាក់ ពីព្រោះលោកឆ្លើយបញ្ជាក់នៅពេលនេះថា កាំបិតអារត្នោត អាកាំបិតអារត្នោត ហើយនិងធាងត្នោតវាខុសគ្នា បានខ្ញុំសួរបញ្ជាក់ហ្នឹង ។

ចំណុចទីប្រាំបី លោកព្រឹកមិញបានឆ្លើយម្តងហើយ ថា លោកបានធ្លាប់បានទៅរោងជាងខាងក្រោយ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលនោះ គឺកន្លែងហ្នឹងចិញ្ចឹមជ្រូក១ ជ្រូកច្រើនហ្នឹង ហើយខ្ញុំក៏នាំគ្នាដើរទៅមើលជ្រូកហ្នឹង គេឲ្យទៅមើលជ្រូកហ្នឹង ដល់តែពេលដូចថា ថ្ងៃណាដែលគេធ្វើម្ហូបហ្នឹង គេឲ្យមើលជ្រូកហ្នឹងឲ្យហើយ ថ្ងៃណាធ្វើម្ហូបដែលយើងត្រូវជប់លៀងអី ព្រោះអត់មានម្ហូបស៊ី ។ ទៅមើលជ្រូក ឃើញជ្រូកវាធំ១នោះ ក៏មើលជ្រូកហើយ ដើរចេញមកវិញមក អាហ្នឹងខ្ញុំទៅអ៊ីចឹងមែន ។

[១៣:៥២:០៥]

**ស៖** ប៉ុន្តែ ខ្ញុំសូមសួរបញ្ជាក់ថា តើលោកដែលចូលទៅក្នុងរោងជាងហ្នឹងឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា កន្លែងរោងជាង ហើយនិងកន្លែងចិញ្ចឹមជ្រូកនៅជាមួយគ្នាហ្នឹង ជាប់១គ្នានៅហ្នឹង ។

**ស៖** អ៊ីចឹងបើលោកដែលចូលទៅក្នុងរោងជាងហ្នឹង អ៊ីចឹងក្នុងថ្ងៃ១ មករា ថ្ងៃ១ ថ្ងៃ២ ថ្ងៃ៣ ថ្ងៃ៤ ថ្ងៃ៥ ថ្ងៃ៦ រហូតដល់ថ្ងៃ៧ មករា ហ្នឹង តើបើលោកធ្លាប់ចូលទៅក្នុងរវាងក្នុងប្រាំពីរថ្ងៃហ្នឹង តើ

លោកមានធ្លាប់ឃើញកូនក្មេងពីរនាក់ ឬក៏កូនទារកអី ម្នាក់ពីរអីនៅហ្នឹង លោកមានធ្លាប់ឃើញទេ?

**ឆ៖** បាទ, ខ្ញុំបានបញ្ជាក់ពីម្សិលមិញហើយថា ខ្ញុំពាក់កណ្ដាលឆ្នាំ៧៨ គេដកឲ្យខ្ញុំទៅធ្វើស្រែនៅខាងត្បូងជើងឯង រហូតដល់បែក៧មករាហ្នឹង ។

**ស៖** សូមអរគុណ ។ លោកបានបញ្ជាក់ប្រាប់ជូនតុលាការថា ការកម្ទេចនៅជើងនៅជើងឯក ដែលថា កម្ទេចពេលដែលថាច្រើននោះណា៎ គឺលោកប្រញាប់ប្រញាល់ប្រូសប្រាស១ ព្រោះខ្លាចភ្លឺគេដឹង អ៊ីចឹងលោកមិនដឹងថា គាត់ ឬ តាហ៊ ទេ គាត់ហ្នឹងគឺ តាឌុច ន៎ែ មិនដឹងជា តាឌុច ឬ តាហ៊ទេ ។ តែពេលព្រឹកមិញ លោកជម្រាបលោក ហុង គឹមសួន-- មេធាវីហុង គឹមសួន ថាលោករក្សាចម្លើយនៅចៅក្រមអង្កេតដែលថាឆ្លើយនៅជើងឯកហ្នឹងដដែល ។ អ៊ីចឹង ពីព្រោះថា អាចម្លើយពីរហ្នឹងវាផ្ទុយគ្នា ។ អ៊ីចឹងខ្ញុំសូមសួរលោក សូមលោកបញ្ជាក់សាជាថ្មី លោករក្សាចម្លើយដែលលោកឆ្លើយនៅចៅក្រមស៊ើបអង្កេត ឬមួយក៏លោករក្សាចម្លើយ ដែលលោកបានឆ្លើយនៅពេលសវនាការនេះ ឆ្លើយទៅលោកចៅក្រមនោះ តើចម្លើយពីរហ្នឹង លោកចោលមួយណា? លោកទុកមួយណា? សូមលោកបញ្ជាក់ សូមអរគុណ ។

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលដែលសម្លាប់អ្នកទោសច្រើន ដល់ថ្នាក់ជិតមួយរយ និងមួយរយនាក់នោះ គឺជាការពិបាកណាស់ វាច្រើន ។ ពេលហ្នឹងហើយ ខ្ញុំមិនដឹងថាអ្នកណា១ ព្រោះពេលវាជិតភ្លឺហើយ គឺឲ្យគេរូតរះ ន្ទាលប្រមូលអីវ៉ាន់ឡើងឡាន ។ ពេលហ្នឹងហើយគឺ តាហ៊, តាឌុច ហ្នឹង គាត់ទៅហ្នឹងដែរ ដល់ហើយគាត់ ហើយបានគាត់ឡើងឡានមកវិញមក ហើយពួកខ្ញុំក៏ប្រមូលអីវ៉ាន់ហ្នឹងដាក់ឡាន រូតមកវិញមកដែរ បើកយ៉ាងឡាន ព្រោះខ្លាចភ្លឺ តែភ្លឺបែកការណ៍ គេដឹងគ្រប់គ្នាហើយ អ៊ីចឹងក៏នាំគ្នារូតរះនឹងមក ។

[១៣:៥៥:០៩]

**ស៖** សូមអរគុណ ។ អ៊ីចឹងលោករក្សាចម្លើយ ដែលលោកបានឆ្លើយនៅពេលសវនាការនេះ អ៊ីចឹងមែនទេ?

**ឆ៖** បាទ, គឺអ៊ីចឹងមែន ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ សូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ សូមឲ្យមេធាវីអន្តរជាតិសួរបន្ត សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារក្តីអន្តរជាតិ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកប្រធាន ។ សូមជម្រាបសួរលោក ហ៊ឹម ហ៊ុយ ខ្ញុំមេធាវី រ៉ូ យើងបានជួបគ្នានៅពេលសម្តែងឡើងវិញនៅទួលស្លែង ហើយនិងព្រៃស ដែលរៀបចំឡើងដោយសហចៅក្រមស៊ើបអង្កេត ហើយខ្ញុំសួរសំណួរលោកកាលពីពេលនោះ ។ ខ្ញុំនឹងសួរសំណួរផ្សេងទៀតមួយចំនួន ដើម្បីសរុបព័ត៌មាននូវសក្ខីកម្មដែលលោកបានផ្តល់ដល់អង្គជំនុំជម្រះពេលនេះ យើងស្វែងរកដើម្បីយល់ តើមានអ្វីកើតឡើងលោក ហ៊ឹម ហ៊ុយ លោកអាចជួយយើង ដើម្បីឲ្យយើងបានយល់ច្បាស់ ។

**ស៖** ខ្ញុំសូមបន្តទៅលើបញ្ហាមួយចំនួនដែលលោកមេធាវី ការ សាវុត្ថ បានលើកឡើង ហើយខ្ញុំក៏រំឭកលោកថា ទាក់ទងទៅនឹងហេតុការណ៍ដែលបានកើតឡើងនៅជើងឯក ហើយខ្ញុំនឹងត្រឡប់ទៅរកអ្វីដែលលោកបាននិយាយ ហើយអ្វីដែលសហចៅក្រមស៊ើបអង្កេត បានសរសេរនៅពេលដែលយើងបានទៅទីនោះទាំងអស់គ្នា ។ ប្រសិនបើយើងមើលទៅលើឯកសារថ្ងៃទី២៦ កុម្ភៈ អង្គជំនុំជម្រះអាចនឹងឃើញឯកសារ D48/1 ហើយយើងយោងទៅរកកថាខណ្ឌ៦.១ ។ សហចៅក្រមបានសរសេរដូចខាងក្រោមនេះ៖

[១៣:៥៧:៤៩]

សាក្សី ហ៊ឹម ហ៊ុយ បានបញ្ជាក់ដោយមិនស្របគ្នាទៅសម្តីរបស់គាត់ ទាក់ទងទៅនឹងចំនួនដែលឌុច បានទៅកាន់ទីកន្លែងជើងឯកនោះ ។

នៅថ្ងៃទី២៨ កុម្ភៈ ពីរថ្ងៃក្រោយពីនោះមក ឯកសារ D52 លោកបាន នៅពេលតទល់គ្នា ហើយសហចៅក្រម ម៉ាក់សែល ឡឺម៉ុងដ៍ បានសួរទៅលោកនូវសំណួរដូចខាងក្រោម ហើយគាត់បញ្ជាក់សំណួរដូចខាងក្រោម៖

លោកបានបញ្ជាក់ថា នៅកន្លែងដែលកើតហេតុនោះ ទីមួយ លោកថា ឌុច បានមកជើងឯកពីពេលមួយទៅពេលមួយ ហើយបន្ទាប់មក ហើយលោកបានឆ្លើយទៅសំណួរដែលចៅក្រមសួរនោះ ហើយលោកនិយាយថា គាត់មកម្តង ឬពីរដង ។ ហើយសំណួរសួរទៅនឹង ចម្លើយទៅនឹងសំណួរដោយមេធាវីការ លោកនិយាយថា លោកមិនបានដឹង ថាគាត់មកច្រើនជាងម្តង ឬក៏ម្តងនោះទេ ។ ហើយនៅពេលនោះឯង លោកបាននិយាយថា គាត់បានមកម្តងជាមួយ ហ៊ ។ ដូច្នេះ សំណួរខ្ញុំចង់សួរទៅលើនោះ

គឺថាតើត្រឹមត្រូវទេ ដើម្បីឲ្យខ្ញុំបញ្ជាក់ថា បន្ទាប់ពីការផ្តល់ចម្លើយមួយចំនួនដែលថា ខុសៗគ្នាទាក់ទងទៅនឹងការទៅជើងឯករបស់ ឌុច នេះ អ៊ីចឹងថ្ងៃនេះលោកទទួលស្គាល់ថា ឌុច បានទៅជើងឯកតែម្តងទេ តើត្រឹមត្រូវទេដែលខ្ញុំនិយាយបែបនេះ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា តាឌុច ដែលខ្ញុំឃើញទៅ គឺពីរដង តែបើគាត់និយាយប្រកែកថាខ្លួនគាត់ទៅបានម្តង អាហ្នឹងជារឿងរបស់គាត់ ដែលគាត់និយាយ ។

**ស៖** សូមអភ័យទោស លោក ហ៊ឹម ហ៊ុយ យើងមិនយល់គ្នាច្បាស់ទេ ។ មិនមែនគាត់ជាអ្នកនិយាយទេ គឺលោកជាអ្នកនិយាយពាក្យហ្នឹងចំពោះមុខចៅក្រមស៊ើបអង្កេត ។

**ឆ៖** ខ្ញុំសូមជម្រាបថា អង្កាល់នេះគាត់និយាយ គាត់ថាគាត់ទៅជាមួយ តាហ៊ី តែម្តងទេ តែខ្ញុំបានដាក់ក្នុងនេះហ្នឹងថា ខ្ញុំឃើញគាត់ច្បាស់គឺទៅពីរដង ហើយគាត់ប្រកែកថាទៅតែម្តង អាហ្នឹងប្រកែកថា ទៅតែម្តងអាហ្នឹងជារឿងរបស់គាត់ ។ ប៉ុន្តែខ្ញុំថា គាត់ទៅពីរដងព្រោះខ្ញុំឃើញគាត់ទៅពីរដង ។

**ស៖** ប៉ុន្តែ ដោយខ្ញុំមិនដឹងនៅពេលដែលលោកនិយាយនោះ ខ្ញុំពិបាកហ្នឹងយល់បន្តិច។ ប៉ុន្តែ តើលោកនៅតែប្រកាន់តាមអ្វីដែលលោកបាននិយាយនៅចំពោះមុខអង្គជំនុំជម្រះកាលពីថ្ងៃព្រហស្បតិ៍មុនដែរឬទេ? នៅពេលដែលលោកឆ្លើយទៅនឹងសំណួរដែលសួរដោយលោកចៅក្រមឡាវែន់នោះ? ខ្ញុំរំឭកសំណួរនោះឡើងវិញ ។ សំណួរនោះសួរថា តើ ឌុច បាននៅមាត់រណ្តៅជាមួយលោកនៅពេលជិតភ្លឺហ្នឹងដែរឬទេ ដែលជាអ្នកបង្គាប់ឲ្យលោកសម្លាប់អ្នកទោស? ហើយលោកបានឆ្លើយថា ដោយហេតុថា យើងធ្វើការប្រញាប់ប្រញាល់ ហើយឡានរៀបចំហ្នឹងចេញទៅហើយ ហើយប្រសិនបើភ្លឺទាន់នោះគេអាចនឹងបែកការណ៍ គេមើលយើងឃើញ ។ ហើយ ការសម្ងាត់នៃការសម្លាប់មនុស្សនិងដំណើរការអាចហ្នឹងគេដឹងឮបាន ដូច្នេះខ្ញុំមិនប្រាកដថា តើគាត់ ឬហ៊ី ទេ? វាអាចថាគាត់ឬហ៊ី ដែលនៅទីនោះ ពីព្រោះគាត់ក៏បាននៅទីនោះផងដែរ ហើយគាត់បានទៅទីនោះជាមួយគ្នានឹងហ៊ីដែរនៅពេលនោះ ។ តើខ្ញុំអាចបញ្ជាក់ច្បាស់ទេថ្ងៃនេះថាលោកមិនច្បាស់ថា ហ៊ី ឬ ឌុច ទេដែលបង្គាប់លោកឲ្យសម្លាប់អ្នកទោសម្នាក់នោះ ។ តើខ្ញុំនិយាយអ៊ីចឹងត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលហ្នឹងគឺពេលរញ៉េរញ៉ៃ ហើយភ្លឺក៏កាន់មកជិតដល់ហើយ ។ អ៊ីចឹងពេលហ្នឹងគឺ កន្ទេលមួយក្រាលនៅកន្លែងហ្នឹង ។ ហើយមួយទៀត អ្នកដែលប្រាប់ហ្នឹងវារញ៉េរញ៉ៃហ្នឹងសភាពការណ៍ហ្នឹងផង ហើយអ្នកដែលធ្វើការសម្លាប់ហ្នឹងក៏ប្រញាប់ប្រញាល់ដែរព្រោះគេស្តីឲ្យ ។ អ៊ីចឹងខ្ញុំក៏មិនដឹងថា មួយណាមួយណាទេ ព្រោះខ្ញុំវារញ៉េរញ៉ៃដែរប្រញាប់រឿងនឹងឆ្ពាលទៅភ្នំពេញវិញដែរ ។

**ស៖** សូមអរគុណ ។ ដូច្នេះ លោក ហ៊ឹម ហ៊ុយ គឺជាលើកដំបូង ឬក៏ជាលើកទីពីរដែរលោកប្រាប់មកខ្ញុំថាលោកបានទៅនោះពីរដង ។ ថាតើវាមានរឿងហ្នឹងកើតឡើងមុនភ្លឺហ្នឹងដែលគាត់មកថ្ងៃហ្នឹងមកទីពីរ ឬក៏ទីមួយ?

[១៤:០៤:១៦]

**ឆ៖** នៅក្នុងពេលទីមួយ ។

**ស៖** សូមអរគុណ ។ ដូច្នេះ តើលើកទីពីរហ្នឹងយ៉ាងម៉េចដែរ? នៅពេលដែរលោកប្រធានសួរទៅលោកៗបានឆ្លើយថានិយាយរកតែការមកម្តងទេ តើអ៊ីចឹង-- ប៉ុន្តែលោកនិយាយពេលនេះថា ជាលើកទីមួយ ។ ចុះដែលគាត់មកជាលើកទីពីរនោះម៉េចដែរ?

**ឆ៖** លើកទីពីរហ្នឹងគឺគាត់ ខ្ញុំក៏មិនបានទៅនៅចាប់ភ្លឹកមើលគាត់អីដែរ ព្រោះគាត់ទៅហ្នឹងគាត់នៅហ្នឹងឡានរបស់គាត់ហ្នឹង ។ ហើយវាម្នាក់ៗគេ ខ្ញុំក៏មិនគិតគូររឿងហ្នឹងទេ ធ្វើម៉េចកត់ឈ្មោះកត់អីឲ្យគេកុំឲ្យច្រឡំ ខ្លាចវាគ្រោះថ្នាក់ដល់ខ្ញុំតែប៉ុណ្ណឹង ។

**ស៖** ដូច្នេះ បញ្ហានៅកន្លែងនេះគឺយើងមិនច្បាស់ទេ លោក ហ៊ឹម ហ៊ុយ នៅពេលដែលលោកឆ្លើយទៅសហចៅក្រមស៊ើបអង្កេតនោះ ។ ហើយខ្ញុំអាចបញ្ជាក់ឡើងវិញដោយយោងទៅចម្លើយដែលកត់ត្រាថ្ងៃទី២៨ កុម្ភៈ ២០០៨ ហើយលោកបានឆ្លើយដូចខាងក្រោមនេះ។ គាត់បានមកម្តងជាមួយ ហ៊ី ហើយខ្ញុំមិនច្បាស់ថាមកពេលណាទេ គាត់ជិះឡានរបស់គាត់មកហើយមាននីរសារមកជាមួយគាត់ផងគឺនៅពេលនេះហើយដែលបានឃើញគាត់អង្គុយនៅមាត់រណ្តៅ ហើយក្នុងពេលនោះ ហ៊ី បាននៅកន្លែងផ្ទះមួយ ។ បន្ទាប់មកគឺមួយថ្ងៃក្រោយមកទៀត គឺ ហ៊ី បានមកទៅមាត់រណ្តៅនោះផងដែរ ហើយបានបញ្ជាឲ្យខ្ញុំសម្លាប់មនុស្សបួននាក់ហើយខ្ញុំសូមបញ្ជាក់ថាលោកបានជម្រាបចៅក្រមថា ឌុច ហើយនិងហ៊ី មិនបានមកក្នុងពេលជាមួយគ្នាទេ នៅមាត់រណ្តៅនោះ។ ដូច្នេះ ខ្ញុំដែលខ្ញុំនិយាយថា ពីពេលមួយទៅពេលមួយមានន័យថាពីរដង ។ នេះហើយជាអ្វីដែលលោកបានបញ្ជាក់ប្រាប់សហចៅក្រមស៊ើបអង្កេត។ តើលោកនៅ ចាំពាក្យដែលលោកនិយាយនឹងទេ លោកហ៊ឹម ហ៊ុយ?

**ឆ៖** បើខ្ញុំចាំគឺពីរដងហ្នឹង ។

**ស៖** ដូច្នេះ ខ្ញុំថាគាត់មកពីរដងម្តងមកពេលជិតព្រលឹមដែលថា មកមាត់រណ្តៅ ហើយដែលម្តងទៀតមក ឃើញថាគាត់មកជាមួយឡានរបស់គាត់ តើនេះជាជំហររបស់លោកនៅថ្ងៃនេះឬ?

**ឆ៖** បាទ ។

[១៤:០៧:២៩]

**ស៖** អ៊ីចឹងហើយ យើងប្រកាន់យកគោលជំហរនេះហើយនិងរក្សាបញ្ហានេះជូនអង្គជំនុំជម្រះពិចារណា។ អ៊ីចឹងចំណុចមួយទៀត លោក ហ៊ីម ហ៊ុយ អ៊ីចឹងយើងត្រឡប់ទៅការងាររបស់លោកហើយនិងមុខងាររបស់លោក ។ ខ្ញុំមិនជាអ្នកជំនាញនៅក្នុងកិច្ចការយោធាទេ អ៊ីចឹង ខ្ញុំចង់ឲ្យលោកពន្យល់ ឲ្យខ្ញុំដឹងអំពីថាតើអ្វីដែលហៅថាអង្គភាពពិសេសហ្នឹង? ថាតើវាពិសេសយ៉ាងដូចម្ដេចដែលលោកនៅក្នុងកងនោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា អង្គភាពពិសេសនេះ គឺជាសម្ដីរបស់គាត់ទេដែលនិយាយថា អង្គភាពពិសេស ។ អង្គភាពហ្នឹងគេដកតាំងពីនីរសាកម្មាភិបាលដែលគេចាប់ខ្លួនចាប់អីយកនីរសារនោះមកប្រើប្រាស់ជាមួយហ្នឹង ។ ហើយពួកខ្ញុំដែលជាអ្នកដែលចាំទទួលអ្នកទោសទៅចាប់អីហ្នឹង ពួក តាហ៊ី ឲ្យពួកខ្ញុំហាត់រៀន តាហ៊ី អ្នកបង្រៀនពួកខ្ញុំអាក្បាច់ចាប់មនុស្សចាប់អីហ្នឹងឲ្យពួកក្រុមខ្ញុំ ហើយដកកម្លាំងពីក្នុងមកយកបង្រៀនហ្នឹង មិនមែនរៀនហើយដើរចាប់ដើរអីតាមបញ្ជារបស់គាត់ហ្នឹង ហើយគាត់ហៅថាអង្គភាពពិសេស ។ អង្គភាពពិសេសហ្នឹង ខ្ញុំយល់ថាអ៊ីចឹង ព្រោះគ្មានរៀបចំថា ប៉ែកខាងនេះពិសេសអីណាគ្មានទេ ។

**ស៖** អ៊ីចឹង នៅពេលដែលលោកជាយុទ្ធជនតើលោកទទួលការបណ្ដុះបណ្ដាលពិសេសអីទេនៅពេលដែលលោកធ្វើជាយុទ្ធជននោះ?

**ឆ៖** ខ្ញុំសូមជម្រាបថា ការហាត់រៀនកាលហ្នឹង តាហ៊ី ទេនាំពួកខ្ញុំហាត់រៀន គាត់យកសៀវភៅក្បាច់គុណក្បាច់អីរបស់ចិនយកមក ដែលរើសបានតាមផ្ទះហ្នឹងយកមកបង្រៀនពួកខ្ញុំ ។ ដល់រៀនហើយអីហើយពួកខ្ញុំឲ្យសាកគ្នា ហើយពួកក្រុមរបស់ខ្ញុំវ៉ៃខ្ញុំត្រូវចំមាត់ ខ្ញុំក៏ឈប់ហាត់ឈប់អីទៅ ហើយគេនាំគ្នានៅហាត់ទៀតទៅ ខ្ញុំឈប់ហាត់ឈប់អី ។ ព្រោះមួយទៀត ខ្ញុំពិការជើងខ្ញុំទៅទាត់អីកើត?

**ស៖** ដូច្នេះ លោកបានជម្រាបអង្គជំនុំជម្រះថា នៅថ្ងៃមួយដោយហេតុតែលក្ខណៈស្ថានភាពខាងក្រៅហើយនិងការចាប់ខ្លួនមនុស្ស ហើយលោកក៏បានក្លាយទៅជាប្រធានកងពិសេសនោះ? តើអ៊ីចឹងមែនឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា កម្មាភិបាលដែលគេចាប់ខ្លួនអស់ទៅ នៅសល់គ្នាប៉ុន្មាននាក់ តាហ៊ី គាត់អ្នកចាត់តាំងខ្ញុំទេចាត់តាំងខ្ញុំឲ្យឡើងអនុប្រធានកងរយបណ្ដោះអាសន្នទេ ព្រោះអស់មនុស្សរលីង ហើយហើយខ្ញុំទទួលតែមួយក្រុមទេអ្នកចាំទទួលអ្នកទោស ហើយពេលដែលដឹកជញ្ជូន-- អ៊ូ!ហើយពេលដែល

ទៅចាប់ទៅអីឯណាឯណីក៏ប្រមូលខ្ញីយកកម្លាំងពីខាងក្នុងមកក៏ទៅចាប់ជាមួយគ្នាហ្នឹង ។

[១៤:១១:១៥]

**ស៖** សូមអរគុណលោក ហ៊ីមហ៊ុយ ហើយឥឡូវដែលលោកបានព្យាយាមឆ្លើយសំណួរខ្ញុំ ហើយកុំនិយាយឡើងវិញនូវអ្វីដែលលោកថា មានភារៈទទួលអ្នកទោស ។ អ៊ីចឹង នៅពេលដែលលោកក្លាយទៅជាអនុប្រធាន តើលោកចង់ជម្រាបអង្គជំនុំជម្រះថា តើមានសមាជិកប៉ុន្មាននៅក្រោមបង្គាប់របស់លោកនោះ?

**ឆ៖** ខ្ញុំសូមជម្រាប! ខ្ញុំឡើងអនុប្រធានកងរយបណ្ដោះអាសន្ន វាមានផ្នែក ខ្ញុំទទួលត្រឹមតែមួយក្រុមដែលខ្ញុំនៅទេ ពីព្រោះតាហ៊ិថា អ្នែងទទួលមួយក្រុមហ្នឹង មួយក្រុមចាំទទួលអ្នកទោស ទៅចាប់អ្នកទោស ។ ហើយប៉ែកខាងផ្នែកការពារគឺនៅលើ ប៉េង ទាំងអស់ក្នុងបន្ទប់ ។ ហើយផ្នែកកន្លែង យាមម្ខាងទៀត គឺនៅលើ ស្រ៊ី ។

**ស៖** សូមលោកឆ្លើយសំណួររបស់ខ្ញុំថាតើ មានសមាជិកប៉ុន្មាននាក់ដែលស្ថិតនៅក្រោមការបញ្ជារបស់លោក?

**ឆ៖** ខ្ញុំសូមជម្រាបថាមានតែមួយក្រុមទេ ដែលចាំទទួលអ្នកទោសហ្នឹងដែល តាហ៊ិ ឲ្យខ្ញុំគ្រប់គ្រងមានតែមួយក្រុមហ្នឹង ។

**ស៖** សូមអរគុណ ។ គឺថាមានមួយក្រុម តើមួយក្រុមហ្នឹងមានគ្នាប៉ុន្មាននាក់? សូមបញ្ជាក់?

**ឆ៖** ខ្ញុំសូមជម្រាបថា មួយក្រុមហ្នឹងមានគ្នាជាងដប់នាក់ ប្រហែលជាដប់ពីរ ឬដប់មួយនាក់ ។ វាមានតាំងពីអ្នកជាងឡាន អ្នកបើកឡាន ហើយអ្នកនៅធ្វើការហ្នឹងប៉ុន្មាននាក់ជាមួយគ្នាហ្នឹង ។

**ស៖** អ៊ីចឹងខ្ញុំអាចនិយាយថា លោកជាអ្នកដឹកនាំក្រុមដែលមានសមាជិកដប់ពីរនាក់ ។ លោក ហ៊ីម ហ៊ុយ តើលោកជាមេដឹកនាំដាច់ខាត ឬក៏ថាផ្ដាច់ការឬ? តើលោកអាចកំណត់ខ្លួនឯងបានទេនៅពេលនោះ លោកជាអ្នកដឹកនាំរបៀបម៉េច?

**ឆ៖** ខ្ញុំសូមជម្រាបថា ពួកខ្ញុំមិនមែនជាពួកដាច់ខាតទេ ។ ទាំងអស់ផ្នែកការពារដូចតែគ្នាទាំងអស់ទាំងពួកខ្ញុំ ទាំងការពារអីទាំងអស់ហ្នឹង គឺគេបញ្ជាឲ្យធ្វើអីគឺធ្វើហ្នឹង បើយើងមិនធ្វើតាមគេយើងប្រឆាំងជាមួយគេក៏យើងត្រូវស្លាប់ដែរ ។

**ស៖** ខ្ញុំយល់ហើយ ខ្ញុំយល់ច្បាស់គឺថាលោកត្រូវតែជាឃោធា យើងត្រូវតែទទួលបញ្ជា ហើយត្រូវតែអនុវត្តតាមបញ្ជាពីថ្នាក់លើ។ ប៉ុន្តែ លោកក៏បានបញ្ជាទៅកូនចៅរបស់លោកដែរ។ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថា ខ្ញុំមិនមែនបញ្ជាផ្ទាល់ខ្លួនខ្ញុំទេ ។ ក្រុមខ្ញុំដែលត្រូវទៅដូច តាហ៊ី អ៊ីចឹងគាត់បញ្ជាឲ្យក្រុមខ្ញុំ ហើយគាត់នឹងប្រមូលពួកខ្ញុំទៅទៀត ។ ខ្ញុំមានគ្នាប៉ុន្មាននាក់ គាត់យកប៉ុន្មាននាក់ គាត់ប្រមូលទៅៗជាមួយគ្នាទៅ ។

[១៤:១៥:១៦]

**ស៖** អ៊ីចឹង លោកបានពន្យល់អង្គជំនុំជម្រះថា លោកជាប្រធានក្រុម ។ ប៉ុន្តែលោកមិនដែលបានបញ្ជាទៅកូនអ្នកក្រោមបង្គាប់នោះទេ តើអ៊ីចឹងមែនឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបថាការងារដែលត្រូវចាប់ខ្លួន ឬមួយយ៉ាងម៉េចៗហ្នឹង គឺខ្ញុំមិនបានបញ្ជាដោយខ្លួនខ្ញុំទេ ព្រោះនៅក្រោមការដឹកនាំរបស់ តាហ៊ី ដែលគាត់ទៅជាមួយខ្ញុំ គឺនៅបញ្ជាលើខ្ញុំគឺគាត់បញ្ជាពួកខ្ញុំទាំងអស់គ្នាហ្នឹង ។

**ស៖** ប៉ុន្តែ នៅក្នុងពាក្យឃោធា តាមដែលខ្ញុំដឹង ហ៊ី បញ្ជាមកលោក ហើយលោកត្រូវតែបញ្ជាទៅអ្នកក្រោមបង្គាប់របស់លោក ។ តើអ៊ីចឹងមែនឬទេក្នុងពាក្យឃោធានោះ?

**ឆ៖** ពាក្យឃោធា ដូចខ្ញុំជម្រាបអ៊ីចឹងថា គេឲ្យក្រុមរបស់ខ្ញុំទៅគ្នាប៉ុន្មាន គឺខ្ញុំរៀបចំប៉ុណ្ណឹងនាក់ទៅជាមួយគេ ។ ហើយឈ្មោះអីៗ គេនឹងប្រាប់ឈ្មោះឲ្យយកទៅគ្នាប៉ុន្មាននាក់ឈ្មោះអី ចាំទទួលបញ្ជាគេទៅជាមួយគ្នា ជាមួយគាត់តែម្តង ។

**ស៖** នៅពេលដែលលោកបានទៅជើងឯក នៅពេលដែលលោកបានចូលរួមក្នុងការសម្លាប់ជាមួយក្រុមរបស់លោកនោះ តើលោកបានបញ្ជាទៅអ្នកក្រោមបង្គាប់របស់លោកឲ្យធ្វើការសម្លាប់ទេ តើមែនឬមិនមែន?

**ឆ៖** ខ្ញុំសូមជម្រាបថា ពេលដឹកទៅហ្នឹង គឺពួកខ្ញុំជួយការពារនិងបណ្តើរទៅឲ្យក្រុមគេ ហើយក្រុម បងតេង ដែលជាអ្នកដឹករណ្តៅនិងអ្នកចាំសម្លាប់ ពីព្រោះតាហ៊ី ចែងច្បាស់ណាស់ក្រុមហ្នឹងអត់មានធ្វើអីទេ ចាំតែជីករណ្តៅហើយនិងសម្លាប់ និងកប់ការពារនៅតែកន្លែងហ្នឹង ។

**ស៖** ដូច្នេះ លោកបានព្យាយាមពន្យល់ប្រាប់ខ្ញុំថា កូនចៅរបស់លោកមិនដែលចូលរួមក្នុងការសម្លាប់មនុស្សទេ តើអ៊ីចឹងមែនទេ?

**ឆ៖** គឺក្រុមរបស់ បងតេង ហ្នឹងជាអ្នកសម្លាប់ ការងាររបស់គាត់ដោយឡែកពីពួកខ្ញុំ ពួកខ្ញុំដឹងតែបញ្ជូនយកទៅឲ្យគេនិងកត់ឈ្មោះកត់អីយកមកវិញ ។

[១៤:១៨:០៥]

**ស៖** រហូតមកដល់ពេលនេះ ខ្ញុំបានយល់ហើយប៉ុន្តែលោកមិនបានឆ្លើយសំណួររបស់ខ្ញុំឲ្យច្បាស់ទេ នៅពេលដែលយើងនិយាយពីឋានានុក្រមថ្នាក់របស់យោធា ។ តើលោកអាចបញ្ជាក់ប្រាប់អង្គជំនុំជម្រះបានទេថ្ងៃនេះអំពីឋានានុក្រម ពីលំដាប់លំដោយដែលលោកបានជម្រាបជូនសហចៅក្រមស៊ើបអង្កេតនៅពេលដែលយើងទៅជើងឯកនៅថ្ងៃទី២៦ កុម្ភៈ ២០០៨ គឺ D48/1 កថាខណ្ឌ៧.១ សាក្សី ហ៊ឹម ហ៊ុយ បានរៀបរាប់អ្វីដែលគាត់យល់អំពីឋានានុក្រមក្នុងសម័យនោះ ឌុច គឺជាថ្នាក់លើរបស់ ហ៊ី ដែលជាថ្នាក់លើរបស់ ផល ហើយ ផល នេះជាថ្នាក់លើរបស់ ប៉េង ដែលមាន ប៊ូ នៅក្រោមបញ្ជារបស់ខ្លួន ។ តើអ៊ីចឹងពិតឬទេ?

**ឆ៖** អ្នកដែលថ្នាក់លើផ្នែកការពារគឺ តាហ៊ី ហើយបន្ទាប់មកគឺ ផល ។ ផល ហើយ ប៉េង ។ ប៉េង ហើយ តាំងពី ទុយ តាំងពី ប៊ូ និងសុទ្ធតែប្រធានហើយនិងបញ្ជាការ ។ ហើយដល់ខ្ញុំអនុប្រធានបណ្តោះអាសន្នដោយខ្លួន ។ ស្រ៊ី សមាជិកដោយខ្លួន គឺខ្ញុំពីរនាក់នៅក្រោមគ្នាប៉ុន្មាននាក់ខាងលើហ្នឹង ។

**ស៖** ទាក់ទងទៅនឹងតេង តើនៅក្រោមបញ្ជាគាត់ ឬក៏លោកនៅជាអ្នកបញ្ជាគាត់?

**ឆ៖** ខ្ញុំសូមជម្រាប តាហ៊ី និយាយច្បាស់ដាក់លក្ខខណ្ឌជាផ្នែកត្រឹមត្រូវរបស់គាត់ហើយ គឺកាលពីនៅភ្នំពេញគឺ គាត់ជាអង្គភាពនៅនឹងក្រុមជាមួយពួកខ្ញុំ កងជាមួយគ្នា ក្រោមការដឹកនាំរបស់ខ្ញុំ ដល់ពេលដកជើងឯកគឺត្រូវនៅលើការគ្រប់គ្រងរបស់ តាហ៊ី ទាំងអស់ ។ ទទួលបញ្ជាអីលើ តាហ៊ី ពួកខ្ញុំដាច់ដោយឡែកគឺចាំតែទទួលអ្នកទោសនិងដឹកទៅឲ្យគេ មួយក្រុមផ្សេងដាច់ដោយឡែក ។

**ស៖** ឥឡូវនេះ ខ្ញុំសូមចូលទៅពិនិត្យឡើងវិញនូវទីកន្លែងដែលយើងជួបគ្នាជាមួយជនរងគ្រោះលោក ប៊ូ ម៉េង ។ តើសូមលោកបញ្ជាក់ជាងមុនច្បាស់ជាងមុនបន្តិចទេ ហើយរំឭកឡើងវិញអំពីៗកន្លែងមួយដែលថាបញ្ជាក់ពីដែលថាលោកជិះលើស្មាលោក ប៊ូ ម៉េង ថាលោកអាចពន្យល់បន្ថែមទៀតថាមើលថាវាសភាពការណ៍ហ្នឹងយ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមជម្រាបថា កាលនោះមិនដឹងថាខ្ញុំធ្វើទារុណកម្មគាត់ទេ នឹកឃើញថានិយាយលេងសាក ហ៊ឺ!ចុះតូចៗម្ល៉េះ ។ តូចហើយមានប្រពន្ធ វាធ្លាប់តែមនុស្សធំបានមានប្រពន្ធ គាត់ថាតូចអត់កម្លាំងតូចខ្លាំង ។ ខ្ញុំថាតូចខ្លាំង ចុះបើជិះ ស្ពាយរួចអត់? ថារួចៗ អ៊ីចឹងជិះមើលរួចមិនរួច ដល់ហើយជិះលេងរួចជិះលេងរួច ខ្ញុំថាចុមខ្លាំងអ៊ីចឹងមែន ។ ហើយខ្ញុំក៏មិនដឹងថាកន្លែងនេះជាកន្លែងអីទេ ខ្ញុំធ្វើលេងទេកាលហ្នឹង ។

[១៤:២២:៣២]

**ស៖** តើនៅពេលនោះលោកយល់ថា ជាការសប្បាយចិត្ត ឬក៏រីករាយទេពេលដែលលោកបានធ្វើបែបនោះ ដូចថាជិះស្នាគាត់ ជិះលើក គាត់នោះ?

**ឆ៖** ពេលនោះ ពេលអ៊ីចេះទេ ម្នាក់ថាខ្លាំង ម្នាក់ថាមិនជឿ ។ បើអ៊ីចឹងទាល់តែសាក បើថាគាត់ខ្លាំងទាល់តែសាក សាកជិះៗគាត់លីរួចអ៊ីចឹងមែនៗ បានថារួចអ៊ីចឹងមែន ។ ហើយខ្ញុំក៏ថាជាខ្ញុំធ្វើនេះធ្វើលេងដែរ ធ្វើសាកចង់ដឹងថា គាត់ខ្លាំងអ៊ីចឹងមែនឬមួយមិនខ្លាំង ។

**ស៖** ហើយជឿជាក់ក្នុងចិត្តពេលនោះថា តើលោក ប៊ូ ម៉េង ហ្នឹងគាត់ពេញចិត្តអ៊ីចឹង? តើលោកគិតថាលោក ប៊ូ ម៉េង ហ្នឹង គាត់ពេញចិត្តនឹងប្រកួតពាក្យសម្ដីជាមួយលោកអ៊ីចឹងទេពេលនោះ?

**ឆ៖** កាលនោះ គាត់ៗថាគាត់ខ្លាំងមិនមែនគាត់លីមិនរួច គាត់លីរួច ។ ពេលនោះគាត់និយាយអ៊ីចឹងជាមួយខ្ញុំ អ៊ីចឹងសាកគ្នា លីរួចមិនរួច ។ ហើយខ្ញុំពេលហ្នឹងក៏ខ្ញុំធ្វើលេងដែរ ខ្ញុំមិនមែនថាទៅធ្វើដោយគំរាមកំហែងធ្វើគាត់ណាក៏គ្មានដែរ ។

**ស៖** ចំពោះលោក លោកថាជាការធ្វើលេង ប៉ុន្តែចំពោះគាត់វិញ គាត់គិតខុសពីលោក ។

**ឆ៖** ខ្ញុំឈប់និយាយហើយ ព្រោះខ្ញុំនិយាយប៉ុន្មានសារឿងហ្នឹងហើយ ។

**ស៖** តាមពិត ចាប់តាំងតែយើងបានស្ដាប់នៅទីនេះជាមួយការផ្ដល់សក្ខីភាពហើយនិងលោក ប៊ូ ម៉េង ផងហើយខ្ញុំអាចនឹងអានឡើងវិញអំពីចំណុចដែលលោកបាននិយាយពីព្រឹកមិញនេះ ។ ដូច្នេះ នៅថ្ងៃទី២៧ កុម្ភៈ ឆ្នាំ២០០៨ យើងបានទៅទួលស្លែងជាមួយសហចៅក្រមស៊ើបអង្កេតមួយឆ្នាំកន្លះនៅក្នុងអត្ថបទលាយលក្ខណ៍អក្សរ នៅក្នុងឧបសម្ព័ន្ធ D48/2 ហើយនៅក្នុងកថាខណ្ឌ៨.៧ ដែលបាននិយាយដូចខាងក្រោមនេះ ៖

ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ប៊ូ ម៉េង បានបញ្ជាក់ថា គាត់រៀបរាប់អំពីទារុណកម្មដែលគាត់បានទទួលរង គឺគេបានប្រាប់គាត់ឲ្យបន្ទាបខ្លួនចុះ ហើយគាត់បញ្ជាក់ថា ហ៊ីម ហ៊ុយ, ប៉េង បានវាយគាត់ ហើយនិង ម៉ម ណៃ ហើយនិង ហ៊ា ផងដែរ ដោយប្រើដំបងឫស្សី ហើយនិងរំពាត់ផ្ដៅ ។ គាត់បាននិយាយថា ពួកគេបានបង្ហាញដំបងទៅគាត់ ហើយសួរគាត់ថាអ្នកឯងយកដំបងមួយណា? ដើម្បីឲ្យគេវាយរូបគាត់នោះ។ គាត់និយាយថា ហើយគេវាយគាត់លើខ្នង ហើយនិងបង្វិលខ្លួនដើម្បីគេចដំបងនោះហើយក៏បានៗស៊កដំបងទៅលើខាងក្រោយខ្នង ហើយអ្នកខ្លះនិយាយថា “កុំធ្វើទារុណកម្មឲ្យគាត់ស្លាប់យើងត្រូវការឲ្យគាត់គូររូប ប៉ុល ពត” ។ កថាខណ្ឌ៨.៨ សាក្សី ម៉ម ណៃ និយាយថា គាត់មិនបានចងចាំថាគាត់បានចូលរួមនៅក្នុងការសួរចម្លើយជាមួយ ប៉េង, ទិត ឬ ហ៊ា ទ ។ គេបានចាត់តាំងឲ្យគាត់សួរ

ចម្លើយពួកអ្នកទោសវៀតណាម ។ កថាខណ្ឌ៨.៩ សាក្សី ហ៊ីម ហ៊ុយ ទទួលស្គាល់ថា គាត់បានចូលរួមក្នុងការសួរចម្លើយនិងធ្វើទារុណកម្ម ហើយគាត់បានបន្ថែមទៀតថា តាមធម្មតាគាត់មិនត្រូវចូលរួមសួរចម្លើយទេ គឺគ្រាន់តែយាមនៅបរិវេណនៅខាងក្រៅតែប៉ុណ្ណោះ ។ គាត់និយាយថា គាត់ហើយបើសហចៅក្រមស៊ើបអង្កេតបានដាក់ក្នុងអព្ភន្តរ ដកស្រង់សម្តីរបស់លោកហើយបើកអព្ភន្តរ "គាត់បានភ្លេចរឿងទាំងអស់នេះហើយតែគាត់នៅតែទទួលស្គាល់ដដែល" ។ ដូច្នេះ លោក ហ៊ីម ហ៊ុយ តើពិតដែរឬទេការដែលលោកសុំឲ្យលោក ប៊ូ ម៉េង បន្ទាបហើយជិះពីលើគាត់នោះជាល្បែងលេងសើចដែរឬទេ?

**ឆ៖** ខ្ញុំសូមជម្រាបប៉ុន្នានសាថា កាលនោះខ្ញុំក៏មិនមែនដឹងថារឿងហ្នឹងវារបៀបម៉េចដែរ ខ្ញុំថាធ្វើនេះធ្វើលេង ហើយភ្ញាល់គ្នាទេកាលហ្នឹងនោះ ។ ហើយមួយទៀតរឿងសួរចម្លើយសួរអី ខ្ញុំអត់មានទៅជាផ្នែកអ្នកសួរចម្លើយអីទេ ។

**ស៖** លោក ហ៊ីម ហ៊ុយ ព្រឹកមិញលោកនិយាយថា លោកជាជនរងគ្រោះដែលលោកចង់មករកយុត្តិធម៌ ហើយចង់បានយុត្តិធម៌ ហើយខ្ញុំយល់ស្របជាមួយលោកដែលថា លោកមិនជ្រើសរើសស្ថានភាពមួយដែលថា លោកធ្លាក់ទៅក្នុងស្ថាបភាពនោះ? ដូច្នេះចំពោះខ្ញុំ តើវាត្រឹមត្រូវដែរនេះទេក្នុងការនិយាយថា វាជាប្រព័ន្ធមួយឧក្រិដ្ឋដែលក្នុងប្រព័ន្ធនេះលោកបានចូលរួម ហើយលោកអាចបំពេញការងារដោយសារតែនៅគ្រប់ជាន់ថ្នាក់នៃប្រព័ន្ធនេះ គឺយើងមានឃើញតាំងពីប្រធាន តាំងពីថ្នាក់តូចដែលធ្វើការចេញបញ្ជាសម្លាប់និងទទួលបញ្ជាអីផ្សេងៗ ។

**ឆ៖** ខ្ញុំមិនយល់ទេ សូមឃោបល់ម្តងទៀតមក ។

**ស៖** ខ្ញុំព្យាយាមសួរនិងធ្វើការសម្រួលនូវសំណួររបស់ខ្ញុំ ។ ឌុច បាននិយាយនូវប៉ុន្នាននាទីមុនថាលោកជាកម្មាភិបាលមួយរូបដែលមានតំណែងនៅក្នុងកងអនុសេនាតូច តើលោកយល់ស្របជាមួយខ្ញុំដែរឬទេ? ក្នុងការលើកឡើងថា រាល់បុគ្គលទាំងឡាយនៅក្នុងខ្សែបញ្ជាមានតួនាទី និងដើរតួនាទីរបស់ខ្លួនហើយបុគ្គលនីមួយៗស្ថិតនៅក្នុងប្រព័ន្ធដ៏ឧក្រិដ្ឋមួយ គឺអ្នកទាំងអស់នោះ គឺគោរពបញ្ជាហើយអនុវត្តទៅតាមបញ្ជារបស់ថ្នាក់លើ ។

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា អ្នកណាក៏ដោយដែលនៅកន្លែងហ្នឹងគេបញ្ជាឲ្យធ្វើអីគឺធ្វើហ្នឹង បើមិនធ្វើមិនធ្វើតាមគេគឺស្លាប់ហើយ ។

**ស៖** លោក ហ៊ីម ហ៊ុយ តើនរណាគេទទួលខុសត្រូវស-២១? តើអ្នកណាគេជាប្រធានស-២១? តើលោកដឹងដែរឬទេ?

**ឆ៖** បាទ, តាឌុច ប្រធានស-២១ ។

**ស៖** សំណួររបស់ខ្ញុំបន្តទៀត តើពីណាគេនៅពីលើស-២១?

**ឆ៖** បាទ, គឺ សុន សេន ហើយក្រោយមកទៀត គឺខ្ញុំអត់ដឹងថាអ្នកណាៗទេ ។

**ស៖** លោក ហ៊ីម ហ៊ុយ ដោយសារតែការទទួលខុសត្រូវរបស់លោក ហើយនិងលោកធ្វើដំណើរទៅគ្រប់កន្លែងនៅក្នុងប្រទេសរួមទាំងភ្នំពេញផងដែរនោះ ហើយលោកបានទៅជិតព្រំដែនវៀតណាមផងដែរ ។ លោកបានជម្រាបយើងខ្ញុំថា លោកមិនពេញចិត្តការងាររបស់លោកទេ លោកមានការភ័យខ្លាចនឹងការងាររបស់លោក ។ ហេតុអ្វីបានជាលោកមិនព្រមគេចចេញពីការងារនោះ? ហេតុអ្វីបានជាលោកមិនបោះបង់ចោលការងាររបស់លោក? ដូចដែលបុគ្គលដទៃទៀតបានធ្វើនៅពេលដែលលោកទៅដល់ក្បែរព្រំដែនហើយនោះ?

[១៤:៣៣:៤៩]

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពេលនោះគឺកងទ័ពខ្មែរវៃជាមួយកងទ័ពវៀតណាមហ្នឹង គឺខ្ញុំទៅរត់ចូលម៉េច? បើម្ខាងវៃម្ខាងអ៊ីចឹង ហើយថាខ្ញុំធ្វើការនៅទួលស្លែងហ្នឹង ព្រោះខ្ញុំឃើញគុកហើយបានខ្ញុំសូមលោកតា សុន សេន ហ្នឹងចេញទៅទ័ពវិញ សុខចិត្តទៅច្បាំងគ្នាងាប់ចោលទៅកុំនៅគុកហ្នឹង នៅគុកចៀសងាប់មិនរួចទេ ។ កន្លែងហ្នឹងហើយដែលខ្ញុំថា មិនចង់នៅគុកហ្នឹងភ័យខ្លាចព្រោះកន្លែងនេះវាគុក អ៊ីចឹងហើយ សុន សេន មិនឲ្យខ្ញុំចេញទៀត ។ ខ្ញុំសួរថា "អ៊ំៗ សុំអ៊ំឯងទៅទ័ពវិញហើយ" សួរថា "មិត្តឯងប៉ានវៃយួនអត់?" ថា "ប៉ានអ៊ំ" ។ នឹកឃើញថាចង់ចេញពីហ្នឹងទៅទ័ពងាប់ចោលទៅកុំឲ្យងាប់ជាខ្សែចង្វាក់ដល់ម៉ែឪបងប្អូនខ្ញុំ ។

**ស៖** ដូច្នេះ អ្វីដែលលោកកំពុងតែជម្រាបអង្គសវនាការថា ទោះបីជាលោកមានរថយន្តក៏ដោយ ឬក៏ដែលអនុញ្ញាតឲ្យលោកចេញពីភ្នំពេញ ហើយលោកមានលិខិតដើរផ្លូវក៏ដោយដែលអនុញ្ញាតចេញពីភ្នំពេញ ។ ទោះបីជាលោកមានចំណុចទាំងអស់នេះក៏ដោយលោកមានអារម្មណ៍ថា លោកមិនអាចគេចចេញពីស-២១ ទេ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ទោះបីខ្ញុំមានលេខហ្នឹងក៏ដោយ ហើយលេខនោះក៏ខ្ញុំមិនកាន់ខ្លួនខ្ញុំដែរ គឺ ស្រ៊ឹម ដែលអ្នកបើកឡានទេ កាន់ហ្នឹង ហើយមួយទៀតបើខ្ញុំរត់ទៅខ្មែរហើយនិងយួនទំនាស់គ្នាវៃគ្នាអ៊ីចឹង ខ្ញុំចូលទៅគេថា អាពត ក៏ងាប់អ៊ីចឹងខ្ញុំម៉េចប៉ានរត់ទៅ ។ ហើយមួយទៀត បើខ្ញុំរត់ទៅខាងនេះថាខ្ញុំ-- ថាម៉ែឪខ្ញុំ ខ្ញុំរត់ចូលខ្មាំងងាប់ម៉ែឪខ្ញុំទៀត ។ អ៊ីចឹងរកគន្លឹះដោះស្រាយមិនចេញវាចេះតែនៅៗ

អ៊ីចឹង ។

**ស៖** ដូច្នេះហើយលោកមានអារម្មណ៍ថា លោកគឺជាជនរងគ្រោះនៅក្នុងប្រព័ន្ធដ៏ឧក្រិដ្ឋនេះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា ពួកខ្ញុំទាំងអស់គ្នាក៏ជាអ្នករងគ្រោះដែរ បាទព្រោះពួកខ្ញុំទោះបីធ្វើការក៏ដោយអីក៏ដោយ ក៏នៅគេចាប់សម្លាប់ចោលបន្តកន្ទុយគ្នាអ៊ីចឹង ។ ការជ្រើសរើសដែលចេញពីហ្នឹង គឺអត់មានទេ តែចេញពីទ័ពទៅមូលដ្ឋានក៏អត់ទទួលស្គាល់ដែរ ។ បើចេញពីនេះទៅទ័ពៗទទួលស្គាល់គឺខ្ញុំចេញហើយ ព្រោះសុំគេមិនឲ្យមិនឲ្យចេញអ៊ីចឹង ហើយមើលម្នាក់ៗឃើញតែចូលគុកស្លាប់ៗអ្នកធ្វើការហ្នឹង ។ វាពិបាកដែរកន្លែងអស់ហ្នឹង ។

**ស៖** លោកដឹងថា អតីតមេស-២១ នោះ ដែល ណាត នោះ-- ជា ណាត នោះគាត់ក៏ត្រូវបានគេសម្លាប់នៅស-២១ ដែរឬទេ?

[១៤:៣៧:៥៧]

**ឆ៖** បាទ, ខ្ញុំសូមបញ្ជាក់ម្តងទៀត អ្នកណាគេ?

**ស៖** គឺអតីតប្រធាន ស-២១ គឺ ណាត ។

**ឆ៖** បាទ, តាណាត ហ្នឹង គឺអត់មានមកជាប់គុកនៅស-២១ នេះទេ មិនដឹងគាត់ជាប់នៅណាខ្ញុំអត់ដឹងទេ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ខ្ញុំអាចឆ្លើយថា គាត់ត្រូវបានគេឃុំនិងសម្លាប់ចោលនៅស-២១ ក្រោយពេលដែលគាត់ជាប្រធាន ស-២១ ។ សូមអរគុណលោកសាក្សី ខ្ញុំពុំមានសំណួរនោះទៀតទេ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះថែមទៀតដែរឬទេ?

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំចង់សួរសំណួរ-- មិនសួរសំណួរទៅកាន់សាក្សីនោះទេ ហើយខ្ញុំចង់សូមសួរសំណួរទៅកាន់ជនជាប់ចោទប្រសិនបើអនុញ្ញាត ។ លោក កាំង ហ្កេកអ៊ាវ តើលោកអាចបញ្ជាក់ដែរឬទេថា-- ហើយគឺថា សាក្សីរូបនេះ គឺត្រូវបានបង្ខំចេញពីស-២១ ហើយទៅឲ្យនៅព្រៃស ហើយប្រសិនបើអ៊ីចឹងមែននោះ ថា

តើនរណាគេជាអ្នកសម្រេចឲ្យគាត់ទៅស-២៤? ហើយមូលហេតុអ្វីបានជាគេដកគាត់ទៅស-២៤? តើដោយសារតែគេតម្រូវឲ្យគាត់ធ្វើការអប់រំឬដែរទេ? ឬក៏មូលហេតុអ្វីបានគេតម្រូវឲ្យគាត់ទទួលការអប់រំបន្ថែមនោះ?

**ជនជាប់ចោទ៖**

លោកចៅក្រមជាទីគោរព! តាំងពីខ្ញុំឡើងជាប្រធានមន្ទីរ ស-២១ ខ្ញុំឃើញមិត្ត ហ៊ុយ នេះសាក្សីរូបនេះដែលនៅចំពោះមុខអង្គជំនុំជម្រះយើងនេះ ជាអនុប្រធានអនុសេនាតូចកងពិសេស ។ ហើយពាក្យកងពិសេសនេះ ជាពាក្យដែលខ្ញុំក៏ប្រើ មិត្តហ៊ី អនុប្រធានខ្ញុំក៏ប្រើ ណាត ក៏ប្រើ លោកគ្រូ សុន សេន មេយើងខ្ញុំទាំងអស់គ្នាហ្នឹងក៏ប្រើ ហើយដែលម្សិលមិញលោកសាក្សីរូបនេះ បានមានប្រសាសន៍ថា កាលពីសម័យសង្គ្រាមគេប្រើហៅថា “កងរើសម្រុក” ។

[១៤:៤១:២៩]

ដូច្នេះខ្ញុំត្រឡប់មកវិញ តាំងពីខ្ញុំឡើងជាអនុប្រធាន-- ឡើងជាប្រធាន ស-២១ ខ្ញុំស្គាល់មិត្ត ហ៊ុយ ជាអនុប្រធានអនុសេនាតូច ហើយជាអនុប្រធានអនុសេនាតូចដែលយើងខ្ញុំទាំងពីរនាក់ គឺខ្ញុំ និងមិត្ត ហ៊ុយ-- (សូមទោស) គឺខ្ញុំហើយនិង ហ៊ី ជឿទុកចិត្ត ។ ខ្ញុំប្រើបុគ្គលរូបនេះរហូតដល់ថ្ងៃ៧ មករា នៅពេលដែលយួនចូលមក ។ នេះខ្ញុំបានបញ្ជាក់ជូនលោកប្រធានម្តងរួចមកហើយ ។ សូមអរគុណ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំដូចជាយល់ថា លោកហាក់ដូចជាមិនសូវយល់សំណួររបស់ខ្ញុំ ។ សាក្សីបានជម្រាបយើងថា នៅពាក់កណ្តាលឆ្នាំ១៩៧៨ គាត់បានចាក់ចេញពីស-២១ ហើយទៅជាប់នៅព្រៃស ។ អ្វីដែលខ្ញុំចង់ដឹងនោះគឺថា គាត់លែងជាអនុប្រធានកងពិសេសទៀតហើយ ។ ហើយថាតើការសម្រេចដកគាត់នោះគឺដោយសារតែចង់យកគាត់ទៅអប់រំ ឬយ៉ាងម៉េច? ហើយអ្នកណាគេជាអ្នកសម្រេចយកគាត់ទៅព្រៃស?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំឆ្លើយនេះឆ្លើយរបៀបមិនចំពោះៗ បានន័យថា ខ្ញុំឃើញបុគ្គលនេះនៅបម្រើការងាររហូតដល់ថ្ងៃ ៧ មករា ។ បានន័យថា ខ្ញុំបាទក៏ដូច មិត្តហ៊ី ក៏ដូចខាងលើអត់បានបញ្ជូនមិត្ត ហ៊ុយ ទៅស្រែទេ ។ អត់មានបញ្ជូនទៅសោះ នេះសូមលោកបញ្ជាក់ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ នៅក្នុងការយល់ឃើញរបស់លោក គឺសាក្សីរូបនេះមិននិយាយការពិតទាំងស្រុងនោះទេ ។

**ជនជាប់ចោទ៖**

ខ្ញុំនៅតែបញ្ជាក់ថា បុគ្គលរូបនេះជាកម្មាភិបាលមួយដែលគណៈកម្មាធិការស-២១ ជឿទុកចិត្ត ។ ដូច្នេះ សក្ខីកម្មរបស់គាត់ក្នុងបញ្ហានេះ ខ្ញុំមិនជឿ មិនមានភស្តុតាង ។

**ប្រធានអង្គជំនុំ៖**

ម៉េចទៅលោកសហព្រះរាជអាជ្ញា? ចង់មានយោបល់អីកាត់ចៅក្រមកំពុងតែសួរ?

[១៤:៤៥:០៤]

**លោក វីលៀម ស្មីត៖**

ខ្ញុំសូមអភ័យទោស ខ្ញុំគិតថា ចៅក្រមឡាវែន៍ នោះ គាត់បញ្ចប់រួចហើយ ដូច្នេះទើបខ្ញុំកាត់ ប៉ុន្តែយ៉ាងណាក៏ដោយ គឺខ្ញុំរង់ចាំគាត់បញ្ចប់សិន ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំចង់ឲ្យលោកៗ ហ៊ឹម ហ៊ុយ មានឱកាសក្នុងការឆ្លើយតបទៅនឹងអ្វីដែល ឌុច បានលើកឡើង ហើយនៅពេលនេះ ខ្ញុំពុំមានសំណួរអ្វីទៀតទេ ។

**ស៖** លោកសាក្សី លោក ហ៊ឹម ហ៊ុយ តើលោកបានឮនូវអ្វីដែលជនជាប់ចោទបាននិយាយដែរឬទេ? នៅក្នុងការយល់ឃើញរបស់គាត់ គឺលោកបន្តធ្វើការនៅស-២១ រហូត ហើយលោកបន្តទៅទទួលខុសត្រូវជាអនុប្រធានកងពិសេសរហូតដល់ថ្ងៃ០៧ ខែមករា ឆ្នាំ១៩៧៩ ។ តើទាំងអស់នេះ គឺជាការពិតដែរឬទេ? ឬក៏លោកនៅរក្សានូវអ្វីដែលលោកបាននិយាយ? ហើយប្រសិនបើលោកនៅរក្សាជំហររបស់លោក ថាតើលោកត្រូវបានគេចាប់ខ្លួនយ៉ាងម៉េច? ហើយស្ថិតនៅក្នុងស្ថានភាពណាដែលគេនាំលោកទៅកាន់ព្រៃសនោះ?

**ឆ៖** បាទ,ខ្ញុំសូមជម្រាប! ពាក់កណ្ដាលឆ្នាំ៧៨ គេដកខ្ញុំទៅជាមួយកងការពារពីរក្រុមទៅធ្វើស្រែនៅកន្លែងចំផ្ទះ លន់ ណុន មកកើតមក ។ ទៅផ្ដាក់ដីផ្ដាក់អី លើកភ្លឺស្រែ លើកអី ហើយរកគោរកអី ។ កាលមុនគោនៅកន្លែង បងហ៊ុយ ស្នើគោខាងហ៊ុយយកមកភ្ជួរស្រែ ភ្ជួរអីហ្នឹង ។ ហើយដល់ពេលសាបស្រូវ សាបអី គឺខ្ញុំសាបស្រូវ សាបអីហ្នឹង អាកន្លែងណាខ្លះព្រោះ ។ ហើយម៉ាស៊ីនដែលយកពីភ្នំពេញទៅ មានម៉ាស៊ីនស្ដាបយ៉ាមួយបើកបូមទឹករហូតដល់ផ្ទះ ។ ហើយមានម៉ាស៊ីនមួយទៀត កែច្នៃគឺម៉ាស៊ីនឡាន កែច្នៃដុតធ្យូង សែងស្នែងបួនទៅស្នែងប្រាំមួយម៉ាស៊ីនឡានហ្នឹង ។ ពួកខ្ញុំនៅរហូតដល់ស្រូវទុំ ធ្វើស្រូវហ្នឹងទាល់ទុំៗហើយក៏រៀតណាមវៃចូលមក ។ ពួក តាឌុច ហ្នឹង មួយ តាហ៊ី មួយពួក

ប៉េង ជាមួយពួក ប៊ូ ពួកអីនាំគ្នាទៅ កាត់ៗន៎ែ!អាកន្លែងគេដាក់កាំភ្លើងធំនោះ នៅអាកន្លែងចំការដូង នៅកន្លែងចំការដូងហ្នឹង ។ ពួកខ្ញុំក៏-- ពួកដែលទៅហ្នឹងប្រាប់ខ្ញុំថា ចំការដូងកន្លែងកាំភ្លើងធំ កាំភ្លើងអីហ្នឹងមក ។ ហើយពួកខ្ញុំនៅនោះ រៀបបាយ រៀបអីស៊ី អត់បានស៊ីបាយស៊ីអីទេ បាយនៅពេញៗតុអស់គ្នា ។ អត់មានណាស៊ីបាយមួយ តែប្រមូលពួកខ្ញុំហ្នឹងទៅ ខ្ញុំបានតែអាវដៃខ្លី ប្រឌិបដៃខ្លីមួយ ហើយនិងខោមួយ ហើយកន្សែងមួយ ហើយអង្រឹងមួយតែប៉ុណ្ណឹងទេ ។ ប្រមូលពួកខ្ញុំអ៊ីចឹង ទៅព្រៃសទៀត ទៅព្រៃសទៅ ប្រមូលព្រៃសរត់ទៅទៀត ។ ខ្ញុំអត់មាននៅភ្នំពេញរហូតដល់បែកទេ ។ ខ្ញុំស្បថផ្ដាច់ជីវិតតែម្ដង ។

[១៤:៤៨:១៨]

**ស៖** លោក ហ៊ីម ហ៊ុយ ខ្ញុំព្យាយាមធ្វើយ៉ាងណា អង្គសវនាការសាលាដំបូងយល់លោកឲ្យបានត្រឹមត្រូវ ។ នៅពេលដែលគេបញ្ជូនលោកទៅវាលស្រែនោះ ថាតើវាជាព្រៃសដែរឬទេ? ហើយគេបញ្ជូនលោកទៅនោះ ដើម្បីអប់រំលោក ឬក៏យ៉ាងម៉េច? ហើយគេបញ្ជូនលោកទៅទីនោះដោយសារតែគេចាប់ខ្លួនលោក ឬក៏លោកទៅទីនោះដើម្បីបំពេញការងាររបស់លោក?

**ឆ៖** បាទ, ទៅហ្នឹង គឺគេឲ្យខ្ញុំធ្វើស្រែ លែងឲ្យខ្ញុំនៅ ។ មួយទៀត ខ្ញុំនឹកឃើញថា កាលខ្ញុំនៅភ្នំពេញហ្នឹង គាត់ថា ខ្ញុំ, ណុប ងួន ឆ្លើយដាក់ខ្ញុំ ។ ខ្ញុំក្រោយមកខ្ញុំទៅធ្វើស្រែ បានខ្ញុំភ័យខ្លួនខ្ញុំរហូតថា ទៅធ្វើស្រែ គឺតែមិនស្រួលគេចាប់ទៀតហើយ ចាប់ដូចអ្នកទោសដែលគេហៅថា ឲ្យទៅធ្វើការអ៊ីចឹង ។ បោកអ៊ីចឹង បានខ្ញុំភ័យរហូត ។ ចាំ បងហ៊ុយ ក៏ខ្ញុំដឹងដែរ ខ្ញុំមកអត់ទាន់ផង ដល់ចាប់ បងហ៊ុយ ខ្ញុំញាក់បណ្ដោយ ។ តែចាប់ បងហ៊ុយ គឺចាប់ខ្ញុំទៀតហើយ ចាប់ខ្ញុំ ក៏ចាប់ តាហ៊ី ចាប់ឡើងអស់ ។

**ស៖** លោកនៅតែមិនទាន់ឆ្លើយនឹងសំណួររបស់ខ្ញុំ ។ គេចាត់តាំងឲ្យលោកទៅស្រែនៅព្រៃសអ៊ីចឹងដើម្បីឲ្យយើងយល់ច្បាស់នោះ តើគេចាប់ខ្លួនលោកដែរឬទេនៅពេលដែលគេបញ្ជូនលោកទៅព្រៃស?

**ឆ៖** បាទ, ខ្ញុំជម្រាបថា គេអត់មានចាប់ខ្លួនខ្ញុំទេ គេឲ្យខ្ញុំទៅ តាហ៊ីអ្នកឲ្យខ្ញុំទៅហ្នឹង ។ មិនមែនគាត់ឲ្យខ្ញុំទៅ តាហ៊ី ឲ្យខ្ញុំទៅ ។

**ស៖** ថាតើលោកទៅទីនោះតាមរបៀបណា? ពេលដែលលោកនិយាយថា នៅទីនោះ ថាតើគឺជាទីតាំងព្រៃស ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ, ខ្ញុំសូមជម្រាបថា មិនមែនទីតាំងព្រៃស គឺទីតាំងខាងត្បូងជើងឯកហ្នឹង ហើយទៅផ្ដាក់ដីផ្ដាក់អី ទៅកាប់ព្រៃកាប់អីនៅជិតវត្តព្រៃខ្លឹង ត្រឹមហ្នឹងរហូតមកដល់ខាងលិចផ្ទះ លន់ ណុន ទៀត ហើយអ៊ីចឹងមកដល់ៗជិតជើងឯក កន្លែងធ្វើស្រែហ្នឹង ។ ហើយប្រឡាយមួយទៅលិចកើតហ្នឹង អាហ្នឹង

សម្រាប់បូមទឹក ។

**សៈ** តើគេតាមដាលោកដែរឬទេ នៅពេលនោះ? គឺថា ហ៊ុយ ស្រែ នៅពេលនោះ តើគាត់នៅតែទទួលខុសត្រូវនៅស្រែនោះដដែល ឬក៏យ៉ាងម៉េច?

[១៤:៥១:៤១]

**ឆៈ** បាទ, បងហ៊ុយ កាលហ្នឹង គាត់នៅធ្វើការនៅស្រែដដែល ហើយខ្ញុំនៅធ្វើការនៅអាកន្លែងជើងឯកហ្នឹង ថ្ងៃមួយតាហ៊ា ឲ្យនីរសារគាត់យកឡានទៅយកខ្ញុំមក យកមកប្រជុំនៅមុខគុកហ្នឹង កន្លែងផ្ទះគាត់ ហើយខ្ញុំដើរចូលទៅនឹកគិត-- សួរនីរសារគាត់តាមផ្លូវមក "ចុះបងហៅអញធ្វើអីហ៎ា" "អត់ដឹងដែរ" ដល់ហើយខ្ញុំចេះតែនឹកឃើញថា ហៅសង្ស័យចាប់ទៀតហើយ ។ ដល់ហើយខ្ញុំចេះតែមកៗដល់ពេលដើរចូលកន្លែងផ្ទះគាត់ហ្នឹង ប៉េង នៅពីក្រោយ គាត់ហៅចូលក្នុងផ្ទះគាត់ ខ្ញុំនៅងេងង៉ាងៗអត់ហ៊ានចូល ខ្ញុំថា ខ្ញុំចប់ហើយមួយសានេះ គឺចាប់ហើយ ។ យូរខ្ញុំភ័យខ្លួន ភ័យឡើងត្រជាក់ខ្លួនអស់អាលឹងហើយឡើងទុន ហើយថាមិនបាច់ទេ ប៉េង មិនបាច់ចាប់ទេ គ្រាន់តែគាប់កខ្ញុំងាប់ហើយ ។ បើវាមាឌប៉ុនណាណី ហើយខ្ញុំតូច ។ ដល់អ៊ីចឹង តាហ៊ា ចេះតែហៅចូលទៅ ។ ចូលទៅខ្ញុំបង្ខំខ្លួនថា ចប់ ហើយចូលទៅចប់ហើយ ។ ទៅដល់ផ្អែកជញ្ជាំងផ្ទះថ្មៗអង្គុយដីហ្នឹង គាត់ថា "ឥឡូវ! រឿងអាណានៅស្រែដឹងស្រែហ៎ា អត់មានអាស្រែភ្នំពេញ អាភ្នំពេញដឹងស្រែវិញ" ខ្ញុំថា រឿងប៉ុណ្ណឹងសោះ ម៉េចក៏ហៅខ្ញុំមកធ្វើអី បើសរសេរសំបុត្រប្រាប់ខ្ញុំថា "ឥឡូវហ្អែងធ្វើស្រែឲ្យដឹងធ្វើស្រែ កុំដឹងរឿងភ្នំពេញ" ។ រួចហើយ តាហ៊ា ក៏ប្រាប់អ៊ីចឹងឲ្យខ្ញុំចេញមកវិញថា "ហ្អែងអត់ស្រួលខ្លួនអ៊ីចឹងហ្អែងសុំថ្នាំពេទ្យយកផឹកទៅ" ។ ហើយខ្ញុំចេញមកវិញ ក៏ខ្ញុំសុំថ្នាំពេទ្យថ្នាំអីទៅឡាននីរសារគាត់ ឈ្មោះ ថាៗ ហ្នឹងបើកឡានជូនខ្ញុំទៅវិញទៅ ។

**សៈ** ប្រសិនបើខ្ញុំយល់ពីលោកត្រឹមត្រូវនោះ គឺហ៊ុយ ស្រែ គឺគាត់នៅតែទទួលខុសត្រូវនៅទីនោះនៅពេលដែលលោកនៅស្រែ នេះគឺជាអ្វីដែលលោកទើបតែនិយាយឬយ៉ាងម៉េច? ដូច្នេះ ចំណុចវាមានន័យថា លោកលែងទទួលខុសត្រូវនៅកងពិសេសទៀតហើយ នៅពេលដែលគេចាប់ ហ៊ុយ ស្រែ ។ ហើយលោកមិនបានពាក់ព័ន្ធ ឬក៏ចូលរួមនៅក្នុងការចាប់ខ្លួន ហ៊ុយ ស្រែ ទេ គឺលោកទៅផ្ទះមួយដែល ហ៊ុយ នោះត្រូវបានចាប់ខ្លួន ។

**ឆៈ** បាទ, ខ្ញុំសូមជម្រាប ខ្ញុំផ្ទះនៅកើតនុ៎ង ហើយគេចាប់បងហ៊ុយ ចាប់នៅកន្លែងផ្ទះ លន់ ណុនទេ គេហៅចាប់ត្រឹមហ្នឹង ។ ហើយខ្ញុំផ្ដាច់ខ្លួន តាហ៊ា នោះឲ្យខ្ញុំទៅធ្វើស្រែ លែងឲ្យដឹងឮនៅភ្នំពេញទៀតហើយ ធ្វើស្រែដឹងតែធ្វើស្រែទៅ ។ នៅខាងត្បូងជើងឯកហ្នឹង ដកកម្លាំងការពារដែលកម្លាំងណាខ្សោយ

ពីរក្រុមហ្នឹងទៅនៅជាមួយខ្ញុំធ្វើស្រូវហ្នឹង រហូតដល់បែក ។

**ស៖** ជាថ្មីម្តងទៀតលោក ហ៊ឹម ហ៊ុយ នៅពេលដែល ហ៊ុយ ស្រែ ត្រូវគេចាប់ខ្លួន តើលោកទទួលភារកិច្ចអ្វីនៅពេលនោះ? ថាតើលោកនៅជាអនុប្រធានដដែល ឬក៏នៅស្រែ? ប្រសិនបើលោកនៅស្រែថា តើលោកនៅតែស្នាក់នៅក្នុងផ្ទះរបស់លោកដដែល ឬក៏យ៉ាងម៉េច?

[១៤:៥៥:២៤]

**ឆ៖** បាទ, ខ្ញុំនៅហ្នឹង គឺមួយក្រុមៗគឺមានផ្ទះនៅទាំងអស់គ្នា នៅកន្លែងធ្វើស្រែហ្នឹង ហើយចាប់បងហ៊ុយ ហ្នឹង គឺចាប់ជិតបែកនេះទេ ចាប់គាត់ជិតបែកហ្នឹង ប្រហែលជាពីរខែ បីខែអាម៉េចទេកាលហ្នឹង ត្រឹមហ្នឹង ។

**ស៖** ថានៅពេលនោះ លោកធ្វើអ្វី? លោកមានភារកិច្ចអ្វីដែរ?

**ឆ៖** បាទ, ខ្ញុំអត់មានភារកិច្ចអ្វីទេ ព្រោះចាប់ហ្នឹង ពួកភ្នំពេញទៅចាប់ទាំងអស់ ។ ពួកប៊ូ ពួកអីទៅពីភ្នំពេញទាំងអស់ទៅចាប់ ។

**ស៖** ដូច្នេះ លោកមិនពាក់ព័ន្ធនៅក្នុងការចាប់ខ្លួននោះទេ ។ ដូច្នេះតើលោកដឹងពីការចាប់ខ្លួននោះតាមរបៀបណា? ហេតុអ្វី? ហើយបន្ទាប់មកនរណាគេទៀតជាអ្នកទទួលតំណែងជំនួស ហ៊ុយ ស្រែ?

**ឆ៖** បាទ, ខ្ញុំបានដឹងពីរឿងចាប់ខ្លួនបងហ៊ុយ ដល់ហើយបានផ្អើលពេញថា ចាប់បងហ៊ុយហើយ ។ ចាប់ បងហ៊ុយ ហ្នឹងហើយ គឺ ផល គឺជាអ្នកកាន់កាប់នៅកន្លែងព្រៃសហ្នឹង ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ សាក្សីរូបនេះ គឺគាត់បានផ្តល់ភស្តុតាងយ៉ាងច្រើនទាក់ទងនឹងទំនាក់ទំនងរវាង ហ៊ា និង ឌុច ។ ដូចដែលលោក លោកស្រីចៅក្រមបានឮហើយ នៅពេលដែលជនជាប់ចោទបានផ្តល់ការសង្កេតទៅលើភស្តុតាងទាំងអស់នេះ គាត់ជឿថាភាគច្រើន គឺពិត ។ ហើយនៅក្នុងការដែលយើងដេញដោលទៅលើសាក្សីនេះ យើងមិនមានឃើញការតតាំងអង្គហេតុផ្សេងៗទាក់ទងទៅនឹង ហ៊ា និង ឌុច ។ ដូច្នេះ ហើយវាជាផលប្រយោជន៍ដែលថា លោក លោកស្រីចៅក្រមអាចសួរជនជាប់ចោទទៅលើបញ្ហា ហ៊ា និង ឌុច ។ ហើយថាតើ ឌុច នោះ គឺគាត់បានស៊ើបអង្កេតទៅលើ ហ៊ា ដែរ ឬទេនៅក្នុងអំឡុងពេលនោះ? ហើយថាតើ ឌុច បានសម្លាប់ ហ៊ា ដែរឬទេ? ហើយចំណុចទីបួន ប្រសិនបើ

គាត់មិនសម្លាប់ ហ៊ ទេ តើនរណាគេជាអ្នកសម្លាប់ ហើយគាត់ស្លាប់យ៉ាងម៉េច? សំណួរនេះ មិនទាន់ត្រូវបានសួរទៅ ឌុច ទេទាក់ទងទៅនឹងអង្គហេតុទាំងអស់នេះ ។ លើកលែងតែយើងសួរ យើងនឹងដឹង ហើយប្រសិនបើយើងមិនសួរទេ គឺថាយើងមិនទទួលបានភស្តុតាងដែលលោក លោកស្រីចៅក្រមចង់បានទេ ។ វាជាចំណុចមួយដែលសំខាន់ណាស់ ដូច្នេះហើយខ្ញុំសូមស្នើថា ឲ្យសួរសំណួរទាំងអស់នេះទៅកាន់ជនជាប់ចោទ ។

[១៤:៥៩:០៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីការពារ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមានការសោកស្តាយដែលសហព្រះរាជអាជ្ញាមិនបានសួរសំណួរបែបនេះ នៅពេលដែលគាត់តាំងសំណួរនោះ ។ ដូច្នេះហើយ ប្រសិនបើសហព្រះរាជអាជ្ញាមានបំណងក្នុងការនិយាយនិងសួរបន្ទាប់ពីមេធាវីការពារក្តីនោះ មេធាវីការពារក្តី យើងសូមស្នើសុំពេលវេលានោះដែរនោះ ស្មើគ្នា បើសិនមិនអ៊ីចឹងទេយើងឈប់ទាំងអស់គ្នានៅពេលនេះ ។ លោកសហព្រះរាជអាជ្ញាលោកមានពេលវេលាគ្រប់គ្រាន់តាំងសំណួរហើយមុនហ្នឹងនោះ ។

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតទៀតទេ សហព្រះរាជអាជ្ញា ។ អង្គជំនុំជម្រះមិនអនុញ្ញាតទេ ។

ការស្តាប់សក្ខីកម្មសាក្សីឈ្មោះ ហ៊ឹម ហ៊ុយ អង្គជំនុំជម្រះយល់ថាដល់ទីបញ្ចប់ហើយ ។ លោក ហ៊ឹម ហ៊ុយ អង្គជំនុំជម្រះសូមអរគុណលោក ដែលបានអញ្ជើញចូលរួមនៅក្នុងដំណើរការសវនាការផ្តល់សក្ខីកម្មតាមការកោះអញ្ជើញរបស់អង្គជំនុំជម្រះ ។ អង្គជំនុំជម្រះក៏បានយល់អំពីបញ្ហាលំបាករបស់លោកសាក្សី ប្រឈមនឹងបញ្ហាជាច្រើននៅក្នុងអំឡុងពេលឆ្លើយនឹងសំណួរផ្សេងពីអង្គជំនុំជម្រះ និងពីភាគីនានា ម្យ៉ាងទៀតរឿងហេតុហ្នឹង កើតឡើងជាងសាមសិបឆ្នាំមកហើយ ការចងចាំរបស់មនុស្សដែលរឿងហេតុដែលកើតឡើងជាងសាមសិបឆ្នាំដូច្នេះ គឺក៏មានការលំបាកក្នុងការចងចាំឲ្យបានសព្វគ្រប់នោះដែរ ។ ប៉ុន្តែទោះបីយ៉ាងណាអង្គជំនុំជម្រះអរគុណ ដល់លោកសាក្សីដែលបានធ្វើសក្ខីកម្មកន្លងមកនេះ ។

មន្ត្រីនាំសាក្សីរូបនេះ ជូនទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីឲ្យគាត់រៀបចំជូនគាត់

ត្រឡប់ទៅលំនៅដ្ឋានវិញ ។ ដោយឡែក អង្គជំនុំជម្រះឥឡូវនេះសម្រាកម្ភៃនាទីរហូតដល់ម៉ោងបី និងម្ភៃនាទីចូលវិញ ។ ប៉ុន្តែ អង្គជំនុំជម្រះសូមជម្រាបជូនដល់សាធារណជនឲ្យបានជ្រាបថា តាមពេលវេលាដែលបានកំណត់នេះ គឺដោយសារអង្គជំនុំជម្រះត្រូវបើកកិច្ចប្រជុំអសារធាណៈ ដើម្បីពិភាក្សាផ្ទៃក្នុងនៃអ្នកដំណើរការនីតិវិធី ដែលតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងកាលពីព្រឹកមិញ ដែលមិនទាន់បានពិភាក្សានៅឡើយនោះ ។ ដូច្នេះ ដំណើរការទៅមុខនេះ គឺអង្គជំនុំជម្រះនឹងធ្វើអសាធារណៈ ដោយពិភាក្សាអំពីការងារបច្ចេកទេសប៉ុណ្ណោះ។ ដូច្នេះ សាធារណជនអាចត្រឡប់អញ្ជើញទៅលំនៅដ្ឋានបានហើយ ។ ដោយឡែក គឺខាងភាគីទាំងអស់ គឺសូមអញ្ជើញចូលរួមប្រជុំបន្ត នៅបន្ទាប់ពីសម្រាកម្ភៃនាទី ។

ខ្ញុំសូមបញ្ជាក់បន្ថែមសាធារណជនថា អង្គជំនុំជម្រះនឹងមិនធ្វើការស្តាប់សក្ខីកម្ម របស់សាក្សីតាមកម្មវិធី ដែលត្រូវបន្តទៀតទេ ។ ដោយមូលហេតុពេលវេលាខ្លីពេក ហើយពេលវេលាដែលនៅសេសសល់បន្ទាប់ពីសម្រាកនោះ អង្គជំនុំជម្រះហ្នឹង ពិភាក្សាអំពីបច្ចេកទេសផ្ទៃក្នុងដើម្បីដំណើរការសវនាការទៅមុខឲ្យបានល្អ ។ ដូច្នេះ សូមអញ្ជើញត្រឡប់ទៅលំនៅដ្ឋានចុះ បើទំនេរស្អែកអញ្ជើញមកបន្តស្តាប់សក្ខីកម្មសាក្សីតទៀត ៕

*[សវនាការសម្រាកនៅម៉ោង ១៥:០៤នាទី]*